ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ព្រះពុទ្ធនៅតែទទួល ទោះបី នួន ជា បដិសេធចោលសាសនា វត្តអារាម និងព្រះសង្ឃនៅពេលគាត់គ្រប់គ្រង
- ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកការយោគយល់ និងការរើសអើង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣៦ ខែសីហា ឆ្នាំ២០១៩

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២៣៦ ខែសីហា ឆ្នាំ២០១៩


## មាតិកា

### សំបុត្រ


◆ ព្រះពុទ្ធនៅតែទទួល ទោះបី នួន ជា បដិសេធ..........................១


### ផ្នែកឯកសារ


◆ ឡេ វ៉ាន់មិញ តួនាទីភ្នាក់ងារបោរកម្ម.................................... ៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ជំរំជនភៀសខ្លួននៅក្នុងប្រទេសហ្វីលីពីន................................ ៩
◆ សៀវភៅ «បូជាភ្លើង» និយាយអំពីអ្នករស់រានមានជីវិត...........១៣
◆ រឿងរ៉ាវរបស់ប្រជាជនចេញពីស្រុកវាលវែង......................... ១៦
◆ យន់ យ៉ោង ជីវិតមនុស្សតាំងពីកើតរហូតដល់ស្លាប់ត្រូវ.......... ២៥
◆ ការស្រឡាញ់ព្រៃឈើប្រៀបដូចជាស្រឡាញ់ ...................... ៣៤
◆ នួន ជា ជានរណា?....................................................... ៣៦
◆ សៀវភៅប្រវត្តិសាស្ត្រដែលបកប្រែជាខេមរៈភាសា................ ៤២


### ផ្នែកច្បាប់


◆ សេចក្ដីសង្ខេបសាលក្រមសំណុំរឿង០០២/០២......................៤៦


### វេទិកាពិភាក្សាសាធារណៈ


◆ និស្សិតមកពីឃ្វីនស៍លែន ស្វែងយល់ពី................................៤៩
◆ សិស្សអនុវិទ្យាល័យតាំងយ៉ចំនួន៩៣នាក់ទទួល ...................... ៥១
◆ ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកការយោគយល់ និង.................៥៤


### ទំព័រស្រាវជ្រាវរកគ្រួសារ


◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៩




ពុទ្ធបដិមាករដែលបាក់បែកក្រោមរបបខ្មែរក្រហម


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ស៊ិន ប៊ុនស៊ីម, សួត វិចិត្រ, លីម អិភីង, សុង ថាណៃ, វ៉ាន់ថាន់ ពៅដារ៉ា, ឡុង ដានី **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា, អ៊ុន សុដាវី, ដារ៉ាវដ្ឋ មេត្តា **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា **ក្រាហ្វិកកុំព្យូទ័រ៖** ផាត ចាន់សុនិតា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ព្រះពុទ្ធនៅតែទទួល ទោះបី នួន ជា បដិសេធចោលសាសនា វត្តអារាម និងព្រះសង្ឃ នៅពេលគាត់គ្រប់គ្រងអំណាច

ប្រជាជនកម្ពុជា ជាង៩៥ភាគរយ បានគោរពប្រណិប័តន៍ និងមានជំនឿយ៉ាងមុតមាំទៅលើព្រះពុទ្ធសាសនាតាំងពីយូយារណាស់មកហើយ ពីព្រោះព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម និងជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ដោយផ្តល់ជាកន្លែងសម្រាប់បណ្តុះបណ្តាល កន្លែងអប់រំ ប្រៀនប្រដៅដល់មនុស្សឲ្យវៀរចាកអំពើអាក្រក់ មកប្រព្រឹត្តល្អ និងជាកន្លែងសម្រាប់ព្យាបាលជំងឺទៀតផង។

ប៉ុន្តែចាប់តាំងពីរបបខ្មែរក្រហមបានឡើងកាន់អំណាច ព្រះពុទ្ធសាសនា ត្រូវបានបំបាត់ចោលទាំងស្រុងចេញពីសង្គម ហើយព្រះសង្ឃប្រមាណ៦០,០០០អង្គ (នៅមុនឆ្នាំ១៩៧៥) និងពុទ្ធសាសនិកដែលជាអ្នកប្រណិប័តន៍សាសនា បានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ។

នៅក្នុងសវនាការសួរដេញដោល ទៅលើភ័ស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីអំឡុងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ នួន ជា បានឆ្លើយថា«ការគោរពព្រះពុទ្ធសាសនា មិនបាច់មានវត្តអារាមទេ គឺប្រតិបត្តិនៅក្នុងចិត្តបាន



មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងមន្ត្រីទូតចិនរង់ចាំទទួលលោកជំទាវ តឹង យីងឆាវ (ភរិយា ជូ អេនឡាយ អតីតនាយករដ្ឋមន្ត្រីសាធារណរដ្ឋប្រជាមានិតចិន) នៅព្រលានយន្តហោះអន្តរជាតិ ពោធិ៍ចិនតុងថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨
រូបខាងឆ្វេងទី១ ៖ មិត្ត លីន (ជនជាតិចិន) ជាអ្នកបកប្រែ
រូបខាងឆ្វេងទី២ ៖ ស៊ុន ហាវ អគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំកម្ពុជាប្រជាធិបតេយ្យ
រូបស្ត្រីនៅកណ្តាលពាក់អាវស ៖ ខៀវ ប៉ុណ្ណារី (ភរិយារបស់ ប៉ុល ពត)
រូបបន្ទាប់ពីខៀវ ប៉ុណ្ណារី ៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
រូបស្ត្រីពាក់អាវសខាងស្តាំទី១ ៖ អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
រូបស្ត្រីពាក់អាវសខាងស្តាំទី២ ៖ យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌អប់រំ និងសិក្សាធិការ
រូបខាងស្តាំទី៣ ៖ ប៉ុល ពត នាយករដ្ឋមន្ត្រី និងលេខាបក្សកុម្មុយនីស្តកម្ពុជា
រូបខាងស្តាំទី៤ខាងក្រោយ ប៉ុល ពត ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

ហើយ។ ព្រះពុទ្ធទ្រង់ប្រសូត្រ និងត្រាស់ដឹងនៅក្នុងព្រៃដោយមិនមានកុដិទេ»។ នួន ជា បានបន្ថែមថា «ខ្លឹមសារពិតប្រាកដនៃព្រះពុទ្ធសាសានា រួមមាន ៖ សីលៈ សមាធិ និងបញ្ញា ដែលកើតឡើងនៅក្នុងចិត្ត គឺជាប់ជាមួយនឹងការរស់នៅរបស់ប្រជាជនជាប្រចាំ»។ នួន ជា បានអះអាងថា «បើទោះបីជាគ្មានការអុជធូប ថ្វាយបង្គំព្រះ ក៏ខ្លឹមសារស្ថិតនៅក្នុងចិត្តរបស់ខ្លួន និងប្រជាជន» ដែរ។ នួន ជា ថែមទាំងបានធ្វើការចោទប្រកាន់ប្រជាជន ដែលបានលើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យបានបំផ្លាញព្រះពុទ្ធសាសនាថា«ប្រជាជនទាំងនោះមិនយល់ពីខ្លឹមសារពិតប្រាកដរបស់ព្រះពុទ្ធសាសនា»។

នៅក្នុងរដ្ឋធម្មនុញ្ញ នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានអនុម័តកាលពីថ្ងៃទី១៤ខែធ្នូឆ្នាំ១៩៧៥ និងប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ត្រង់ជំពូកទី១៥ មាត្រា២០ ដែលលើកឡើង អំពីសិទ្ធិខាងជំនឿ និងសាសនាក៏បានចែងថា ៖ ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនជឿជំនឿអ្វី ឬមិនជឿសាសនាណាក៏ដោយ។ មិនអនុញ្ញាតឲ្យសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត។

នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភា តំណាងប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) ត្រូវចាប់ខ្លួន និងឃុំខ្លួនជាបណ្តោះអាសន្ននៅមន្ទីរឃុំឃាំង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ពាក់ព័ន្ធនឹងការបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន រួមទាំងការប្រព្រឹត្តមកលើពុទ្ធសាសនិក និងការដែលបណ្តាលឲ្យប្រជាជនកម្ពុជាជាងពីរលាននាក់បាត់បង់ជីវិត។ នួន ជា ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយសម្រេចរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរក្នុងករណីសំណុំរឿង០០២/០១ និង០០២/០២។

នៅក្នុងសាលក្រមសំណុំរឿង០០២/០២ ដែលកម្រិតត្រឹមតែសហករណ៍ត្រាំកក់ អង្គជំនុំជម្រះបានរកឃើញថា ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ និមិត្តរូបតំណាងឲ្យព្រះពុទ្ធត្រូវបានបំផ្លិចបំផ្លាញ ហើយវត្តអារាមមិនត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់គោលបំណងសាសនាទេ។

អង្គជំនុំជម្រះក៏បានរកឃើញថា ព្រះសង្ឃជាង១០០



រូបខាងស្តាំទី១ ពាក់អាវពណ៌ស៖ ឧត្តមសេនីយ៍ គីង ឃុនសាន ប្រធានក្រុមជំនា...
សានបានស្លាប់នៅកម្ពុជា ដោយជំងឺគ្រុនចាញ់នៅចុងឆ្នាំ១៩៧(៥)
រូបខាងស្តាំទី២៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក...
រូបខាងស្តាំទី៣៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
រូបខាងស្តាំទី៤៖ សុន សេន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

អង្គត្រូវបានខ្មែរក្រហមប្រមូលដោយចេតនា ហើយបង្ខំឲ្យសឹក។ ព្រះសង្ឃក៏ត្រូវបានបង្ខំឲ្យសឹកនៅតាមវត្តផ្សេងៗទៀតដែរ។ ថ្វីត្បិតតែភ័ស្តុតាង មិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសន្និដ្ឋានឲ្យបានច្បាស់លាស់អំពីចំនួនព្រះសង្ឃ ដែលលាចាកសិក្ខាបទសរុបនៅស្រុកត្រាំកក់ក៏ដោយ ក៏អង្គជំនុំជម្រះ

យល់ឃើញថា មានភស្តុតាងអាចឲ្យជឿទុកចិត្តបានដែលបង្ហាញថា ព្រះសង្ឃរាប់រយអង្គត្រូវបានគេជម្លៀសនៅតាមឃុំនានា។ បេតនារើសអើងនេះត្រូវបានបញ្ជាក់ដោយការហៅព្រះសង្ឃថាជា «គេនញ៉ា» ឬជា «ឈ្លើង»សង្គម និងការប្រកាសបដិសេធព្រះពុទ្ធសាសនា ដោយថាជាអបិយជំនឿសុទ្ធសាធនិងថាព្រះពុទ្ធបដិមា«គ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ»



...ការចិនប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ (ឧត្តមសេនីយ៍ គឹង យុន
...កុម្មុយនីស្តកម្ពុជា

ដែលអង្គជំនុំជម្រះយល់ឃើញថា ទង្វើទាំងនេះគឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ហើយបានប្រព្រឹត្តទៅលើពុទ្ធសាសនិក។

យោងតាមការរៀបរាប់របស់ប្រជាជន ដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) បទសម្ភាសន៍ឯកសាររាប់ម៉ឺនទំព័រ និងរូបថតដែលនៅសេសសល់ បានបញ្ជាក់យ៉ាងច្បាស់ថា ខ្មែរក្រហមបានបំផ្លិចបំផ្លាញ គម្ពីរ ក្បួនខ្នាត វាយកម្ទេចវត្តអារាម កុដិព្រះវិហារ ជម្លៀសព្រះសង្ឃ សម្លាប់ព្រះសង្ឃ និងបង្ខំព្រះសង្ឃឲ្យយកប្រពន្ធ ដែលជាការប្រព្រឹត្តបំពានយ៉ាងធ្ងន់ធ្ងរទៅលើព្រះពុទ្ធសាសនា។

នួន ជា បានស្លាប់ដោយសារជំងឺ និងភាពចាស់ជរាក្នុងអាយុ៩៣ឆ្នាំ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត (ឬមន្ទីរពេទ្យរុស្ស៊ី) នៅវេលាល្ងាចថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។ នៅព្រលឹមថ្ងៃបន្ទាប់ សពរបស់ នួន ជា ត្រូវបានក្រុមគ្រួសារដឹកតាមរថយន្តទៅ ធ្វើបុណ្យតាមព្រះពុទ្ធសាសនានៅវត្តព្រហ្មគិរីមរកត ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីព្រំដែនខ្មែរ-ថៃក្នុងភូមិផ្សារព្រំដើង ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិនជាទឹកន្លែង ដែលគាត់និងអតីតកងកម្លាំងខ្មែរក្រហមរស់នៅបន្ទាប់ពីបានផ្តាច់ខ្លួន និងធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅដើមឆ្នាំ១៩៩៩។

សពរបស់ នួន ជា គ្រោងនឹងធ្វើនឹងតម្កល់ទុកធ្វើបុណ្យរយៈពេលប្រាំពីរថ្ងៃ និងធ្វើការបូជាទៅតាមទំនៀមទម្លាប់ព្រះពុទ្ធសាសានា ផ្ទុយទៅនឹងពេលដែលគាត់នៅគ្រប់គ្រងអំណាច និងនៅពេលរស់រានមានជីវិតបានបដិសេធបោលទាំងស្រុងព្រះពុទ្ធសាសនា និងបន្ទុះបង្អាប់ព្រះសង្ឃ។ ទោះបីយ៉ាងណានៅក្នុងគម្ពីរធម្មបទកថាភាគទី១ នៃព្រះពុទ្ធសាសនា បានចែងអំពី «ការចងពៀរ រំងាប់ដោយការមិនចងពៀរ» ដោយព្រះពុទ្ធនៅតែទទួល នួន ជា ជាមួយនឹងជីវិតចុងក្រោយរបស់គាត់។

បើតាមព្រះតេជគុណ ប៊ុន សាលួត ព្រះមេគុណខេត្តឧត្តរមានជ័យ មានសង្ឃដីកាថា ព្រះពុទ្ធនៅតែទទួល នួន ជា ប៉ុន្តែអំពើរបស់ នួន ជា ដែលធ្លាប់បានប្រព្រឹត្តមកលើព្រះពុទ្ធសាសនានិងប្រជាជនហើយបណ្តាលឲ្យមនុស្សស្លាប់នោះ នួន ជា មិនអាចរួចផុតពីបាបរបស់គាត់បានឡើយ។

**សោម ប៊ុនថន**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងវេជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាន ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# ឡេ វ៉ាន់មិញ គួនាទីភ្នាក់ងារចារកម្ម

ឡេ វ៉ាន់មិញអាយុ ៥៥ឆ្នាំ(១៩៧៨)នាទីចារកម្មរបស់ប្រធានឃុំតិនឡិបស្រុកម៉ុកវ៉ា ខេត្តឡុងអាន។ ឡេ វ៉ាន់មិញ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៨ នៅភូមិចន្ទ្រាក្នុងខេត្តស្វាយរៀង។ បន្ទាប់ពីបានចាប់ខ្លួនរួចមក វ៉ាន់មិញ បានឆ្លើយសារភាពទៅកាន់អ្នកសួរចម្លើយដូចខាងក្រោម៖

ខ្ញុំបាទកើតនៅភូមិ៤ ក្នុងឃុំតិនឡិប ស្រុកម៉ុកវ៉ា ខេត្តឡុងអាន ប្រទេសវៀតណាមខាងត្បូង។ ខ្ញុំគឺជាអតីតទាហានធីវគឺ។កាលពីខែសីហា ឆ្នាំ១៩៧៥ប្រពន្ធខ្ញុំបាននិយាយប្រាប់ខ្ញុំថានៅដើមខែសីហានេះនឹងមានខ្មែរកម្ពុជាក្រោមចំនួន ១៥០នាក់ នៅឃុំប៊ិញវ៉ាតិន មកធ្វើបាតុកម្មប្រឆាំងបក្សវៀតណាមដោយសារតែបក្សវៀតណាមបានប្ញន់យកផ្ទះសម្បែង



ផាម ថាន់មិន ទាហានកងវរសេនាធំ២០១ របស់ខេត្តតាយនិញ សមរភូមិខេត្តស្វាយរៀង

ដីស្រែ និងស្រូវព្រមទាំងចាប់បញ្ជូនប្រជាជនឲ្យទៅរស់នៅតំបន់សេដ្ឋកិច្ចថ្មីដែលជាកន្លែងគ្រុនចាញ់ និងមិនអាចប្រកបរបរធ្វើស្រែបាន។ ដល់ខែកញ្ញាក្នុងឆ្នាំដដែលប្រពន្ធរបស់ខ្ញុំបានយកមាសដំឡឹង និងប្រាក់សុទ្ធចំនួន៩០.០០០ដុងយកទៅសូកឈ្មោះហាយហួយមានតួនាទីជាប្រធានគុកម៉ុកវ៉ា ដើម្បីដោះលែងខ្ញុំឲ្យចេញពីគុក។ រហូតដល់ចុងឆ្នាំ១៩៧៥ ប្រពន្ធរបស់ខ្ញុំធ្វើស្រូវបាន៦០ថាំង ពេលនោះបក្សវៀតណាមបានមកប្លន់អស់៧០% នៃចំនួនស្រូវដែលប្រពន្ធរបស់ខ្ញុំប្រមូលផលបាន ហើយប្រជាជនវៀតណាមដទៃទៀត ក៏ត្រូវបានបក្សវៀតណាមជិះជាន់ដូចជាគ្រួសារខ្ញុំដែរ។



កងទ័ពវៀតណាមដែលយោធាខ្មែរក្រហមចាប់មកឃុំខ្លួននៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង

ជាមួយគ្នានេះ បក្សវៀតណាមក៏បានដើរបោកប្រាស់ប្រជាជនថា ៖ «ប្រជាជនយើងទាំងអស់គ្នាអត់មានគោក្របីធ្វើស្រែទេ ដូច្នេះប្រជាជនទាំងអស់ត្រូវបង់ថ្លៃប្រេង២.០០០ដុង ក្នុងមួយហិចតាឲ្យបក្សយើង ហើយបក្សវៀតណាមយើងនឹងយកត្រាក់ទ័រមកភ្ជួរស្រែឲ្យអ្នករាល់គ្នា។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ បក្សវៀតណាមកក៏បានយកត្រាក់ទ័រមកភ្ជួរតាមការសន្យាពិតមែន ប៉ុន្តែភ្ជួរស្រែបានត្រឹមតែ១ទៅ២ហិចតាប៉ុណ្ណោះ ក៏ប្រាប់ប្រជាជនថាត្រាក់ទ័រខូច។ ក្រោយមក បក្សវៀតណាមក៏បានបង្ខំឲ្យប្រជាជនបង់ប្រាក់ចំនួន៥.០០០ដុង បន្ថែមទៀតដើម្បីជួសជុលត្រាក់ទ័រ។ មិនយូរប៉ុន្មាន ប្រជាជនក៏អស់ភាពអត់ធ្មត់ជាមួយបក្សវៀតណាមហើយសម្រេចចិត្តធ្វើបាតុកម្មនៅស្រុកម៉ុកវ៉ាដែលរួមមានប្រជាជនក្នុងឃុំតិនឡិប ឃុំប៊ិញវ៉ាតិន និងឃុំតាញ់វ៉ា។

រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧ បក្សវៀតណាមបានប្រើប្រាស់នយោបាយដោយចង់បំបាត់ពូជសាសន៍ខ្មែរកម្ពុជាក្រោមយ៉ាងព្រៃផ្សៃបំផុត។ បក្សវៀតណាមបានអនុវត្តផែនការចាប់ចង និងដាក់គុកច្រវ៉ាក់ប្រជាជនខ្មែរកម្ពុជាក្រោមនៅស្រុកម៉ុកវ៉ាទាំងអស់ជាបន្តបន្ទាប់តាមគ្រប់កលល្បិច។ នៅដើមឆ្នាំ១៩៧៨ កងពលលេខ៨ ដែលឈរជើងនៅស្រុកម៉ុកវ៉ាបានបាញ់សម្លាប់ប្រជាជនម្នាក់ដើម្បីប្លន់យកត្រី។

បន្ទាប់មកបក្សវៀតណាមបាននិយាយកុហកប្រជាជនថា កងទ័ពកម្ពុជាជាអ្នកបាញ់សម្លាប់។ មិនតែប៉ុណ្ណោះ ទាហានកងពលលេខ៨នេះ ក៏បានផ្ទោងគ្រាប់កាំភ្លើងទំហំ៨០មីលីម៉ែត្រ ឆ្ពោះទៅភូមិសុកមួន ចំប្រជាជនមួយក្រុមដែលកំពុងដើររើសកួរស្រូវក្នុងស្រែ ដែលច្រូតកាត់រួចហើយ បណ្តាលឲ្យស្លាប់ម្នាក់ និងរងរបួស៤នាក់។

នៅខែឧសភា ឆ្នាំ១៩៧៨ ក្មួយខ្ញុំឈ្មោះ ផាន គិញ មកពីខេត្តតៃនិញ បាននិយាយប្រាប់ខ្ញុំថា ទាហានកងពលទី៩ ពួកជីវគី និងអ្នកកាន់សាសនាវ៉ាហាវនៅភ្នំដូនខ្មៅ បានវាយតទល់ជាមួយទាហានវៀតណាមជាប់រហូតមក ហើយសព្វថ្ងៃនេះក៏បានផ្ទោងកាំភ្លើងធំដាក់ក្រុងតៃនិញជាញឹកញាប់ដែរ។

ក្នុងខែខសភានេះមានលោកយាយម្នាក់អាយុ៨០ឆ្នាំ បាននិយាយប្រាប់ខ្ញុំថាគួរឲ្យខ្លាចផង្វាណាស់ ដែលបក្សវៀតណាមកាប់សម្លាប់ប្រជាជនខ្មែរកម្ពុជាក្រោម ដែលជាម្ចាស់ទឹកដីនេះយ៉ាងព្រៃផ្សៃ។ បក្សវៀតណាមបានយកកប៉ាល់ចុងញឹកទៅដឹកខ្មែរកម្ពុជាក្រោមនៅឃុំតិនឡិប ឃុំថាញ់វ៉ា និងឃុំប៊ិញវ៉ាតិនទៅប្រានទម្លាក់ទឹកទន្លេឡុងអានអស់រាប់រយពាន់នាក់។ ហេតុការណ៍ទាំងនេះបានធ្វើឲ្យប្រជាជនខ្មែរកម្ពុជាក្រោម នឹកឃើញដល់រឿងកំពប់តែអុងសម័យទ្រឿងមិញយ៉ាងមកវិញ។ពេលនោះខ្មែរកម្ពុជាក្រោមក៏ងើបឈរឡើងវិញ ដើម្បីតស៊ូវាយបក្សវៀតណាមដណ្តើមអាវុធ ហើយបន្តការតស៊ូយ៉ាងខ្លាំងក្លាបំផុត។

នៅខែមិថុនាឆ្នាំ១៩៧៨បក្សវៀតណាមបានដឹកនាំទ័ពនិងកាំភ្លើងធំមកត្រៀមនៅព្រំដែនកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដូចជានៅប៊ិញចូវ ព្រែកទៀនប៊ិញ និងនៅយូម៉ង់ដា។ ដល់ខែកក្កដា ក្នុងឆ្នាំដដែល រដ្ឋការខេត្តឡុងអានបានដើរខបាយកលខ្ទីស្រូវប្រជាជន ដោយប្រជាជនមិនអាចប្រកែកតវ៉ាបានឡើយ។ ប្រជាជនក៏ចាប់ផ្តើមអត់ឃ្លាន និងស្លាប់ជាបន្តបន្ទាប់ៗរហូតដល់ខែសីហា ក៏មានទឹកជំនន់ជន់លិចភាគខាងត្បូងប្រទេសវៀតណាម ហើយប្រជាជនរាប់សិបពាន់នាក់បានលង់ទឹក និងដាច់ពោះស្លាប់ទៀតផង។ ប្រជាជននៅក្នុងឃុំតិនឡិបចាប់ផ្តើមស្លាប់មួយថ្ងៃពី១០ ទៅ ២០នាក់។

ក្រោយមក រដ្ឋការវៀតណាមតាមភូមិ ឃុំ ស្រុក ក៏បានយកឱកាសនេះដើម្បីសុំជំនួយពីបរទេសធ្វើជានុយ ក្នុងការបោកបញ្ឆោតប្រជាជនថា «ប្រសិនបើឲ្យកូនៗទៅធ្វើទាហានឈ្លានពានកម្ពុជា ជំនួយទាំងនេះនឹងត្រូវប្រគល់ឲ្យអ្នកទាំងអស់គ្នា»។ ជាក់ស្តែង បក្សវៀតណាមនេះមិនបានប្រគល់អង្ករសូម្បីតែមួយគ្រាប់ ឲ្យប្រជាជននោះទេ។ តទៀត បងត្រិនវ៉ាន់ដូ បងត្រិន វ៉ាន់ដុង និងបងងៀងជីកក់ បាននិយាយថា គាត់ត្រូវបានពួករដ្ឋការកេណ្ឌឲ្យដឹកជញ្ជូនជំនួយពីបរទេសដើម្បីប្រគល់ឲ្យប្រជាជនដែលរងគ្រោះដោយសារទឹកជំនន់ ប៉ុន្តែពួករដ្ឋការបានបញ្ជាឲ្យខ្ញុំយកទៅដាក់នៅក្នុងឃ្លាំងយោធា ហើយត្រូវហែកផ្លាកបំបាត់ភ័ស្តុតាងមិនឲ្យប្រជាជនដឹង និងស្គាល់ទៀតផង។

ពេលទឹកជំនន់ក្នុងឆ្នាំនេះ រដ្ឋការវៀតណាមក៏បានដឹកខ្មែរកម្ពុជាក្រោមនៅស្រុកម៉ុកវ៉ាជាច្រើនកប៉ាល់ យកទៅទម្លាក់ទឹកទន្លេទៀងញ៉ងជិត ដែលស្ថិតនៅទីប្រជុំជនខេត្តឡុងអាន។ ដល់ខែកញ្ញាឆ្នាំ១៩៧៨នេះឡេវ៉ាន់ជី ដែលជាប្រធានឃុំរបស់ខ្ញុំ បានលួចទូកប្រជាជនលក់ឲ្យឈ្មួញ និងលួចអង្ករពីឃ្លាំងរដ្ឋដាក់ទូកទៅលក់នៅឯព្រៃនគរ។

ប្រជាជនចំនួន៥០ទូក ក៏បានធ្វើបាតុកម្មទាមទារអង្ករនិងបានបរិហារអំពីសកម្មភាពដែលលួចអង្ករ និងលួចទូករបស់ខ្លួន។នៅពាក់កណ្តាលខែកញ្ញានេះ ប្រជាជនភូមិលេខ៤ព្រែកជីកលេខ១២ ចំនួន៤២នាក់ ព្រមទាំងមានកូនស្រីរបស់ខ្ញុំពីរនាក់ផ្សេងទៀតបានធ្វើបាតុកម្មវាយឃ្លាំងស្រូវ និងឃ្លាំងកន្ទក់របស់កងពលលេខ៨នៅភូមិទៀនថាញ់ ស្រុកម៉ុកវ៉ា។ មួយរំពេចនោះ ស្រាប់តែមានទាហានកងពលលេខ៨នាំគ្នាមកព័ទ្ធបាញ់ ហើយមានប្រជាជនរងរបួសចំនួនបីនាក់និងចាប់បានប្រជាជនផ្សេងទៀត។

រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៨ ឈ្មោះ ឡេវ៉ាន់ជីនាទីប្រធានឃុំនិងឈ្មោះក្វាន នាទីប្រធាននគរបាលឃុំតិនឡិបបានបញ្ជាឲ្យ ហាយ វិន ប្រធានស្រុកម៉ុកវ៉ា ចាត់តាំងខ្ញុំឲ្យចូលស៊ើបការនៅភូមិចន្ទ្រា ខេត្តស្វាយរៀងប្រទេសកម្ពុជាដើម្បីឲ្យបក្សវាយកម្ពុជានៅរដូវប្រាំងខាងមុខនេះ។

ពេលនោះ ខ្ញុំក៏បានប្រកែកតវ៉ាដែរ ប៉ុន្តែមិនបានសម្រេចឡើយ។ម្យ៉ាងទៀត ខ្ញុំក៏ព្រួយបារម្ភអំពីអាយុជីវិតប្រពន្ធកូនខ្ញុំដែរ ទើបខ្ញុំបានសម្រេចចិត្តធ្វើតាមបង្គាប់បញ្ជារបស់ថ្នាក់លើ។ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៨ ឈ្លបរបស់ ឡេវ៉ាន់ជី បានជូនខ្ញុំទៅព្រំដែនកម្ពុជា ហើយបានបង្ខំឲ្យខ្ញុំចូលភូមិចន្ទ្រា ក្នុងខេត្តស្វាយរៀងភ្លាមៗ។ ក្រោយនោះបន្តិច ខ្ញុំក៏ធ្លាក់ចូលក្នុងដៃកងឈ្លបរបស់កម្ពុជាតែម្តង។

**ហូ ថុនា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង យី សុខី តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthsokhy.y@dccam.org។
















# ជំរំជនភៀសខ្លួននៅក្នុងប្រទេសហ្វីលីពីន៖ ផ្សារភ្ជាប់ទំនាក់ទំនង រវាងប្រជាជនខ្មែរ និងប្រជាជនហ្វីលីពីន

ប្រជាជនខ្មែរ និងប្រជាជនហ្វីលីពីនបានស្វែងយល់ពីគ្នាជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់ៗ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ប្រជាជនខ្មែរបានរត់ភៀសខ្លួនទៅរស់នៅលើទឹកដី នៃប្រទេសហ្វីលីពីនចំនួនប្រមាណ១០ភាគរយប្រៀបធៀបទៅនឹងជនភៀសខ្លួន មកពីប្រទេសឥណ្ឌូចិនសរុបប្រមាណ៤០០.០០០នាក់ៗ សង្គ្រាមបានធ្វើ ឲ្យប្រជាជនខ្មែរបង្ខំចិត្តចាកចេញពីក្រុមគ្រួសារ ធ្វើចំណាកស្រុកទៅរស់នៅខាងក្រៅប្រទេសដើម្បីរក្សាសុវត្ថិភាព និងមិនវិលត្រឡប់ចូលមករស់នៅ ក្នុងទឹកដីកំណើតប្រទេសខ្លួនវិញឡើយៗ

នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ ប៉ុល ពត ក្នុងរបបខ្មែរក្រហម ប្រជាជនខ្មែរតែងតែគិតអំពីការរត់គេចទៅរស់នៅកន្លែងផ្សេងៗ ដែលអាចរក្សាសុវត្ថិភាពដល់ខ្លួន និងក្រុមគ្រួសារៗ ប្រជាជនមួយចំនួនត្រូវបានខ្មែរក្រហមសម្លាប់នៅពេលដឹងអំពីផែនការរត់គេចខ្លួន ហើយប្រជាជនផ្សេងទៀតក៏បានរត់រួចដោយសុវត្ថិភាពៗ នាចុងឆ្នាំ១៩៧៨ នៅពេលដែល កងទ័ពវៀតណាមបានវាយចូលមករំដោះប្រទេសកម្ពុជាទាំងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមបានបន្តរត់គេចខ្លួនទៅកាន់ព្រំដែននៃប្រទេសថៃ និងរស់នៅតាមជំរំនៅទីនោះៗ ដោយមូលហេតុ នៃការមិនទុកចិត្ត និងភ័យខ្លាចថា សង្គ្រាមនឹងអាចកើតមានឡើងម្តងទៀត ប្រជាជនខ្មែរទាំងនោះ បានរិះរកមធ្យោបាយបន្តរត់គេចខ្លួនទៅរស់នៅប្រទេសផ្សេងៗទៀតដូចជា ប្រទេសកាណាដាន័រវេស អូស្ត្រាលី បារាំង និងអាមេរិកដោយបានធ្វើដំណើរមកស្នាក់នៅក្នុងមណ្ឌលរៀបចំជនភៀសខ្លួន នៅក្នុងប្រទេស



រូបចម្លាក់ដែលតំណាងឲ្យជនភៀសខ្លួនខ្មែរនៅក្នុងប្រទេសហ្វីលីពីន

ហ្វីលីពីន ដែលត្រូវបានហៅថាជំរំជនភៀសខ្លួនបាតាអាន ស្ថិតនៅក្នុងខេត្តបាតាអាន ក្រុងម៉ូរ៉ុងនៃប្រទេសហ្វីលីពីន ដែលជាចំណតចុងក្រោយ នៃជំរំភៀសខ្លួនសម្រាប់ប្រទេសនៅក្នុងឥណ្ឌូចិន។

ជំរំជនភៀសខ្លួនបាតាអាន មានចម្ងាយ១៣០គីឡូម៉ែត្រពីទីក្រុងនីឡា នៃប្រទេសហ្វីលីពីន។នៅពេលដែលយើងធ្វើដំណើរទៅកាន់ ជំរំជនភៀសខ្លួនបាតាអានយើងឃើញមានវាលស្រែ និងជ្រលងភ្នំភ្លើងដ៏វែងអន្លាយតភ្ជាប់គ្នានៅតាមផ្លូវ។ យើងត្រូវធ្វើដំណើរស្របទៅតាមផ្ទៃទឹក សមុទ្រដ៏ធំល្វឹងល្វើយនៃឈូងសមុទ្រស៊ូប៊ីក ដែលមានកប៉ាល់ធំៗជាច្រើនចតនៅទីនោះ។ សព្វថ្ងៃ ជំរំជនភៀសខ្លួនបាតាអាន គឺជាឧទ្យានមួយដែលមានសភាពស្ងប់ស្ងាត់ និងពោរពេញទៅដោយភាពស្រស់បំព្រងនៃសម្រស់ធម្មជាតិ។ នៅក្នុងជំរំបានរៀបចំបង្កើតសារមន្ទីរមួយ ដែលបានសរសេរនៅពីខាងមុខក្លោងទ្វារថា សារមន្ទីរ បណ្ណាល័យ និងបណ្ណសារដ្ឋាន ដែលនេះជាទីកន្លែងសម្រាប់ ដាក់តាំងសម្ភារប្រើប្រាស់ដែលជនភៀសខ្លួនធ្លាប់បានប្រើប្រាស់នាពេលនោះ និងថែមទាំងមានបន្សល់ទុក សាលារៀន និងទីកន្លែងគោរពបូជាសាសនាដែលជនភៀសខ្លួនបានប្រើប្រាស់នាពេលនោះ។ សម្ភារទាំងអស់បានបង្ហាញអំពីអត្តសញ្ញាណរបស់ជនភៀសខ្លួនមកពីបណ្ដាប្រទេសនីមួយៗ។ ជនភៀសខ្លួនខ្មែរបានបន្សល់ទុកនូវសារុងដែលខ្លួនប្រើប្រាស់អំឡុងពេលនោះ ថែមទាំងបានបន្សល់ទុកអត្តសញ្ញាណជាតិនៅលើទឹកដីនៃប្រទេសហ្វីលីពីន ដូចជាការសាងសង់និមិត្តរូបនៃប្រាសាទអង្គរវត្ត ប្រាសាទបាយ័នវត្តអារាម និងប្រពៃណីវប្បធម៌ផ្សេងៗរបស់ខ្លួន។

ជំរំជនភៀសខ្លួនបាតាអានបានបង្កើតឡើងនៅថ្ងៃទី២ ១ មករា ឆ្នាំ១៩៨០ ក្រោមកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលហ្វីលីពីន និងអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក្នុងគោលបំណងជួយដល់ជនរងគ្រោះដែលបានគេចខ្លួនពីការធ្វើទារុណកម្មការសម្លាប់ នៅក្នុងប្រទេសរបស់ខ្លួនដែលកំពុងតែជួបប្រទះនឹងសង្គ្រាម។ ជំរំនេះមានផ្ទៃដីសរុបប្រមាណ៣៦៥ហិចតា ស្ថិតនៅភាគខាងជើងនៃឈូងទ្រស៊ូប៊ីក។ ជំរំជនភៀសខ្លួនបាតាអានមិនត្រឹមតែជាកន្លែងទទួលជនភៀសខ្លួនឲ្យមកស្នាក់នៅនោះទេ ប៉ុន្តែជំរំនេះគឺជាកន្លែងមួយសម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល ផ្នែកភាសាការងារ និងជំនាញផ្សេងៗដល់ជនភៀសខ្លួនដែលនឹងធ្វើដំណើរ


ប្រាសាទបុរាណដែលតំណាងឲ្យជនភៀសខ្លួនកម្ពុជានៅក្នុងប្រទេសហ្វីលីពីន

ទៅរស់នៅក្នុងប្រទេសប្រទេសទីពី។ ជំរំជនភៀសខ្លួនបាតាអានបានរៀបចំរចនាសម្ព័នដូចទីក្រុងតូចមួយ ដែលមានកន្លែងសម្រាប់ស្នាក់នៅសាលារៀន មន្ទីរពេទ្យ បណ្ណាល័យ អាហារដ្ឋានកន្លែងកីឡាមណ្ឌលអប់រំ កន្លែងហ្វឹកហ្វឺត់ការងារ និងទីតាំងគោរពបូជាសាសនាសម្រាប់ជនភៀសខ្លួនទាំងអស់។

ទោះបីជាជំរំជនភៀសខ្លួនបាតាអានបានផ្អាកដំណើរការអស់រយៈពេលប្រហែលជិត៣០ឆ្នាំ ក៏ដោយប៉ុន្តែយើងឃើញមានការបន្តអភិវឌ្ឍទៅលើតំបន់នោះបានយ៉ាងល្អ។ មគ្គុទ្ទេសក៍ទេសចរណ៍ដែលកំពុង ធ្វើការនៅក្នុងជំរំជនភៀសខ្លួនបាតាអានបាននិយាយថា ៖

« ជារឿយៗក្រុមសិស្សនិស្សិតនៅក្នុងប្រទេសហ្វីលីពីនបានធ្វើដំណើរមកទស្សនា និងសិក្សាស្វែងយល់អំពីជំរំជនភៀសខ្លួននេះ។ចំណែកឯជនជាតិបរទេសក៏បានធ្វើដំណើរមកទស្សនាយ៉ាងច្រើនកុះករដែរ»។លោកបានបន្ថែមទៀតថា « អតីតជនភៀសខ្លួនជនជាតិខ្មែរម្នាក់ដែលធ្លាប់បានភៀសខ្លួនមកស្នាក់នៅក្នុងជំរំនេះឈ្មោះលោក ឆាំង យុ ជារឿយៗបានធ្វើដំណើរមកពី ប្រទេសកម្ពុជាមកទស្សនាជំរំនេះដែលជាទីកន្លែងគាត់ធ្លាប់រស់នៅ»។

ជំរំភៀសខ្លួនម៉ូរ៉ុងបានបន្តចំណងមិត្តភាព និងផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីររហូតដល់សព្វថ្ងៃនេះ។ លោកស្រីសាស្ត្រាចារ្យឈ្មោះ ហប គីចាណូ ដែលជាសាស្ត្រាចារ្យជំនាញភាសាអង់គ្លេស នៅសាកលវិទ្យាល័យដូលម៉ានីឡា បានចែករំលែកបទពិសោធន៍របស់គាត់ថា ៖ នៅពេលដែលខ្ញុំឮឈ្មោះប្រទេសកម្ពុជា រឿងដែលខ្ញុំនឹកឃើញដំបូងគេគឺពាក្យថាខ្មែរក្រហម។

នៅក្នុងអំឡុងឆ្នាំ១៩៩០ ខ្ញុំគឺជាគ្រូបង្រៀននៅសាលាអន្តរជាតិប្រែនដែលស្ថិតនៅក្នុងខេត្តបាតាអាន។នាពេលនោះគឺជាឱកាសដំបូងបង្អស់ ដែលខ្ញុំបានឮនិងស្គាល់ពីប្រទេសកម្ពុជា និងប្រជាជនខ្មែរ។ ខ្ញុំបានដឹកនាំសិស្សប្រមាណ៦០នាក់ធ្វើដំណើរទស្សនកិច្ចសិក្សា នៅក្នុងតំបន់ផ្សេងៗគ្នាក្នុងខេត្តបាតាអាន ដែលក្នុងនោះខ្ញុំបានដឹកនាំសិស្សទៅទស្សនាជំរំជនភៀសខ្លួន ដែលមានទាំងប្រជាជនខ្មែរវៀតណាម និងឡាវរស់នៅទីនោះ។ អ្នកយាមទ្វារនៅជំរំជនភៀសខ្លួននោះមិនបានអនុញ្ញាតឲ្យខ្ញុំ និងសិស្សទាំងអស់ចូលទៅក្នុងជំរំឡើយ ព្រោះដើម្បីរក្សាសន្តិសុខសុវត្ថិភាព។ យើងទាំងអស់គ្នា បានត្រឹមតែឈរសម្លឹងពីចម្ងាយនៅពីមុខក្លោងទ្វារឈើមួយសំដៅទៅខាងក្នុងជំរំតែប៉ុណ្ណោះ។ សំណាងល្អខ្ញុំបានជួបបុរសជនជាតិខ្មែរម្នាក់ ដែលអាចនិយាយភាសាអង់គ្លេសបាន។បុរសម្នាក់នោះគឺជាអ្នកជួយបកប្រែ និងសម្របសម្រួលដល់ប្រជាជនខ្មែរដែលរស់នៅទីនោះ។ ខ្ញុំបានសួរទៅកាន់បុរសម្នាក់នោះថា ហេតុអ្វីបានជាគាត់ពាក់ចិញ្ចៀនដែលមានទំហំធំម្ល៉េះ? បុរសម្នាក់នោះបានតបមកខ្ញុំវិញថាវាគឺជាចិញ្ចៀនដែលគាត់យកមកពីប្រទេសកម្ពុជា សម្រាប់ត្រៀមដល់ការចំណាយផ្សេងៗនៅពេលធ្វើដំណើរតាមផ្លូវមកកាន់ប្រទេសហ្វីលីពីន ព្រោះគាត់គឺជាជនភៀសខ្លួនខុសច្បាប់ដែលគ្មានលិខិតឆ្លងដែនត្រឹមត្រូវ។ គាត់នឹងផ្តល់ឲ្យនូវរបស់មានតម្លៃឲ្យទៅនរណាម្នាក់ដែលចង់បាន និងព្រមអនុញ្ញាតឲ្យគាត់ចូលទៅរស់នៅក្នុងទឹកដីហ្វីលីពីន។

ជនភៀសខ្លួននៅក្នុងជំរំបាតាអាន ត្រូវបានហៅថាមនុស្សទូក ព្រោះអ្នកទាំងនោះភាគច្រើនធ្វើដំណើរភៀសខ្លួនមកប្រទេសហ្វីលីពីន តាមរយៈទូកនាពេលយប់។ខ្ញុំក៏បានដឹងថា ជនភៀសខ្លួនទាំងអស់ មិនត្រូវបានអនុញ្ញាតឲ្យចេញទៅខាងក្រៅតំបន់ដែលខ្លួនរស់នោះទេ។ ខ្ញុំបានឃើញប្រជាជនខ្មែរស្លៀកសារុងដើរនៅក្នុងជំរំនោះ។ មិត្តភក្តិរបស់ខ្ញុំភាគច្រើនដឹងអំពីជំរំភៀសខ្លួនម៉ូរ៉ុង និងរបបខ្មែរក្រហមដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំធ្លាប់បានអានរឿងរ៉ាវជាច្រើនដែលទាក់ទងនឹងរបបខ្មែរក្រហមតាមរយៈសារព័ត៌មាននានា។ រឿងដែលស្ថិតនៅក្នុងចិត្តខ្ញុំនោះគឺអំពើដ៏ឃោរឃៅដែលខ្មែរក្រហម ធ្វើបាបប្រជាជនខ្លួនឯងដូចជាការបញ្ជាឲ្យជីករណ្តៅកប់ខ្លួនឯង និងការធ្វើទារុណកម្មដោយចាប់ជ្រមុជក្បាលទៅក្នុងទឹក។

សព្វថ្ងៃនេះនៅក្នុងថ្នាក់រៀនរបស់ខ្ញុំ នៅពេលដែលយើងពិភាក្សាអំពីរឿងនយោបាយ យើងតែងតែនិយាយទៅដល់រឿងរ៉ាវនៃរបបខ្មែរក្រហម នៅក្នុងប្រទេសកម្ពុជា។ សិស្សនៅក្នុងថ្នាក់រៀនរបស់ខ្ញុំ តែងតែប្រៀបធៀបបញ្ហាដែលកើតឡើងនៅក្នុង ប្រទេសហ្វីលីពីនអំឡុងឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៨៦ ទៅនឹងរបបខ្មែរក្រហម។ សិស្សទាំងនោះតែងតែស្ញើចសរសើរប្រជាជនខ្មែរ ដែលហ៊ានតស៊ូប្រឆាំងដើម្បីផ្តួលរំលំរបបខ្មែរក្រហម ទោះបីជារបបនេះកាចសាហាវយ៉ាងក៏ដោយ។ នៅពេលដែលគេនឹកដល់សង្គ្រាមនៅក្នុងប្រទេសហ្វីលីពីន គេតែងតែប្រៀបធៀបថាអាក្រក់ដូចរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។

វ៉ាំនេសា វិសគាល់ គឺជនជាតិហ្វីលីពីន ដែលសព្វថ្ងៃគឺជាជំនួយការនាយកផ្នែកភាសារអង់គ្លេសនៅក្នុង សកលវិទ្យាល័យដូលម៉ានីឡា បានបង្ហាញចំណាប់អារម្មណ៍ចំពោះប្រទេសកម្ពុជាថា ៖ ខ្ញុំមិនធ្លាប់ទៅទស្សនាប្រទេសកម្ពុជានោះទេ ប៉ុន្តែខ្ញុំបានស្គាល់ និងឮពីប្រទេសកម្ពុជា តាមរយៈការសិក្សានៅក្នុងថ្នាក់រៀនផ្នែក ប្រវត្តិសាស្ត្រអំឡុងពេលដែលខ្ញុំកំពុងតែសិក្សាឆ្នាំទី៤។ ខ្ញុំបានទស្សនាកូនឯកសារមួយដែលនិយាយអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ដ៏រុងរឿងរបស់ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលក្នុងនោះមានប្រទេសកម្ពុជាដែរ។ កូនឯកសារនោះ បានបង្ហាញអំពីម្ហូបអាហារ វប្បធម៌ និងរឿងរ៉ាវជាច្រើនទៀត របស់ប្រទេសកម្ពុជា។កូនឯកសារនោះ ក៏បានបង្ហាញពីអរិយធម៌ដ៏រុងរឿងរបស់កម្ពុជាតាមរយៈ ប្រាសាទអង្គរវត្តដែលជាប្រាសាទដ៏ចំណាស់មួយនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំឃើញមានភ្ញៀវទេសចរណ៍យ៉ាងច្រើនកុះករ ធ្វើដំណើរទៅទស្សនាប្រាសាទទាំងអស់នោះ។ ខ្ញុំតែងតែគិតថាប្រទេសកម្ពុជាគឺជាប្រទេសអ្នកមាន មួយក្នុងចំណោមប្រទេសអ្នកមានជាច្រើនទៀត។ ខ្ញុំបានស្គាល់ប្រទេសកម្ពុជាអំពីភាពស្រស់ស្អាតប៉ុន្តែ ខ្ញុំមិនធ្លាប់ដឹងថា ប្រទេសកម្ពុជាធ្លាប់ជួបប្រទះនឹងសង្គ្រាមដ៏ឃោរឃៅស្រដៀងគ្នាទៅនឹង ប្រទេសហ្វីលីពីនទាល់តែសោះ។

តាមរយៈទិន្នន័យពីស្ថានទូតនៃប្រទេសកម្ពុជា ប្រចាំនៅក្នុងប្រទេសហ្វីលីពីន នៅក្នុងអំឡុងឆ្នាំ២០១៨ប្រជាជនខ្មែរបានមករស់នៅធ្វើការ និងបន្តការសិក្សានៅក្នុងប្រទេសហ្វីលីពីនមានចំនួនប្រមាណ១១០នាក់ ដែលបានចុះឈ្មោះនៅក្នុងស្ថានទូត ចំណែកប្រជាជនហ្វីលីពីនបានចូលទៅរស់នៅក្នុងប្រទេសកម្ពុជាប្រហែលជា ៧.០០០នាក់ ប៉ុន្តែបានចុះឈ្មោះនៅ ក្នុងការិយាល័យអន្តោប្រវេសន៍ប្រហែលជា៣.៦០០នាក់តែប៉ុណ្ណោះ។

ប្រជាជនភៀសខ្លួនខ្មែរ បាននាំយកវប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រ និងរឿងរ៉ាវជាច្រើនទៀតមកប្រទេសហ្វីលីពីន ដែលវប្បធម៌ អរិយធម៌ទាំងអស់នោះបានបន្តរស់នៅក្នុងប្រទេសហ្វីលីពីនរហូតដល់សព្វថ្ងៃនេះ។ នេះគឺជាចំណងមួយដែលបានបង្កើតទំនាក់ទំនងរវាងប្រជាជនខ្មែរ និងប្រជាជនហ្វីលីពីន ហើយក៏ជាឱកាសមួយដែលប្រជាជននៃប្រទេសទាំងពីរស្វែងយល់ពីគ្នាទៅវិញទៅមកដែរ។

**អ៊ុន សុដាវី**



កម្រងរូបភាពដែលបង្ហាញអំពីសកម្មភាពរបស់ជនភៀសខ្លួនឥណ្ឌូចិននៅប្រទេសហ្វីលីពីន

# សៀវភៅ «បូជាភ្លើង»និយាយអំពីអ្នករស់រានមានជីវិតពីការសម្លាប់រង្គាលនៅអឺរ៉ុប

មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងសម្ពោធសៀវភៅថ្មីមួយអំពីបទពិសោធន៍ អ្នករស់រានមានជីវិតពីការសម្លាប់រង្គាល នាអំឡុងសង្គ្រាមលោកលើកទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩នៅសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹករីត នៅក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ។ ពិធីនេះនឹងមានការអញ្ជើញចូលរួមពីលោកជំទាវទន់សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយនឹងតំណាងស្ថានទូតអាមេរិក និងស៊ុយអែតប្រចាំនៅកម្ពុជា។ ការសម្ពោធសៀវភៅនេះ គឺជាការរំឭកដល់របបខ្មែរក្រហមដែលបានដួលរលំអស់រយៈពេល៤០ឆ្នាំ និងស្របពេលជាមួយគ្នានឹងការបិទបញ្ចប់ នៃការសម្លាប់រង្គាលនៅអឺរ៉ុបកាលពី៧០ឆ្នាំមុន ហើយក៏ដំណាលគ្នាទៅនឹងអនុសញ្ញាស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានអនុម័ត និងផ្តល់សច្ចាប័ន ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨។

សៀវភៅប្រែសម្រួលជាខេមរភាសា កម្រាស់២០៦ទំព័រនេះ គឺជាសៀវភៅមុនដំបូងបង្អស់ដែលបានពន្យល់ និងបកប្រែពាក្យ «ហូឡូខស្ត៍» មកជាភាសាខ្មែរ ដែលមានន័យ



សៀវភៅបូជាភ្លើង

ថា«បូជាភ្លើង»។គួររំឭកថាស្នាដៃនេះត្រូវបានបោះពុម្ពផ្សាយជាសាធារណៈលើកដំបូងជាភាសាស៊ុយអែត កាលពីឆ្នាំ២០១៧ ដោយអ្នកនិពន្ធឈ្មោះ ហេឌី ហ្វ្រាយ។ សព្វថ្ងៃនេះ លោកស្រី ហេឌី មានវ័យ៩៥ឆ្នាំ ហើយធ្វើជាអ្នកនិពន្ធ និងចិត្តវិទូជន ដែលបានរួចរស់ជីវិតពីការសម្លាប់រង្គាលនាអំឡុងសង្គ្រាមលោកលើកទី២(ពីឆ្នាំ១៩៤១ដល់ឆ្នាំ១៩៤៥)ដែលមានមនុស្សប្រមាណ៦លាននាក់ស្លាប់បាត់បង់ជីវិត។

ពីរឆ្នាំក្រោយមក ស្នាដៃរបស់លោកស្រីត្រូវបានប្រែសម្រួលជាភាសាអង់គ្លេស មានចំណងជើងថា «សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុបដោយ អាលីស អ៊ី អ៊ុលស៊ិន ដែលជាអ្នកនិពន្ធ អ្នកប្រែសម្រួល និងនិពន្ធនាយក។

សៀវភៅដដែលនេះ ក៏ត្រូវបានប្រែសម្រួលបន្តពីភាសាអង់គ្លេសមកជាភាសាខ្មែរដោយ កញ្ញា សូវិចិត្រមេត្តា ដែលជាអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជានិស្សិតទើបបញ្ចប់ការសិក្សា ផ្នែកទំនាក់ទំនងអន្តរជាតិ។ មេត្តា បានពន្យល់ថា ៖ «សៀវភៅមួយនេះគឺជាសៀវភៅដំបូងបង្អស់ ដែលបានពន្យល់បង្ហាញអំពីទស្សនៈរបស់អ្នករួចរស់ជីវិត នៃការសម្លាប់រង្គាលទ្រង់ទ្រាយធំក្នុងរបបណាហ្ស៊ី អាល្លឺម៉ង់ ដែលស្រដៀងគ្នាទៅនឹងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែរ។ ជនរងគ្រោះរាប់លាននាក់ត្រូវបានបំពាន បង្អត់អាហារ ធ្វើទារុណកម្ម និងសម្លាប់ក្រៅប្រព័ន្ធតុលាការ»។

កញ្ញា បន្តថា អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ហេតុនេះហើយ ការបង្រៀនមនុស្សជំនាន់ក្រោយអំពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលទ្រង់ទ្រាយធំ គឺមានគោលបំណងប្រឆាំងទប់ស្កាត់នឹងការរើសអើងជាតិសាសន៍ ជម្លោះជាតិពន្ធ និងអំពើប្រល័យពូជសាសន៍នាពេលអនាគត។

ក្នុងនាមជាកូន និងជាចៅរបស់ជីដូនជីតាដែលបានឆ្លងកាត់របបខ្មែរក្រហមសូវិចិត្រមេត្តាចង់ឲ្យអ្នករួចរស់ជីវិតម្នាក់ៗកត់ត្រាទុករឿងរ៉ាវ ដែលមានភាពប្រាកដច្បាស់លាស់ដើម្បីបម្រើឲ្យការអប់រំ។ កញ្ញាឲ្យដឹងថា ៖ «ប្រវត្តិសាស្ត្របន្ទាប់ពីប៉ុន្មានឆ្នាំទៅមុខទៀត អាចនឹងត្រូវបានជនខិលខូចបំភ្លៃហើយបាត់បង់ការពិត ប៉ុន្តែជាមួយនឹងឯកសារជាក់ស្តែង ទោះបីជាលែងមានជនរងគ្រោះនៅសេសសល់ដើម្បីនិយាយប្រាប់ ក៏ប្រវត្តិសាស្ត្រនេះ មិនអាចត្រូវបាត់បង់ទៅណា ហើយអំពើឃោរឃៅក៏មិនអាចត្រូវគេបំភ្លេច។ ចំណែក


កញ្ញា សូវិចិត្រ មេត្តាអ្នកបកប្រែសៀវភៅ «បូជាភ្លើង»

ជនរងគ្រោះដែលបានបាត់បង់ជីវិតយ៉ាងអយុត្តិធម៌នោះ នឹងនៅតែមានក្នុងការចងចាំរបស់ពិភពលោកជានិច្ច»។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានជឿជាក់ថា មនុស្សជាតិគ្រប់គ្នាមិនត្រូវបំភ្លេចអំពើឧក្រិដ្ឋនោះឡើយ។ លោកនិយាយថា ៖ «យើងមានការតព្

កិច្ចក្នុងការចងចាំ។ ការចងចាំនេះមិនមែនជាកាតព្វកិច្ចដែលត្រូវបានកំណត់នៅក្នុងដែនអនុសញ្ញារដ្ឋធម្មនុញ្ញឬច្បាប់ណាមួយឡើយ។ ផ្ទុយទៅវិញ វាគឺជាកាតព្វកិច្ចមួយដែលកើតឡើងពីការប្ដេជ្ញាចិត្តរបស់មនុស្សចំពោះមនុស្សជាតិ។

ដូចជាព័ត៌មានទាំងអស់ដែរ ប្រវត្តិសាស្ត្រអាចត្រូវបានបំភ្លៃ ឬបំផ្លាញ និងលុបចោល ហើយដំណោះស្រាយតែមួយគត់ដើម្បីបង្ការបញ្ហាទាំងអស់នេះ គឺការប្ដេជ្ញាចិត្តរបស់




លោកស្រី ហេឌី ហ្វ្រាយអ្នកនិពន្ធសៀវភៅប៉ូជាភ្លើង

បុគ្គលម្នាក់ៗក្នុងការចងចាំ»។

ឆាំង យុ ក៏ជាអ្នករួចរស់ជីវិតមួយរូបពីរបបខ្មែរក្រហម។ នាអំឡុងឆ្នាំ១៩៩៥ គាត់និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មកពីសាកលវិទ្យាល័យ យ៉េល នៅសហរដ្ឋអាមេរិក បានចាប់ផ្ដើមធ្វើការប្រមូល និងរក្សាទុកឯកសារពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម។ មកទល់សព្វថ្ងៃ មជ្ឈមណ្ឌលបានរកឃើញឯកសារជាង១លាន២សែនទំព័រ ហើយប្រមាណពាក់កណ្ដាលនៃឯកសារទាំងនោះ បានបម្រើជាភ័ស្ដុតាងនៅសាលាក្ដីខ្មែរក្រហម ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បន្ថែមពីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរកឃើញរណ្ដៅសាកសព២ម៉ឺនរណ្ដៅ មន្ទីរសន្តិសុខឬគុកប្រមាណ១០០ទីតាំង និងប្រវត្តិជនរងគ្រោះ និងជនដៃដល់ចំនួន៣ម៉ឺននាក់។ លោកបានពន្យល់ទៀតថា៖ ឯកសារសក្ខីកម្មទាំងនោះ នឹងត្រូវបានប្រើប្រាស់ជាសម្ភារសិក្សាស្រាវជ្រាវនិងបង្រៀនសម្រាប់ការចងចាំមួយដែលមិនលម្អៀង។ នៅក្នុងបរិបទនេះការចងចាំ គឺមិនមែនជារឿងរ៉ាវឯកជនទៀតនោះទេ។ សាច់រឿងទាំងនោះ ក៏មិនអាចជាការចងចាំដែលមិនបង្ហាញចេញមកក្រៅនៅស្ងៀមស្ងាត់ឬមិនផ្លាស់ប្ដូរទៅរកអ្វីដែលល្អប្រសើរនោះដែរ។

អ្នកដែលបានហែលឆ្លងកាត់ប្រវត្តិសាស្ត្រទាំងឡាយត្រូវតែចែករំលែកចំណេះ ដឹងរបស់ខ្លួនទៅដល់មនុស្សជំនាន់ក្រោយ ហើយមនុស្សជំនាន់ក្រោយមានកាតព្វកិច្ចក្នុងការរៀនសូត្រ និងផ្សព្វផ្សាយចំណេះដឹងនេះជាបន្តបន្ទាប់។

ការចងចាំគឺជាការចាប់ផ្ដើម និងជាសេចក្ដីបញ្ចប់ចំពោះបេសកកម្មក្នុងការស្វែងរកយុត្តិធម៌ សន្តិភាព និងការពិត។ ចំណែកកាតព្វកិច្ចក្នុងការចងចាំគឺចាប់ផ្ដើម និងបញ្ចប់ដោយបុគ្គលម្នាក់ៗ ធ្វើការសម្រេចចិត្តអំពីសារសំខាន់របស់ប្រវត្តិសាស្ត្រមិនត្រឹមតែចំពោះខ្លួនឯងផ្ទាល់តែ ប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះមនុស្សជំនាន់ក្រោយឯទៀតដែរ»។

បន្ថែមពីការចែកសៀវភៅជាង៣ ពាន់ក្បាលមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បង្កើតឲ្យមានមាតិកាជាសាធារណៈជាទម្រង់សៀវភៅអេឡិចត្រូនិចជាសំឡេងនិងតាមបណ្ដាញផ្សព្វផ្សាយសង្គម។ ការប្រែសម្រួលនេះ ទទួលបានការគាំទ្រថវិកាពីទីភ្នាក់ងារ សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត និងការគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិប្រចាំនៅកម្ពុជា។ **សន ប៊ុនស៊ីម**

# រឿងរ៉ាវរបស់ប្រជាជនចេញពីស្រុកវាលវែង ខេត្តពោធិ៍សាត់

***១) មិល សឺង ៖ អាយុជាង៥០ឆ្នាំនៃជីវិតខ្ញុំ បានបូជាចំពោះការងារកងទ័ព***

មិល សឺង គឺជាជនជាតិជង់ខ្ទង់ភ្នំដែលមានអាយុ៦១ឆ្នាំ និងមានស្រុកកំណើតនៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។ មិល សឺង ធ្លាប់បានឆ្លងកាត់សង្គ្រាមជាច្រើននៅតំបន់ជួរភ្នំ។ បទពិសោធន៍ទាំងនេះ ធ្វើឲ្យគាត់ស្គាល់ភូមិសាស្ត្រតំបន់ជួរភ្នំក្រវ៉ាញ និងអាចសម្របខ្លួនរស់នៅក្នុងព្រៃភ្នំដើម្បីគេចខ្លួនពីការវាយប្រហារនានា។ សឺង បានរៀបរាប់ពីការសិក្សានៅកុមារភាព ការសម្រេចចិត្តចូលរួមជាមួយចលនាខ្មែរក្រហម ការរត់ចេញពីកងទ័ពខ្មែរក្រហមការសម្រេចចិត្តធ្វើជាកងទ័ពខ្មែរក្រហមជាថ្មី និងជីវភាពរស់នៅនៅតាមជំរំខ្មែរក្រហមនៅទឹកដីថៃ រហូតដល់ការសម្រេចចិត្តចូលរួមជាមួយ កងទ័ពរដ្ឋាភិបាលនៅស្រុកវាលវែងនាឆ្នាំ១៩៩៨។

គាត់បានរៀបរាប់ថា៖«នៅជំនាន់ខ្មែរឥស្សរៈភូមិនេះ (អូរសោម) គឺសុទ្ធតែព្រៃទាំងអស់។ កាលនោះ ឪពុក ម្ដាយខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ចំណែកខ្ញុំរៀនបានត្រឹមថ្នាក់ទី១១។ សម័យនោះការរាប់ថ្នាក់គឺបញ្ច្រាស់ពីសម័យឥឡូវ។ សិស្សចាប់ផ្ដើមរៀនពីថ្នាក់ទី១២ បន្ទាប់មកថ្នាក់ទី១១ហើយថ្នាក់ទី១ គឺជាថ្នាក់ចុងក្រោយ»។ នៅពេលដែលខ្ញុំរៀនបឋម



ទេសភាពតាមដងផ្លូវនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់

សិក្សាគឺជាពេលដែលប្រទេសកម្ពុជា ចាប់ផ្តើមមានរដ្ឋប្រហារឆ្នាំ១៩៧០។ យុវជនខ្លះត្រូវរដ្ឋាភិបាលចាប់ឲ្យចូលធ្វើទាហាន លន់ នល់ និងខ្លះទៀតចូលធ្វើជាកងទ័ពខ្មែរក្រហម។ ខ្ញុំចាប់ផ្តើមស្គាល់ខ្មែរក្រហម ហើយចូលរួមតស៊ូជាមួយខ្មែរក្រហមប្រយុទ្ធតទល់នឹងទាហាន លន់ នល់។ កាលនោះការងារទាហានក៏ខ្ញុំធ្វើ ហើយការងារលើកភ្លឺស្រែចម្ការក៏ធ្វើ។ ខ្ញុំធ្វើកងទ័ពនៅតំបន់ភ្នំសំកុសនៅអំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ដែលមានស្ថានភាពខ្លះមុខនិងខ្លះក្រោយ។ កងទ័ពពេលនោះមិនមែនអង្រឹងដេកទេ ដូច្នេះខ្ញុំត្រូវដេកផ្ទាល់នឹងដី។ ចំណែកអាវុធវិញគឺខ្ញុំប្រើកាំភ្លើងពីបុរាណនិងកាំភ្លើងយន្ត។ ក្នុងចំណោមកងទ័ព១០នាក់ ខ្មែរក្រហមចែកកាំភ្លើងយន្ត៥ដើមឲ្យប្រើ ក្រៅពីនេះយើងត្រូវប្រើកាំភ្លើងបុរាណ។ កាំភ្លើងបុរាណ គឺយើងដាក់រំសេវនិងដែកគោលដើម្បីបាញ់។ សម័យនោះ មិនមានអ្នកណាបង្រៀនខ្ញុំទេ ខ្ញុំរៀនបាញ់កាំភ្លើងខ្លួនឯង។

បន្ទាប់មក នៅខែមេសា ឆ្នាំ១៩៧៥ ចលនាខ្មែរក្រហមបានយកឈ្នះលើរបបសាធារណរដ្ឋខ្មែរដឹកនាំដោយ លន់ នល់ និងបានគ្រប់គ្រងប្រទេសកម្ពុជា។ ខ្ញុំបានបន្តធ្វើជាកងទ័ពខ្មែរក្រហមរហូតមក ដោយប្រចាំការនៅតំបន់ភ្នំសំកុសស្ថិតនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។ រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបញ្ជូនខ្ញុំទៅឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់វិញ។ ខ្ញុំបានចូលបម្រើជាកងទ័ពស្រុកដោយឈរជើងនៅខាងត្បូងស្រុកភ្នំក្រវាញ ដោយមានតួនាទីជាមេក្រុម និងមានកូនចៅ១០នាក់នៅក្រោមបញ្ជា។ ពេលនោះ លែងមានការច្បាំងគ្នាទៀតហើយដូច្នេះខ្ញុំដើរការពារតាមព្រៃភ្នំ។ ខ្មែរក្រហមបានចែកបបរឲ្យហូប ប៉ុន្តែពេលណាដើរ ព្រៃខ្ញុំបានបាយហូប។កងទ័ពភាគច្រើនមិនបានដឹងពីការកាប់សម្លាប់នៅក្នុងភូមិ និងសហករណ៍ទេព្រោះតួនាទីអង្គភាពរបស់ខ្ញុំគឺយាមកាម និងដើរល្បាតតាមព្រៃភ្នំ។ខ្ញុំត្រូវដើរត្រួតពិនិត្យរយៈពេលមួយម៉ោងនៅជុំវិញភ្នំ ចាប់ពីម៉ោង៧ដល់ម៉ោង៨ព្រឹករាល់ថ្ងៃ។ បន្ទាប់មក ខ្ញុំមកប្រចាំការនៅកន្លែងវិញ ហើយយើងដើរល្បាតម្តងទៀតចាប់ពីម៉ោង៥ល្ងាចដល់ម៉ោងយប់ទើបមកសម្រាក។ ខ្មែរក្រហមពង្រាយទ័ពតាមទីតាំងផ្សេងៗនៅលើភ្នំ ដោយមានកងទ័ពចាប់ពី១០ទៅ២០នាក់ដើម្បីត្រៀម និងការពារមុខសញ្ញាឈរជើង។ នៅក្នុងវរសេនាធំមានកងទ័ព២០០នាក់។ ខ្ញុំដឹងថាមានការសម្លាប់ប្រជាជន ព្រោះតំបន់ដែលខ្ញុំយាមស្ថិតនៅក្បែរភូមិដែរ ប៉ុន្តែតើឲ្យខ្ញុំធ្វើដូចម្តេច និងជួយម្តេចបាន។ យើងបានត្រឹមតែនៅស្ងៀម និងនាំគ្នាលាក់ការណ៍ប្រសិនបើគេវាប្តូរនាំច្រើនច្បាស់ជាខ្មែរក្រហមយកទៅសម្លាប់មិនខាន។

ពេលខ្លះខ្ញុំដើរកាត់តាមផ្លូវក៏ប្រទះឃើញ កងឈ្លបតូចៗចងដៃ និងបណ្តើរមនុស្សជាជួរៗយកទៅជាមួយ។ ឃើញស្ថានភាពបែបហ្នឹងខ្ញុំក៏ខឹងដែរ ខ្ញុំអាណិតម៉ែគេ ម៉ែឯងប៉ុន្តែធ្វើម៉េច បើយើងមិនអាចរើបម្រះបាន។ពេលខ្លះខ្ញុំដើរល្បាតតាមព្រៃ ខ្ញុំឃើញខ្មោចតាមផ្លូវ មានក្លិនស្អុយនិងមានសត្វឆ្កែហែកស៊ីសាកសព។ សពខ្លះទៀតមានរយៈពេលពី


មិល សឺត គឺជាជនជាតិជនខ្មែរភ្នំ

៣ទៅ៤ថ្ងៃ នៅពាសពេញវាល និងព្រៃៗ ពេលដើរជួបបែបហ្នឹង ខ្ញុំក៏ដើរគេចព្រោះមិនដឹងទៅរាយការណ៍ប្រាប់ទៅនរណាៗ

ទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំធ្លាប់បានជួយសង្គ្រោះប្រជាជនមួយចំនួនដែលខ្ញុំបានជួបដោយចៃដន្យ នៅអំឡុងពេលប្រជាជនទាំងនោះកំពុងលួចដុតដំឡូងក្នុងព្រៃហូបៗ ខ្ញុំមិនបានចាប់ទោសពៃរ៍ប្រជាជនទាំងនោះឡើយៗ ខ្ញុំថែមទាំងបានប្រាប់ឲ្យប្រជាជនទាំងនោះឲ្យលាក់ការណ៍ឲ្យជិត ហូបឲ្យលឿន និងរត់ទៅធ្វើការវិញ ដើម្បីកុំឲ្យកងឈ្លបតាមមកទាន់ និងចោទថាខ្ជិលក្បត់អង្គការៗ ក្រៅពីនេះខ្ញុំនិងកងទ័ពបានដើរបាញ់សត្វ ហើយជូនកាលយើងចែកសត្វដែលបាញ់បានទៅសហករណ៍ខ្លះ និងទុកហូបខ្លួនឯងខ្លះៗ ខ្ញុំជឿថាខ្ញុំអាចរស់បានយូរព្រោះខ្ញុំមិនដែលប៉ះពាល់អ្នកដទៃ និងមានព្រះពុទ្ធព្រះធម៌តាមថែរក្សាៗ ខ្ញុំមិនដែលបានទទួលបញ្ជាឲ្យទៅចាប់មនុស្សឡើយៗ

បន្ទាប់ពីរបបខ្មែរក្រហមបរាជ័យនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានរត់គេចពីទ័ពតំបន់ និងទ័ពមជ្ឈិមដែលប្រចាំការនៅឃុំលាចខាងត្បូង ស្រុកភ្នំក្រវាញ នៅខែកក្កដា ឆ្នាំដដែល ខណៈដែលខ្មែរក្រហមបម្រុងនឹងបញ្ជូនខ្ញុំទៅសំឡូត នៅខេត្តបាត់ដំបងៗ កងទ័ពនៅអង្គភាពរបស់ខ្ញុំមានបុរសប្រហែល៩០នាក់ និងស្ត្រី៥០នាក់ដោយស្លៀកពាក់ខោអាវខ្មៅៗ ខ្ញុំបានរៀបគម្រោងការរយៈពេលប្រមាណ៦ខែមុន ដើម្បីរត់ចេញពីយោធាទ័ពខ្មែរក្រហមៗ ក្រោយមកទើបខ្ញុំហ៊ានសួរសមាជិកទ័ពដែលខ្ញុំទុកចិត្តបំផុតៗ

ខ្ញុំប្រាប់ទៅកូនចៅក្រោមបង្គាប់ខ្ញុំថា៖«យើងរស់នៅពេលនេះ លំបាកណាស់ៗ ឥឡូវចេញទៅជាមួយអញឬទេ?» សមាជិកកងរបស់ខ្ញុំបានសួរខ្ញុំវិញថា ៖ «ទៅណាបង ឬ ទៅណាមេ?»ៗ ខ្ញុំតបថា ៖ «ទៅស្រុកអញ នៅអូរសោម»ៗ សមាជិកកងរបស់ខ្ញុំបានតបថា ៖ «ទៅតាមបងក៏បាន សុខចិត្តស្លាប់ជាមួយបង យើងច្បាំងទៀតក៏ប្រហែលស្លាប់ដដែល»ៗ បន្ទាប់មក ខ្ញុំក៏ប្រាប់សមាជិកកងទាំងអស់ថា ៖ «ស្រុកអញមានតែដំឡូង និងក្លួចទេមិនមានអ្វីហូបលើសពីនេះទេ»ៗ សមាជិកទាំងអស់ក៏យល់ព្រម ហើយខ្ញុំក៏នាំគ្នាលួចរត់ពីបន្ទាយយោធាខ្មែរក្រហមនៅ ឃុំលាច ស្រុកភ្នំក្រវាញៗ

ពេលនោះ ខ្ញុំបានណាត់សមាជិកនៅក្នុងអង្គភាពតាំងពីពេលថ្ងៃថាវេលាម៉ោង២រំលងអាធ្រាត យើងនឹងចាកចេញពីបន្ទាយភ្លាមៗ យើងរៀបចំអង្ករ ឆ្នាំង អង្រឹង និងកាំ ភ្លើងរួចជាស្រេចៗ នៅពេលដល់វេលាកំណត់ ខ្ញុំដើរដាស់សមាជិកនៅក្នុងអង្គភាពរបស់ខ្ញុំចេញដំណើរៗ ខ្ញុំមិនខ្លាចមីនទេព្រោះខ្ញុំស្គាល់ភូមិសាស្ត្រព្រៃភ្នំនៅតំបន់ ដែលខ្ញុំប្រចាំការៗ ប្រាំពីរថ្ងៃក្រោយមក ខ្ញុំដើរដល់ស្រុកកំណើតរបស់ខ្ញុំនៅឃុំអូរសោម ប៉ុន្តែខ្ញុំមិនហ៊ានដើរតាមផ្លូវទេ គឺដើរកាត់ព្រៃព្រោះខ្លាចជួបកងទ័ពវៀតណាមនិងទាហានថៃៗពេលដែលយើងដើរហត់ និងអស់ស្បៀងយើងបានឈប់ដើម្បីជីកក្លួចទុកហូបៗ

ពេលខ្ញុំត្រឡប់មកភូមិកំណើត ផ្ទះរបស់ខ្ញុំមិនមានមនុស្សរស់នៅឡើយ ព្រោះខ្មែរក្រហមបានជម្លៀសមនុស្សចេញពីផ្ទះអស់ហើយៗ យើងមិនបានចូលមកនៅផ្ទះភ្លាមទេព្រោះមានទាហានបាញ់គ្នានៅក្នុងភូមិនៅឡើយៗ យើងបានសម្រេចចិត្តរស់នៅក្នុងព្រៃរយៈពេល៦ខែទៀតៗ យើងហូបក្លួចនិងដំឡូងដើម្បីរស់ៗពេលខ្លះយើងក៏មានសំណាងបានត្រីសាច់ សត្វព្រៃ ឈ្លូស និងប្រើសមកហូបដែរៗ

រហូតដល់ឆ្នាំ១៩៨០ ខ្ញុំជាមួយសមាជិកកង១០នាក់ទៀត បានចូលរួមជាមួយទ័ពខ្មែរក្រហមសាជាថ្មីនៅថ្មដា ស្រុកវាលវែង ដើម្បីវាយតទល់ជាមួយកងទ័ពវៀតណាមៗ យើងមាន ស្បៀងអាហារមកពីប្រទេសចិនដែលដឹកកាត់តាមប្រទេសថៃៗ យើងមានអាហារហូបគ្រប់គ្រាន់ដូច្នេះយើងលែងហូបបបរទៀតហើយៗ ការសម្រេចចិត្តចូលរួមជាមួយខ្មែរក្រហមលើកនេះ ដោយសារខ្ញុំបានជួបយោធាខ្មែរក្រហមម្នាក់ដែលដឹកជញ្ជូនគ្រាប់កាំភ្លើងនៅតាមផ្លូវៗ

យោធាខ្មែរក្រហមនោះបានប្រាប់ខ្ញុំថា នៅថ្មដាមានមេដឹកនាំមានសម្លៀកបំពាក់ខោអាវ និងម្ហូបគ្រប់គ្រាន់ដើម្បី

រស់។ក្រោយមកយើងក៏សម្រេចចិត្តចូលខ្មែរក្រហមម្តងទៀត ដោយខ្ញុំនិងសមាជិកទាំង១០នាក់ដើរចេញពី អូរសោមរយៈពេលមួយអាទិត្យទើបទៅដល់ថ្មដា។ ពេលទៅដល់ថ្មដាមេបញ្ជាការនៅទីនោះបានបំបែក សមាជិកកងទាំង១០នាក់ នៅក្នុងអង្គភាពរបស់ខ្ញុំទៅរស់នៅតាមជំរំផ្សេងៗខ្ញុំមិនដឹងថាអ្នកទាំងនោះទៅនៅជំរំណាច្បាស់ឡើយ។

ចំណែកខ្ញុំនៅជាមួយ តាសេង គឺប្រធានកងពល។ ការរស់នៅលែងដូចពីមុនទៀតហើយ។ ខោអាវបានផ្លាស់ប្តូរពីខ្មៅទៅបៃតងចាស់មានកាំភ្លើងក្រវាត់ចង្កេះ និងមានមួកកន្ទឹប។ ខ្មែរក្រហមបានចែកអាវ ខោ និងកាំភ្លើងឲ្យខ្ញុំ។ មេរបស់តាសេង គឺតាម៉ុក។ ខ្ញុំឮតែឈ្មោះ តាម៉ុក ប៉ុន្តែមិនដែលជួបមុខ តាម៉ុក ឡើយ។

ខ្ញុំបានចំណាយពេល១៣ឆ្នាំ ចូលរួមជាមួយខ្មែរក្រហម រហូតដល់ឆ្នាំ១៩៩៣ ដោយរស់នៅលើភ្នំនៅថ្មដា។ ខ្ញុំបានរៀបការជាមួយភរិយា និងមានកូននៅទីនោះ។ការងារប្រចាំថ្ងៃរបស់ខ្ញុំនៅពេលនោះ គឺបិតចម្រូងសម្រាប់ការពារទីតាំងបន្ទាយនៅថ្មដា។ ខ្មែរក្រហមមិនបានបញ្ជាឲ្យខ្ញុំទៅបាញ់និងប្រយុទ្ធនៅលើសមរភូមិទេ។ ខ្ញុំត្រូវយកដើមឫស្សីមកកាត់ជាកង់ៗឲ្យបានប្រវែងប្រហែលស្មើនឹងដើមដៃ រួចបិតចុងនិងគល់ឲ្យស្រួចដោតក្នុងអន្លង់ជម្រៅត្រឹមជង្គង់ និងមានផ្ទៃ ក្រឡាមួយម៉ែត្របួនជ្រុង។ ខ្ញុំត្រូវដោតពីមុខថយក្រោយព្រោះបើកាលណាខ្ញុំធ្វេសប្រហែស និងធ្លាក់ចូលក្នុងអន្លង់ច្បាស់ជាខ្ញុំត្រូវស្លាប់ដោយសារមុតចម្រូងមិនខាន។

អន្លង់មួយជួរៗមានចម្ងាយ២ ០ ម៉ែត្រ។ខ្ញុំធ្វើការងារនេះរាល់ថ្ងៃ រយៈពេល១៣ឆ្នាំ។ ខ្ញុំមិនដែលដូរបន្ទាយឡើយ។ នៅពេលនោះ ទាំងចាស់ទាំងក្មេងត្រូវធ្វើការដូចគ្នា។ក្នុងមួយថ្ងៃខ្ញុំត្រូវពុះ និងបិតឫស្សីឲ្យបាន១០០ទៅ២០០ដើម។ក្រោយពីបិទចម្រូងឫស្សីរួច ខ្មែរក្រហមក៏បើកឡានមកដឹកចេញទៅ។ ខ្ញុំមិនអាចទាក់ទងសួរដំណឹងពីគ្រួសាររបស់ខ្ញុំបានឡើយ។ មានពេលមួយ កងទ័ពវៀតណាមបានវាយដល់ជំរំ និងផ្លោងគ្រាប់ដល់ដីថៃ។ខ្ញុំចាំថាខ្ញុំបានរត់ទៅពួននៅត្រង់សេ និងមិនមានបាយ និងទឹកដឹកអស់រយៈពេលជាច្រើនថ្ងៃ។

រហូតដល់អាជ្ញាធរបណ្តោះអាសន្ន ហៅកាត់ថា អ៊ុនតាក់ចូលមកប្រទេសកម្ពុជានៅអំឡុងឆ្នាំ១៩៩២ និងឆ្នាំ១៩៩៣ ទើបខ្ញុំបានទទួលដឹងដំណឹងពីគ្រួសាររបស់ខ្ញុំ។ នៅជំរំសុខសាន្ត(គ្រប់គ្រងដោយសឺន សាន) និងជំរំសាយខេ (គ្រប់គ្រងដោយខ្មែរក្រហម មានជនភៀសខ្លួនខ្មែររាប់រយនាក់ស្នាក់នៅ។ ពីជំរំមួយទៅមួយទៀតមានចម្ងាយ១គីឡូម៉ែត្រឃ្លាតពីគ្នា។ ជនភៀសខ្លួនខ្មែរជួបគ្នារាល់ថ្ងៃ។ ជំរំទាំងនេះស្ថិតនៅក្នុងទឹកដីថៃជាប់ជាមួយស្រុកវាលវែងខេត្តពោធិ៍សាត់។ នៅជំរំសាយខេមានលក់ដូរអីវ៉ាន់ និងបន្លែផ្សេងៗ។ យើងសង់ផ្ទះដោយមានសសរ និងជញ្ជាំងធ្វើពីឫស្សី។ ផ្ទះនោះមានកម្ពស់ចាប់ពី១ទៅ២ម៉ែត្រទៅតាមប្រវែង និងទំហំដើមឫស្សី។ ខ្ញុំត្រូវសង់ផ្ទះដោយខ្លួនឯង។ ប្រធានជំរំវាស់ដីឲ្យយើងសង់ផ្ទះ ដែលមានទំហំទៅតាមចំនួនសមាជិកគ្រួសាររបស់យើង។ បើខ្ញុំចាំមិនភ្លេច កាលនោះ ប្រធានជំរំចែកដីទំហំ២០ម៉ែត្រ៤ជ្រុងដែលមានផ្លូវដើរនៅ កណ្តាលឲ្យខ្ញុំសង់ផ្ទះ។ ក្រៅពីឫស្សី ក៏មានអ្នកខ្លះកាប់ឈើមកធ្វើផ្ទះដែរ។ ចំណែកម្ហូបអាហារវិញ មានជនជាតិបរទេសបើកអង្ករឲ្យខ្ញុំដាំហូប។ នៅជំរំពេលនោះមានផ្ទះរាប់រយខ្នង តម្រៀបគ្នាជាជួរប្រវែងរាប់គីឡូម៉ែត្រ។ មួយសង្កាត់មានផ្ទះ២០ទៅ១០០ខ្នងដោយមានផ្លូវលំខ្វែងខ្វាត់ក្នុងជំរំ។

នៅអំឡុងឆ្នាំ១៩៩៣ ខ្ញុំចាកចេញពីជំរំក្នុងទឹកដីថៃ មកប្រទេសកម្ពុជាវិញ។ កាលរស់នៅជំរំក្នុងទឹកដីថៃ ខ្ញុំមិនបានដឹងថាខាងខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាឡើយ។ ពេលនោះជនជាតិបរទេសបានដឹកជនភៀសខ្លួនខ្មែរ ដែលរស់នៅជំរំមកកាន់ភូមិកំណើតរៀងខ្លួនៗនៅក្នុងប្រទេសកម្ពុជា។ មានឡានទាហាន និងឡានដំរីមកដឹកជនភៀសខ្លួនខ្មែរ ដែលឈររង់ចាំនៅពាសពេញផ្លូវ។

ឡានបានដឹកជនភៀសខ្លួនខ្មែរពីជំរំ សាយ ខេ មកភូមិប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំបន្តដំណើរពី

ភូមិប្រម៉ោយ ទៅឃុំអូរសោម ស្រុកកំណើតរបស់ខ្ញុំវិញ ជាមួយប្រជាជនប្រមាណ៣០គ្រួសារទៀត ដែលសុទ្ធតែជាមនុស្សធ្លាប់ស្គាល់គ្នា។ អ្នកដំណើរទាំងអស់ដើរបានកន្លះគីឡូក៏ឈប់សម្រាក ហើយពេលខ្លះក៏ដេកនៅតាមផ្លូវ ព្រោះមានកូនតូចៗមកជាមួយមិនអាចធ្វើដំណើរឆ្ងាយបាន។

ពេលយើងមកដល់កន្លែងមានទឹក និងត្រី ក៏ឈប់សម្រាក់១ទៅ២ថ្ងៃដើម្បីរកស្បៀងអាហារបន្ថែម រួចហើយទើបបន្តទៅមុខទៀត។ ពេលនោះយើងមាន៣០គ្រួសារដែលក្នុងមួយគ្រួសារមានសមាជិក៣ទៅ៥នាក់។ ខ្ញុំផ្ទាល់មានកូន៥នាក់។ ប្រពន្ធខ្ញុំពកូនតូចៗ ចំណែកកូនធំដើរ ដោយខ្លួនឯង។ កូនរបស់ខ្ញុំបានហូបនំ និងប្រឡែងគ្នាលេងនៅពេលធ្វើដំណើរតាមផ្លូវ។ យើងមានកាំភ្លើងកាន់គ្រប់ដៃ។ ស្ថានភាពផ្លូវពេលនោះអាចដើរ និងបរដំរីបាន ប៉ុន្តែមិនអាចជិះឡានបានឡើយ។ ក្រោយពីធ្វើដំណើររយៈពេលមួយអាទិត្យទើបយើងបានមកដល់ភូមិអូរសោមនេះនៅពេលល្ងាចៗ កាលនោះយើងឃើញតែព្រៃ និងផ្ទៃដីដាំស្រូវនិងដំឡូងរួចហើយ។ យើងមិនដឹងថាអ្នកណាជាអ្នកដាំដំឡូងទាំងនោះទេ។ យើងបាននាំកាប់ឆ្ការព្រៃ និងចែកក្បាលដីម្នាក់១០០ម៉ែត្រក្នុងមួយគ្រួសារ។ យើងសាងសង់ផ្ទះធ្វើពីឈើដែលមាន បណ្តោយចាប់ពី៤ ទៅ៦ម៉ែត្រ តាមចំនួនសមាជិកគ្រួសារតូចឬធំ។ ក្នុងរយៈពេលមួយអាទិត្យ យើងជួយគ្នាសង់ផ្ទះបាន មួយខ្នងដោយប្រើតែពូថៅ និងកាំបិតប៉ុណ្ណោះ។ យើងមិនមានស័ង្កសីនោះទេ ដូច្នេះយើងយកស្លឹកសមមកប្រក់ផ្ទះ។


លក់ ប្រាង គឺជាជនជាតិជនរស់នៅខេត្តពោធិ៍សាត់

ពេលមករស់នៅភូមិនេះដំបូងមិនមានប្រជាជនរកស៊ីទេ។ ប្រជាជនចាប់ផ្តើមដាំដំឡូង និងស្រូវ។ ប្រជាជនខ្លះចាប់ផ្តើមរកឈើខ្លឹម ដើម្បីលក់ឲ្យឈ្មួញថៃ។តំបន់អូរសោមមិនសូវមានមីនបង្កប់ទេ ដូច្នេះពលប្រជាជនអាចធ្វើដំណើរចេញចូលបាន។ នៅឆ្នាំ១៩៩៤ ខ្ញុំចាប់ផ្តើមទាក់ទងជាមួយរាជរដ្ឋាភិបាល ហើយក៏បានសម្រេចចិត្តចូលធ្វើទាហានខាងរាជរដ្ឋាភិបាលវិញ។ នៅឆ្នាំ១៩៩៨ ខាងរាជរដ្ឋាភិបាលបានជិះយន្តហោះមករៀបចំតំបន់វាលវែងឲ្យមានរបៀបរៀបរយ និងមានការបំពាក់ស័ក្តិដល់អតីតយោធាខ្មែរក្រហមទៀតផង។ ខ្ញុំបានទទួលការតែងតាំងដោយមានមេកងពល និងលោក កែ គឹមយ៉ាន ជាអធិបតី មកបំពាក់ស័ក្តិជូន និងមានថតរូប ទៀត ផង ។ ខ្ញុំគឺជានាយសេនាធិការវរសេនាតូចប្រចាំនៅឃុំអូរសោម ហើយក្រោយមករាជរដ្ឋាភិបាលបញ្ចូលទៅក្នុងកងទ័ពជើងគោកវិញ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏ចូលបម្រើយោធាខាងរាជរដ្ឋាភិបាលរហូតដល់ចូលនិវត្តនៅឆ្នាំ២០១៦។

## ២) លក់ ប្រាង ៖ ការរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ លក់ ប្រាង អាយុ៦១ឆ្នាំ គឺជាជនជាតិជនរស់នៅខេត្តពោធិ៍សាត់។ នៅដើមឆ្នាំ១៩៧៥ ខ្មែរក្រហមប្រមូលអ្នកប្រជាជនក្នុងភូមិឲ្យមកនៅឃុំអូរសោម ស្រុកវាលវែងខេត្តពោធិ៍សាត់។ខ្ញុំរស់នៅភូមិបានមួយឆ្នាំបន្ទាប់មកខ្មែរក្រហមក៏ចាត់តាំងខ្ញុំឲ្យទៅនៅឃុំលាចវិញ។ ខ្មែរក្រហមឲ្យខ្ញុំនិង

ប្រជាជននៅក្នុងភូមិដើរខ្វះបររទេះក្របីខ្លះស្ពាយរែក និង ដឹកជញ្ជូនអីវ៉ាន់ទៅជាមួយៗ ពេលធ្វើដំណើរនៅតាមផ្លូវខ្មែរក្រហមមិនបានសម្លាប់មនុស្សទេៗ

ពេលទៅដល់ឃុំលាច ខ្មែរក្រហមចាប់ផ្តើមបែងចែកការងារឲ្យប្រជាជនធ្វើៗ ខ្ញុំមានកូនតូច ដូច្នេះពេលព្រឹក ខ្មែរក្រហមប្រើខ្ញុំលាយជីៗ ខ្ញុំត្រូវទៅកាប់ដើមទន្រ្ទានខៃត្រួច ហើយទូលមកកងវិញ ដើម្បីចិញ្ច្រាំលាយជាមួយអាចម៍ក្របី និងដីដំបូកធ្វើជីដាក់ស្រែៗ នេះគឺជាការងារប្រចាំថ្ងៃរបស់ខ្ញុំៗ ខ្ញុំធ្វើការតាំងពីព្រឹករហូតដល់ម៉ោង១១៖៣០នាទីទើបប្រធានកងអនុញ្ញាតឲ្យឈប់សម្រាកៗ បន្ទាប់មក ខ្ញុំធ្វើការបន្តទៀតចាប់ពីម៉ោងរសៀលដល់ម៉ោងល្ងាចៗពេលនោះមិនមាននាឡិកាមើលម៉ោងទេ គឺខ្ញុំចាំស្តាប់តែស្នូរជួងប៉ុណ្ណោះៗ ជួនកាលប្រធានកងប្រើខ្ញុំឲ្យទៅលើកភ្លឺស្រែ និងស្ទូងស្រូវទាំងយប់ក៏មានដែរៗ ថ្ងៃណាក៏ខ្ញុំខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោលដែរៗ ខ្ញុំមិននឹកស្មានថាខ្ញុំអាចនៅមានជីវិតដល់សព្វថ្ងៃនេះទេៗ

ខ្ញុំមិនដែលឃើញខ្មែរក្រហម វាយសម្លាប់មនុស្សផ្ទាល់ភ្នែកនោះទេ ប៉ុន្តែខ្ញុំធ្លាប់បានឃើញសាកសពស្លាប់តាមផ្លូវ និងនៅក្នុងព្រៃ ដោយដៃនៅជាប់ចំណងនៅឡើយៗ ខ្ញុំចាំថា នៅល្ងាចមួយពេលធ្វើការនៅដំណាក់ឈើក្រំ ខ្ញុំឃើញខ្មែរក្រហមនាំអ្នកដឹកទំនប់មក ប៉ុន្តែមិនដឹងថាខ្មែរក្រហមនាំអ្នកទាំងនោះទៅណាទៀតទេៗ ខ្មែរក្រហមចងមនុស្សដោយប្រើខ្សែអង្រឹង និងបណ្តើរដោយក្នុងមួយជួរមានមនុស្ស៥នាក់ៗ ចំណែកអ្នកបណ្តើរមនុស្សយកទៅគឺជាខ្មែរក្រហមក្មេងៗ ដែលមានអាយុចាប់ពី១០ទៅ១២ឆ្នាំៗ ជួនកាលខ្មែរក្រហមប ណ្តើរមនុស្សចេញទៅស្ទើរពេញមួយ យប់ គឺចាប់តាំងពីព្រលប់រហូតជិតភ្លឺក៏មានដែរៗ ខ្ញុំឮថាមានការសម្លាប់មនុស្សនៅភូមិវាលវង់ នៅខាងត្បូងឃុំលាច ក្នុងស្រុកភ្នំក្រវាញៗ សព្វថ្ងៃប្រជាជនដែលរស់នៅភូមិវាលវង់ មួយចំនួនក៏មិនដឹងថាមាន រណ្តៅសាកសពនៅក្នុងភូមិរបស់ខ្លួនដែរៗ ខ្ញុំធ្វើការ លើកទំនប់បានរយៈពេលប្រហែលពីរខែកន្លះ

វៀតណាមក៏បានវាយចូលមកដល់ ចំពេលដែលខ្មែរ ក្រហមបានដកខ្ញុំឲ្យទៅដកដំឡូងមីនៅឃុំលាចៗ ខ្ញុំក៏មានសំណាងបានជួបគ្រួសារខ្ញុំវិញៗ

ខ្ញុំនៅចាំបានថា នៅពេលបង្កើតសហករណ៍ដំបូងចុងភៅចែករបបបបរ១ វែកក្នុងមួយពេលសម្រាប់មនុស្សម្នាក់ៗ ក្រោយមក ចុងភៅចែកអង្ករឲ្យមួយកំប៉ុងសម្រាប់ហូបគ្នា៧នាក់វិញ ហើយខ្ញុំក៏មិនបានដឹងពីហេតុផលនោះដែរៗ ជួន កាល ចុងភៅបបរមួយខ្ទះគ្មោត សម្រាប់មនុស្សមួយភូមិៗ ខ្ញុំមិនហ៊ានសួរហេតុអ្វីចុងភៅផ្តល់អាហារតិចនោះទេៗប្រសិនបើខ្ញុំហ៊ានសួរច្បាស់ ជាត្រូវអង្គការចោទថាខ្មាំងមិនខានៗ ប្រធានចុងភៅសួរយើងថា៖«តើហូបប៉ុណ្ណឹងឆ្អែតឬទេ?» ប្រសិនបើយើងហ៊ានឆ្លើយថាហូបមិនឆ្អែត នោះខ្មែរក្រហមនឹងយកទៅសម្លាប់មិនខានៗ ប៉ុន្តែប្រសិនបើប្រជាជនហ៊ានឆ្លើយថាឆ្អែត ពេលខ្លះចុងភៅថាយើងហ្នឹងឆ្លើយខឹងផងដាក់ឲ្យអង្គការ ហើយរាយការណ៍ទៅឈ្លបយកអ្នកឆ្លើយទៅសម្លាប់ក៏មានដែរៗ

ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងហូបលួចលាក់ លួចដាំបាយហូប និងមិនឲ្យមានសិទ្ធិនៅតាមផ្ទះរៀងខ្លួនឡើយៗ ប្រសិនបើមានអាហារហូប ត្រូវដាក់នៅរោងបាយរួមៗ អង្គការអនុញ្ញាតឲ្យដាំដំណាំ ប៉ុន្តែប្រសិនបើបានផល អង្គការហាមមិនឲ្យប្រជាជនប្រមូលផល ដោយខ្លួនឯងឡើយៗ ប្រសិនបើអង្គការដឹងថានរណាម្នាក់លួចដំណាំហូប អង្គការនឹងចោទអ្នកនោះថាជាខ្មាំងឬផ្សំគំនិតជាមួយខ្មាំង ដែលអាចមានទោសយកទៅសម្លាប់ចោលៗ ខ្មែរក្រហមប្រាប់យើងឲ្យឡើងប្តេជ្ញា ទោះបីហូបបាយមួយវែកក៏ត្រូវតស៊ូបង្កបង្កើនផលដែរៗ ពេលប្រជុំ អ្នកចូលរួមត្រូវស្រែកថា «តស៊ូបម្រើបដិវត្តន៍» ហើយត្រូវទះដៃតាមអ្នកដឹកនាំប្រជុំៗ ប្រសិនបើអ្នកចូលរួមប្រជុំមិនថាតាម គឺមានទោសៗ ជួនកាលអង្គការអនុញ្ញាតឲ្យប្រជាជនសម្រាកមួយព្រឹកដើម្បីប្រជុំ ហើយការប្រជុំនោះចំណាយពេលពី២ទៅ៣ម៉ោង ដោយមានអ្នកឡើងចាប់អារម្មណ៍ម្តងៗម្នាក់ បន្ទាប់មកចុងភៅវាយជួងបី

ដងហៅប្រជាជនទៅហូបបាយ ប៉ុន្តែបើមកយឺតគឺគ្មានសល់បាយសម្រាប់ហូបឡើយ។

ចុងភៅបានរៀបតុវែង នៅកណ្តាលរោងបាយរួមៗ ចំណែកចាស់ជរា និងកុមារចុងភៅអនុញ្ញាតឲ្យហូបមុនដោយម្នាក់ៗមានស្លាបព្រា និងចានរៀងៗខ្លួន។ ប្រជាជនត្រូវឈរតម្រង់ជួរ ដើម្បីទទួលរបបអាហារពីចុងភៅ។ ចានបាយមានពណ៌សនិងមានក្រឡា ហើយនៅពេលហូបរួចប្រជាជនត្រូវរក្សាទុកចាននោះ រៀងខ្លួនៗដូនកាលសម្លរមួយចានហូបគ្នា៥នាក់។

ចំណែកការរៀបការ អង្គការមិនឲ្យរៀបចំតាមប្រពៃណីខ្មែរឡើយ។ អ្នកដែលរៀបការត្រូវឡើងចាប់អារម្មណ៍មួយគូម្តងៗ ទាំងប្រុសទាំងស្រី។ គូស្វាមីខ្លះនិយាយ ខ្លីព្រោះបើហ៊ាននិយាយច្រើនខ្លាចខុស។ អង្គការរៀបការឲ្យប្រជាជនម្តង១៥គូ ដោយចំណាយពេលរៀបចំកម្មវិធីចាប់ពីពេលព្រឹក ដល់ម៉ោង១២ថ្ងៃត្រង់ទើបបានចប់រួចរាល់។ អង្គការឲ្យប្រជាជនហៅយាយតា ពូមីងម្តាយ និងឪពុកដោយបន្ថែមពាក្យ«មិត្ត»នៅខាងមុខពាក្យនីមួយៗដូចជា ៖ មិត្តតា មិត្តយាយ មិត្តម៉ែ មិត្តពុក មិត្តបង មិត្តកងទ័ព មិត្តយុទ្ធជន និងមិត្តយុទ្ធនារីជាដើម។

នៅដើមឆ្នាំ១៩៧៩ ប្រជាជននៅឃុំលាចបាននាំគ្នារត់ចោលផ្ទះ និងភូមិឋាន។ ប្រជាជនបានរត់ចេញនៅពេលយប់ ដោយមានមនុស្សដើរនៅតាមផ្លូវរាប់រយនាក់ និងមានឮសូរសំឡេងមនុស្សកងរំពងដេញក្របី។ បងប្អូនរបស់ខ្ញុំបានខ្សឹបប្រាប់ថា សូមត្រៀមអីវ៉ាន់ ស្អែកចេញដំណើរទៅតាមគេ ព្រោះកងទ័ពវៀតណាមបានវាយចូលមកដល់ខេត្តពោធិ៍សាត់ហើយ។ ថ្ងៃមួយនៅពេលកំពុងដាំបាយល្ងាចកងទ័ពវៀតណាមបានបាញ់កាំភ្លើងទៅលើដើម្បីកុំឲ្យត្រូវប្រជាជន ព្រោះមានប្រជាជនរាប់រយនាក់ៗ ខ្ញុំក្រាបនឹងដី។ បន្ទាប់មកខ្ញុំឃើញរថក្រោះមកឈប់នៅពីមុខៗ ខ្ញុំបានលើកកន្សែងពណ៌សគ្រវី ហើយប្រាប់ថា បងប្អូនខ្មែរៗ ខ្ញុំក៏បានរួចរស់ជីវិតហើយក៏មិនបានចូលព្រៃជាមួយខ្មែរក្រហមដែរ។


ភាំ នួន ជាជនជាតិជងខ្នងភ្នំអាយុ៧០ឆ្នាំរស់នៅខេត្តពោធិ៍សាត់

### ៣) ភាំ នួន ៖ អាពាហ៍ពិពាហ៍ក្នុងព្រៃ

ភាំ នួន គឺជាជាតិជង មានអាយុ៧០ឆ្នាំ នួនរៀបរាប់ពីការសែនព្រេនក្នុងព្រៃ និងជីវភាពរស់នៅប្រចាំថ្ងៃក្នុង និងក្រោយរបប ខ្មែរក្រហមថា ៖

«ពេលវៀតណាមចូលមក ខ្ញុំរត់ចូលព្រៃទាំងបងប្អូន និងប្តី។ សំណាងដែរ ដែលមិនមានអ្នកណាស្លាប់ក្នុងព្រៃកាលហ្នឹង។ ខ្ញុំរត់គេចខ្លួន និងមិនបានបាញ់តបតទៅវៀតណាមទេ។ នៅក្នុងព្រៃ ខ្ញុំរស់នៅលាយឡំជាមួយជនជាតិខ្មែរ។ ប្តីរបស់ខ្ញុំគឺជាអតីតទាហានខ្មែរក្រហម។ ខ្ញុំមិនចាំឆ្នាំដែលខ្ញុំបានរៀបការទេ។ ខ្ញុំបានរត់ទៅនៅក្នុងព្រៃនៅតំបន់ជួរភ្នំក្រវាញ។ ឪពុកម្តាយរបស់ខ្ញុំគឺជាប្រជាជន និងប្រកបរបរធ្វើស្រែ ចម្ការ។ យើងហូបដំឡូង និងក្តួចតាំងពីសង្គ្រាមរហូតដល់ប្រទេសទទួលបានសន្តិភាព។

កាលជំនាន់ខ្មែរក្រហម ខ្ញុំធ្លាប់បានឃើញសាកសពហើមៗ ខ្មែរក្រហមបានប្រើខ្ញុំឲ្យលើកភ្លឺស្រែ។ ខ្ញុំមិនដែលបាន

ហូបបាយទេ គឺហូបតែបបរប៉ុណ្ណោះ។ ខ្ញុំមានបងប្អូន៣នាក់ ស្រី២ និងប្រុស១ ហើយខ្ញុំគឺជាកូនបងៗតាមពិតទៅ ខ្ញុំមិនបានរៀបការទេ គឺគ្រាន់តែសែនព្រេនពីរនាក់ប្ដីប្រពន្ធខ្ញុំប៉ុណ្ណោះ។ អាពាហ៍ពិពាហ៍ក្នុងព្រៃពេលនោះមានតែអាវ និងខោពណ៌ខ្មៅប៉ុណ្ណោះ ប៉ុន្តែមិនមានការឡើងប្ដេជ្ញានោះទេ ព្រោះកងទ័ពវៀតណាមបានវាយចូលមកហើយ។

ពិធីរៀបការរបស់ខ្ញុំធ្វើឡើងនៅពេលព្រឹក ដោយមានអ្នកចូលរួមប្រហែល១០នាក់ដោយគ្មានឪពុកម្ដាយរបស់ខ្ញុំទេ ព្រោះយើងរត់ចូលព្រៃបែកគ្នា។ ខ្ញុំនិងប្ដីបានស្រឡាញ់គ្នាហើយមកដល់សព្វថ្ងៃមានកូន៣នាក់។ បន្ទាប់ពីសែនព្រេនរួចខ្ញុំឮស្នូរកាំភ្លើងបាញ់គ្នារាល់ថ្ងៃ។ ខ្ញុំបានផ្លាស់ប្ដូរទីកន្លែងរស់នៅស្ទើររៀងរាល់យប់។ យើងមានសាក់កាដូផលិតនៅចិនតាមខ្លួនម្នាក់មួយដោយមានដាក់ខោអាវ និងចានឆ្នាំង។ នៅក្នុងឆ្នាំងមិនមានអង្ករទេ គឺមានតែក្ដួចព្រោះកាលនោះនៅក្នុងព្រៃសម្បូរក្ដួចណាស់។

ខ្ញុំខ្លាចវៀតណាមតាមវាយប្រហារណាស់ ឲ្យតែហូបបាយហើយ យើងរៀបអីវ៉ាន់ដាក់ក្នុងសាក់កាដូពេញ ដើម្បីត្រៀមរត់។ យើងរែកអីវ៉ាន់ខ្លះ ស្ពាយខ្លះ សែងខ្លះ ហើយយប់ត្រង់ណាយើងដេកត្រង់នោះ។ ពេលខ្ញុំរស់នៅក្នុងព្រៃមានខ្មែរក្រហមរស់នៅ និងហូបជាមួយខ្ញុំដែរ។ ខ្មែរក្រហមឈប់ប្រើខ្ញុំឲ្យធ្វើការទៀតហើយ។ សូម្បីយោធាខ្មែរក្រហមក៏ជីកក្ដួចដូចខ្ញុំដែរ។ ខ្ញុំដើរឆ្លងកាត់ភ្នំច្រើនណាស់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះភ្នំទេ។ ខ្ញុំរត់ចុះឡើងៗពីកន្លែងមួយ ទៅកន្លែងមួយទៀត។ ខ្ញុំមានកន្ទេល ភួយ និងមុងសម្រាប់ដេកក្នុងព្រៃ។ ខ្ញុំរស់នៅបែបហ្នឹងរាប់ឆ្នាំនៅក្នុងព្រៃ។

ក្រោយមក សូរគ្រាប់ផ្លោងនិងកាំភ្លើងបានស្ងាត់មួយរយៈខ្ញុំក៏សម្រេចចិត្តចេញពីព្រៃដើម្បីចូលមកភូមិវិញ។ ពេលនោះខ្ញុំភ័យផង និងអរផង។ ខ្ញុំភ័យព្រោះខ្លាចសង្គ្រាមផ្ទុះឡើងវិញ ហើយអរព្រោះខ្ញុំបានរស់នៅក្នុងភូមិវិញ។ យើងនាំគ្នាកាប់ដីធ្វើចម្ការដើម្បីដាំណាំហូប។ មុនដំបូង ខ្ញុំឃើញមានប្រជាជនមកពីឫស្សីជ្រុំតាតែមាត់ប្រើស និងអូរសោមមកដល់ភូមិខ្ញុំដែរ ប៉ុន្តែខ្ញុំមិនចាំឆ្នាំណានោះទេ។ខ្ញុំចាំថាលែងមានការបាញ់គ្នាទៀតហើយ គឺប្រហែលឆ្នាំ១៩៩៨។

**៨) ស័នឆុច៖ ក្ដួចនិងដំឡូង** «ខ្ញុំគឺជាជនជាតិជង់ខ្នងភ្នំ មានអាយុ៨៨ឆ្នាំ។ កាលខ្ញុំនៅក្មេង ខ្ញុំមិនបានចូលរៀននៅសាលាទេ។ ខ្ញុំមានស្រុកកំណើតនៅឫស្សីជ្រុំ ខេត្តកោះកុង ប៉ុន្តែឥឡូវខ្ញុំបានប្ដូរមករស់ភូមិឆាយលូក ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់វិញ។ កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំបានសែនព្រេនជំនួសឲ្យការរៀបការ ប៉ុន្តែខ្ញុំមិនចាំថាសែននៅឆ្នាំណានោះទេ ហើយសូម្បីភ្ញៀវដែលចូលរួមក៏ខ្ញុំភ្លេចដែរ។ ខ្ញុំមានបងប្អូនបង្កើតដល់ទៅ១២នាក់ប៉ុន្តែ ជាអកុសល ខ្ញុំគ្មានកូនបង្កើតសូម្បីម្នាក់ គឺមានតែកូនចិញ្ចឹម។

នៅឆ្នាំ១៩៧៩ ខ្ញុំបានចូលព្រៃដើម្បីគេចពីការប្រយុទ្ធគ្នា។ កាលនោះខ្ញុំមានបងប្អូន និងញាតិមិត្តច្រើនណាស់ដែលបាន រត់ទៅជាមួយគ្នា គឺមនុស្សមួយភូមិតែម្ដង។ខ្ញុំបាន



ស័ន ឆុចគឺជាជនជាតិជង់ខ្នងភ្នំអាយុ៨៨ឆ្នាំរស់នៅខេត្តពោធិ៍សាត់

ផ្លាស់ប្តូរពីទីកន្លែងមួយទៅកន្លែងមួយទៀត រហូតចូលទៅដល់ក្នុងព្រៃ។ ខ្ញុំមិនមានខោអាវស្លៀកពាក់ត្រឹមត្រូវទេ។ កាលណាខ្ញុំបានសារុងមួយមក ខ្ញុំកាត់វាជាពីរដើម្បីស្លៀកពាក់។ ឥឡូវខ្ញុំគ្មានសល់សារុងទាំងនោះឡើយ។ ខ្ញុំរស់ដោយការជីកដំឡូងនិងក្តួចហូប។ ខ្ញុំស្ងោរដំឡូងពីល្ងាចទុកដល់ព្រឹក ហើយទុកពីពេលព្រឹករហូតដល់ល្ងាចវិញ។ បើប្រៀបធៀបនឹងការរស់នៅក្នុងសម័យខ្មែរក្រហម និងបច្ចុប្បន្នខ្ញុំទទួលរបបអាហារមិនគ្រប់ទេ គឺបានតែបាយមួយកូនចានតូចមួយថ្ងៃ២ពេលប៉ុណ្ណោះ គឺពេលព្រឹក និងពេលល្ងាច។ ភារកិច្ចរបស់ខ្ញុំនៅពេល នោះ គឺអង្គការឲ្យមើលថែកុមារនៅពេលដែលឪពុកម្តាយ របស់កុមារទាំងនោះ ជាប់រវល់ធ្វើការងារនៅវាលស្រែ។ពេលនោះ កងកុមារស្ថិត នៅសហករណ៍ថ្មបាំង។

ខ្ញុំធ្លាប់ឃើញខ្មែរក្រហមបណ្តើរមនុស្សជាជួរៗ។ ខ្ញុំមិនហ៊ានសួរខ្មែរក្រហមថា យកអ្នកទាំងនោះទៅទីណាទេ


ហុន មឿន អាយុ៧៨រស់នៅក្នុងខេត្តពោធិ៍សាត់

ព្រោះខ្ញុំគិតក្នុងចិត្តថា បើខ្ញុំហ៊ានសួរ ខ្មែរក្រហមនឹងសម្លាប់ខ្ញុំចោលដែរ។ ខ្ញុំធ្លាប់បានប្រាប់រឿងរ៉ាវទាំងនេះទៅក្មេងជំនាន់ក្រោយ។ ក្មេងខ្លះជឿ និងខ្លះទៀតក៏មិនជឿដែរ។ រាល់ថ្ងៃនេះ ខ្ញុំសុំតែសេចក្តីសុខគឺគ្រប់គ្រាន់ណាស់ទៅហើយ។ ខ្ញុំលែងចង់បានអ្វីលើសពីហ្នឹងទៀតហើយ។

### ៥) ហុន មឿន ៖គុណរបស់ប្រធានសហករណ៍នៅកំពង់ហ្លួង

ហុន មឿន មានអាយុ៧៨ឆ្នាំមានស្រុកកំណើតនៅឫស្សីជ្រុំ ខេត្តកោះកុង ហើយសព្វថ្ងៃរស់នៅភូមិជម្រុកឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានរៀបរាប់ថា ៖

«ប្រធានសហករណ៍ដែលខ្ញុំរស់នៅជាមួយក្នុងសម័យខ្មែរក្រហម បានជួយសង្គ្រោះជីវិតខ្ញុំ និងប្រជាជនឯទៀតៗ គាត់ឈ្មោះ ឆោម មានអាយុប្រហែល៦០ឆ្នាំ នៅពេលនោះ។ ខ្ញុំនៅតែរឭកគាត់ ទោះបីខ្ញុំដឹងថាគាត់បានស្លាប់បាត់ទៅហើយក៏ដោយ»។ ខ្ញុំមិនចាំថាសហករណ៍នោះឈ្មោះអ្វីទេ គ្រាន់តែដឹងថា សហករណ៍ហ្នឹងនៅព្រៃកកំពង់ហ្លួងខេត្តពោធិ៍សាត់។ ការហូបចុក គឺមានគ្រប់ទាំងអស់គ្នា។យើងមានគ្នា៣០នាក់ ស្មើនឹង៥គ្រួសារក្នុងមួយសហករណ៍រួមទាំង ក្មេងនិងចាស់ ហើយមិនមានអ្នកបាត់ខ្លួនសូម្បីម្នាក់នៅក្នុងសម័យខ្មែរក្រហម។

កាលនោះ អង្គការឲ្យខ្ញុំទៅធ្វើស្រែចម្ការ។ ចំណែកម្ហូបអាហារខ្ញុំត្រូវរកដោយខ្លួនឯង។ អង្គការដាក់ទិសឲ្យចាស់ៗបីនាក់ទៅនេសាទ មកធ្វើម្ហូបនៅក្នុងសហករណ៍។ ខ្ញុំបានហូបបបរខាប់ ដោយម្នាក់មួយផ្តែត។ នៅសហករណ៍ ខ្ញុំចង់ហូបពេលណាក៏បានដែរ។ ប្រជាជនខ្លះចង់ហូបដំឡូង គឺអាចទៅជីកហើយដុតហូប ដោយខ្លួនឯងដោយមិនមានអ្នកហាមឃាត់ឡើយ។ ខ្ញុំមិនដែលអត់បាយទេ។ កាលនោះមានកម្មាភិបាលមកពីសហករណ៍ផ្សេងមកតាមដានដែរ ប៉ុន្តែយើងដឹងមុន ហើយក៏នាំគ្នាដាំបបររាវហូបដើម្បីលាក់បាំង។ នៅពេលកម្មាភិបាលនោះត្រឡប់ទៅវិញ យើងនាំគ្នាដាំបាយ និងបបរ ខាប់ហូបធម្មតា»។ **សន ប៊ុនស៊ីម**

# យន់ យ៉ោង ៖ ជីវិតមនុស្សតាំងពីកើតរហូតដល់ស្លាប់ គឺត្រូវការព្រៃឈើ

«ឆ្នាំព្រៃ» ត្រូវបានចាក់បញ្ចាំងជាសាធារណៈលើកទី២នៅលើទឹកដីនៃខេត្តឧត្តរមានជ័យ កាលពីខែមិថុនាឆ្នាំ២០១៩កន្លងទៅនេះ ដោយមានការចូលរួមពីទស្សនិកជនប្រមាណជាង១.០០០នាក់ រួមមានព្រះសង្ឃសិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ស្ថិតនៅក្នុងចំណោមខ្សែភាពយន្តឯកសារ ប្រមាណជាង២០របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ខ្សែភាពយន្តឯកសារ «ឆ្នាំព្រៃ» បានសង្កត់ធ្ងន់ទៅលើតួនាទីព្រះតេជគុណ ប៊ុន សាលួត ព្រះមេគណខេត្តឧត្តរមានជ័យ ក្នុងការផ្តួចផ្តើមថែរក្សាការពារព្រមទាំងផ្សព្វផ្សាយអំពី «ព្រៃសហគមន៍សង្ឃរុក្ខវ័ន» ដែលមួយភាគធំនៃព្រៃអភិរក្សនេះមានទីតាំងនៅក្នុងស្រុកអន្លង់វែង ដែលជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម។ ក្រៅពីការបង្ហាញអំពីទិដ្ឋភាពដ៏ស្រស់ត្រកាលនៃស្រុកអន្លង់វែង តំបន់នេះក៏ជាសហគមន៍ដ៏សុខដុមមួយរបស់ប្រជាជនប្រមាណម៉ឺននាក់ដែលក្នុងចំណោមប្រជាជនទាំងនេះចំនួនពី៧០ទៅ៨០ភាគរយ ធ្លាប់ជាសមាជិកនៃចលនាខ្មែរក្រហម និងប្រកបរបរធ្វើស្រែចម្ការ ព្រមទាំងរកអនុផលព្រៃឈើដើម្បីចិញ្ចឹមជីវិត។

ដូចទៅនឹងអំឡុងពេលនៃសង្គ្រាមស៊ីវិលរយៈពេលបីឆ្នាំ (១៩៧៩-១៩៩៨) ដែរ ខ្មែរក្រហមបានប្រើប្រាស់ព្រៃឈើធម្មជាតិដ៏ក្រាស់ ដែលស្ទើរតែពន្លឺថ្ងៃមិនអាចជ្រៀតចូលដល់ ធ្វើជាខែលយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីការពារខ្លួន ឬបើកការវាយប្រហារបែបសង្គ្រាមទ័ពព្រៃទៅលើកងកម្លាំងរបស់រដ្ឋាភិបាល និងកងទ័ពស្ម័គ្រចិត្តវៀតណាមនៅ



ទេសភាពបឹងអន្លង់វែង ក្នុងខេត្តឧត្តរមានជ័យ

កម្ពុជា។ ព្រៃឈើដ៏ក្រាស់នេះប្រៀបបានទៅនឹងជីវិតតស៊ូរបស់ខ្មែរក្រហមដែរ ដើម្បីអូសបន្លាយឆាកជីវិតនៃចលនារបស់ខ្លួនដោយឥតរុញរា និងផ្សារភ្ជាប់ទៅនឹងព្រៃឈើមួយកន្លែងដែលត្រូវបានស្គាល់ថា «ព្រៃសហគមន៍សង្ឃរុក្ខវ័ន»។ ភ្នំដងរែក ដ៏ខ្ពស់សន្ធឹម ត្រូវបានខ្មែរក្រហមប្រើប្រាស់ក្នុងការប្រមើមើលទីតាំងយុទ្ធសាស្ត្រ សម្រាប់បម្រើដល់ទស្សនវិស័យដ៏វែងឆ្ងាយរបស់ខ្លួន និង ជាតំបន់ការពារចុង ក្រោយនៅ អន្លង់វែង ខេត្តឧត្តរមានជ័យ។

ព្រៃឈើនៅក្នុងតំបន់អន្លង់វែង បានក្លាយជាប្រភពសេដ្ឋកិច្ចចម្បងរបស់ចលនានេះ បន្ទាប់ពីភាគីជម្លោះនៅកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១។តាម៉ុកដែលជាមេទ័ពនៅអន្លង់វែង បានសហការជាមួយឈ្មួញថៃ កាត់ឈើប្រណិតៗមុខកាត់ធំៗ ដើម្បីដូរយករូបិយប័ណ្ណសម្រាប់ផ្គត់ផ្គង់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងយោធារបស់ខ្លួនរហូតដល់ដង្ហើមចុងក្រោយ។

បន្ទាប់ពីសង្គ្រាមបានផុតរលត់ទៅ ហើយពន្លឺនៃសន្តិភាពបានចាប់ពីឆ្នាំ១៩៩៨មក អន្លង់វែងបានប្រែមុខមាត់ទៅជាសហគមន៍មួយនៃការចងចាំអំពីប្រវត្តិសាស្ត្រ និងរឿងរ៉ាវអតីតកាលដ៏ជូរចត់ ដែលប្រជាជនក្នុងសហគមន៍នេះបានជួបប្រទះ។ កេរ្តិ៍ឈ្មោះរបស់អន្លង់វែង បានបន្សល់ទុកនូវរឿងរ៉ាវដ៏សោកសង្រេងជាច្រើន ហើយការរៀបចំទីតាំងប្រវត្តិសាស្ត្រឡើងវិញ ដែលមានស្រាប់ក្នុងតំបន់អន្លង់វែងនោះ ក៏ជាផ្នែកមួយនៃដំណើរការជីវិតនៃទេសចរណ៍បែបអន្តរការដែរ ដែលអាចជាគុណប្រយោជន៍សម្រាប់សហគមន៍អន្លង់វែងនាពេលអនាគត។


ទេសភាពព្រៃសហគមន៍សង្ឃរុក្ខវ័ន ក្នុងខេត្តឧត្តរមានជ័យ

ដើម្បីឆ្លើយតបទៅនឹងទស្សនវិស័យទាំងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្រោមគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានបង្កើតនូវប្លង់គោលស្រុកអន្លង់វែងឡើង ដោយផ្សាភ្ជាប់ទៅនឹងទីតាំងប្រវត្តិសាស្ត្រទាំង១៤កន្លែងក្នុងស្រុកអន្លង់វែង និងការតភ្ជាប់ផ្លូវដើរថ្មើរជើងរបស់ខ្មែរក្រហមដែលមានក្នុងជំនាន់សង្គ្រាម ដើម្បីបង្កឲ្យមានភាពរស់រវើក សម្រាប់វិស័យទេសចរណ៍ប្រវត្តិសាស្ត្រក្នុងសហគមន៍។

ដោយឈរលើទស្សនាទានបែបនេះ ព្រះពុទ្ធសាសនាក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការថែរក្សាព្រៃឈើដែរ ដែលខ្សែភាពយន្ត «ឆ្នាំព្រៃ» នេះបានបង្ហាញពីតួនាទីរបស់ព្រះសង្ឃក្នុងកិច្ចការនេះ។ ដើម្បីជាការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីសក្តានុពល នៃតំបន់អន្លង់វែងមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយស្ទីករីតភាពយន្ត ធ្វើការចាក់បញ្ចាំងនូវខ្សែភាពយន្តរឿង «ឆ្នាំព្រៃ» ដែលជាផ្ទាំងទស្សនីយភាពឯកសារមួយ ទៅកាន់ប្រជាជនគ្រប់មជ្ឈដ្ឋានឲ្យយល់ដឹងពីបរិស្ថាន ដែលផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រនៅក្នុងតំបន់អន្លង់វែងផ្ទាល់តែម្តង។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺការដើរតួនាទីយ៉ាងសកម្មក្នុងបុព្វហេតុការពារព្រៃឈើធម្មជាតិ និងសត្វព្រៃរបស់ព្រះតេជគុណ ប៊ុន សាលួតដែលព្រះអង្គបានផ្សារភ្ជាប់ជីវិត របស់ព្រះអង្គទៅនឹងពុទ្ធសាសនា ដើម្បីប្រមើមើលពីដំណើរជីវិតតាមធម៌ព្រះពុទ្ធដែលព្រះពុទ្ធទ្រង់បានដាក់អាយុសង្ខារ ដើម្បីបុព្វហេតុស្រោចស្រង់ជីវិតមនុស្សលោក។ ម្ល៉ោះហើយ ព្រះតេជគុណ ប៊ុន សាលួត ព្រះអង្គបានសម្រេចចិត្តបួសជាសង្ឃ ដើម្បីប្រមើមើលនិងកសាងអ្វីដែលជាគុណ



ព្រះសង្ឃ សិស្សានុសិស្ស និងប្រជាពលរដ្ឋចូលរួមទស្សនាការចាក់បញ្ចាំងកុនឯកសាររឿង «ឆ្នាំព្រៃ»

ប្រយោជន៍ ដល់មនុស្សលោកដែរ។

ការចាក់បញ្ចាំងខ្សែភាពយន្ត «ឆ្នាំព្រៃ» នៅក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ បានប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ កន្លងទៅដើម្បីជាសារយ៉ាងទូលំទូលាយសម្រាប់មហាជននៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើយើងក្រឡេកទៅមើលពីទិដ្ឋភាពក្រុងសំរោងនៃខេត្តឧត្តរមានជ័យវិញ គឺមានភាពមមាញឹក ដែលស្ថានភាពរស់នៅរបស់ប្រជាជនភាគច្រើន នៅក្នុងតំបន់នេះក៏មិនខុសប្លែកពីស្ថានភាពរស់នៅរបស់ប្រជាជននៅតំបន់ផ្សេងៗទៀត ប៉ុន្មានដែរ ហើយការលក់ដូរ និងការប្រកបរបរធ្វើស្រែចម្ការគឺបានធ្វើឡើងជាធម្មតា។ ចំណែកឯទេសភាព គឺមានបឹងស្មោរដែលបន្សល់ ទុកតាំងពីសម័យសង្គមរាស្ត្រនិយមដោយរំលេចនូវភាព ស្រស់បំព្រងនៃជីវិតដែលលូតលាស់នៅជុំវិញ


ព្រះតេជគុណ ប៊ុន សាលួត ព្រះមេគុណខេត្តឧត្តរមានជ័យ

ប្រភពទឹក។

បើយើងទាញចំណាប់អារម្មណ៍ទៅលើការរៀបចំនៃការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» គឺបានប្រព្រឹត្តទៅអស់រយៈពេលជាច្រើនម៉ោង រហូតដល់ព្រះអាទិត្យ បានទន់ទាបទៅកាន់ជើងមេឃនៅវេលាប្រហែលម៉ោង៥ល្ងាច ពេលនោះព្រះសង្ឃ ប្រជាជន និងសិស្សានុសិស្ស បានធ្វើដំណើរមកបណ្ដើរៗ ដែលបង្កើតបាននូវទិដ្ឋភាពដ៏អ៊ូអរមួយនៅក្នុងក្រុងសំរោង។ ប្រជាជនបានធ្វើដំណើរដោយមធ្យោបាយផ្សេងៗគ្នា ដោយអ្នកខ្លះធ្វើដំណើរដោយម៉ូតូ ខណៈពេលដែលអ្នកខ្លះទៀតធ្វើដំណើរដោយកង់ និងថ្មើរជើង។ ប្រជាជន និងព្រះសង្ឃជាច្រើនអង្គ បានមកកាន់ទីលានបញ្ចាំងកុន ដោយទឹកមុខញញឹមពព្រាយ ព្រមទាំងហែហមដោយសិស្សានុសិស្សជាច្រើននាក់ដែលទើបចេញពីរៀន។

កម្មវិធីនៃការចាក់បញ្ចាំងកុនឯកសាររឿង «ឆ្នាំព្រៃ» បានចាប់ផ្ដើមឡើងដោយការបន្លឺឡើងនូវសំឡេងស្គរ និងការច្រៀងបទពង្សាវតាខ្មែរយ៉ាងគ្រលួច របស់សិស្សានុសិស្សនៃវិទ្យាល័យតេជោ សែនខេត្តឧត្តរមានជ័យ។ ក្រោយការច្រៀងចម្រៀងជាតិត្រូវបានបញ្ចប់កញ្ញា យ៉េន សុសម្ផស្ស» ដែលជាពិធីការនីមួយរូប នៅក្នុងអង្គពិធីទាំងមូលបានបញ្ចេញសារសព្ទទៅកាន់មហាជន ដែលញុំាងឲ្យកម្មវិធីប្រព្រឹត្តទៅមុខបានយ៉ាងល្អ។

ពិធីការនី យ៉េន សុសម្ផស្ស បានអញ្ជើញ បណ្ឌិត លី សុខឃាង គឺជានាយកនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឡើងថ្លែងសុន្ទរកថា និងស្វាគមន៍ភ្ញៀវជាតិ និងអន្តរជាតិ។ តាមរយៈមតិស្វាគមន៍នេះ បណ្ឌិត លី សុខឃាង បានរំលេចនូវចំណងជើងនូវខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» ដែលត្រូវបានដកស្រង់ចេញពីស្រុកអន្លង់វែង ដែលជាតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម ជាពិសេសភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» បានរំលេចចេញនូវគំរូវីរភាពរបស់ព្រះតេជគុណ ប៊ុន សាលួត នៅក្នុងបុព្វហេតុការពារ និងអភិរក្សព្រៃឈើធម្មជាតិដែលត្រូវបានស្គាល់ថាជា «ព្រៃសហគមន៍

សង្ឃរុក្ខវ័ន» ដែលជាព្រៃអភិរក្ស ស្ថិតនៅជាប់ស្រុកចំនួន៣គឺ ៖ ស្រុកចុងកាល់ ស្រុកសំរោង និងស្រុកអន្លង់វែង។ ឆ្លៀតឱកាសនោះ បណ្ឌិត លី សុខឃាង ក៏បានទាញចំណាប់អារម្មណ៍ទាក់ទងនឹង«មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង» ដែលជាស្ថាប័នឈានមុខក្នុងការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សាយពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។

ការបញ្ចប់សង្គ្រាមស៊ីវិលនិងការ នាំមកនូវសន្តិភាព គឺជាសមិទ្ធផលជាតិដ៏មានតម្លៃបំផុតសម្រាប់សង្គមទាំងមូល ។ការថែរក្សាសន្តិភាព គឺជាកាតព្វកិច្ចមួយទៀតដែលប្រជាជាតិទាំងមូលត្រូវការពេលយូរអង្វែងតទៅមុខទៀត។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានបំពេញការងារឆ្ពោះទៅរកការលើកកម្ពស់ការអប់រំប្រវត្តិសាស្ត្រ នៃចលនាខ្មែរក្រហមក្នុងគោលបំណង ដើម្បីបម្រើឲ្យការចងចាំការផ្សះផ្សានិងការកសាងសន្តិភាព។មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានបំពេញកាតព្វកិច្ចមួយទៀត ដោយអភិរក្សនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រទាំង១៤កន្លែងនៅក្នុងស្រុកអន្លង់វែង និងបង្កើតប្លង់គោល ដើម្បីតភ្ជាប់តំបន់១៤កន្លែងទៅជាកញ្ចប់ទស្សនកិច្ចទេសចរណ៍នាពេលអនាគត។ ប្លង់ទិដ្ឋភាពរួមនេះ ក៏បានផ្តោតលើចក្ខុវិស័យក្នុងការអភិវឌ្ឍន៍តំបន់អន្លង់វែងឲ្យទៅជាទីក្រុងនៃសន្តិភាព និងការបង្កើតជីវិតថ្មីនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃដែរ។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានកំពុងរិះរក និងបង្កើតគំនិតផ្សេងៗទៀតជាមួយនឹងថ្នាក់ដឹកនាំទេសចរណ៍ ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយពីអន្លង់វែង តាមរយៈការរៀបចំជាព្រឹត្តិការណ៍រត់ម៉ារ៉ាតុននៅលើភ្នំដងរែក ដែលមានមនុស្សប្រហែលជាង១.០០០នាក់បានចូលរួម។ ក្រៅពីនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏បានរៀបចំវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៏ទេសចរណ៍ សម្រាប់សហគមន៍អន្លង់វែង ចំនួនពីរលើករួចមកហើយ ហើយមានសិក្ខាកាមចូលរួមប្រហែល៣១នាក់ និងមានការតាំងពិព័រណ៍រូបថត១០០សន្លឹកនៅក្នុងសារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែងឬសារមន្ទីរអតីតផ្ទះតាម៉ុកដែរ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបាន និងកំពុងបង្កើតវេទិកាថ្នាក់រៀន ដើម្បីបង្រៀនអំពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង នៅតាមវិទ្យាល័យនិងអនុវិទ្យាល័យនៃស្រុកអន្លង់វែង។

លោកបណ្ឌិត លី សុខឃាង ក៏បានទាញចំណាប់អារម្មណ៍ថា ទោះបីជាសិល្បៈស្ថិតនៅក្នុងទម្រង់ជាល្ខោន ជាភាពយន្ត ឬជាគំនូរគ្គី ក៏អាចចូលរួមចំណែកក្នុងការយល់ដឹងពីប្រវត្តិសាស្ត្របានដែរ។ ដូច្នេះហើយទើបមជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការរៀបចំផលិតខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ ដោយផ្សារភ្ជាប់ទៅនឹងការអប់រំ និងការយល់ដឹងជាសាធារណៈអំពីប្រវត្តិសាស្ត្រខ្មែរក្រហមធម្មជាតិព្រៃព្រឹក្សា និងបឹងបួរក្នុងស្រុកអន្លង់វែង។ ការបង្ហាញអំពី



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ព្រៃឈើនៅក្នុងតំបន់អន្លង់វែង ពុំគ្រាន់តែជាគោលបំណងមួយរបស់ខ្សែភាពយន្ត «ឆ្នាំព្រៃ» ប៉ុណ្ណោះទេប៉ុន្តែដើម្បីប្រែក្លាយឲ្យទៅជាស្មារតីជាតិរួមមួយដែលមានយូរលង់ដំណាលគ្នាទៅនឹងការកកើតព្រៃឈើនៅក្នុងតំបន់នេះ។

គំរូវីរភាពរបស់ព្រះតេជគុណ ប៊ុនសាលួតនឹងជំរុញទឹកចិត្តឲ្យសាធារណជនបងប្អូនប្រជាពលរដ្ឋ សិស្សានុសិស្សទាំងអស់ចូលរួមក្នុងការការពារ និងថែរក្សាធនធាន ធម្មជាតិនិងព្រៃព្រឹក្សាដែរ។

ជាកិច្ចបន្ទាប់ លោកស្រី រីប៊ែកា ប្លេក នាយិកាស្តីទីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ ការអភិវឌ្ឍន៍អន្តរជាតិ (USAID)បានឡើងថ្លែងនូវចំណាប់អារម្មណ៍នៅលើអគ្គវេទិកាទាំងមូលនៃការចាក់បញ្ចាំងកុននេះថា៖ «ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមការបញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នៅក្នុងក្រុងសំរោងនេះ។ ទាំងនេះគឺជាការបង្ហាញនូវការថែរក្សាព្រៃឈើ ដែលជាសម្បត្តិធម្មជាតិដ៏មានតម្លៃបំផុត ដែលយើងបានអនុវត្តកន្លងមក។ កំឡុងពេលបំពេញការងារនៅក្នុងប្រទេសកម្ពុជា ខ្ញុំបានរៀនសូត្រទាក់ទងនឹងបញ្ហាបរិស្ថានធនធានធម្មជាតិនិងជីវៈចម្រុះដែលមានតម្លៃក្នុងប្រទេសកម្ពុជា។ ខ្ញុំសូមស្ងើចសរសើរពីឆន្ទៈរបស់ព្រះសង្ឃ នៃព្រះពុទ្ធសាសនាដែលផ្សាភ្ជាប់យ៉ាងស្អិតរមួតទៅនឹងសកម្មភាពថែរក្សាព្រៃឈើដែលទាក់ទងនឹងព្រៃសហគមន៍សង្ឃរុក្ខវ័ន ដែលជាភ្នាក់ងារឯករាជ្យមួយក្នុងការការពារបរិស្ថានសង្គម។»

លោកស្រីបាននិយាយថា៖« ខ្ញុំមើលឃើញថាព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការថែរក្សាព្រៃឈើ ដើម្បីទប់ស្កាត់នូវផលប្រឈមផ្សេងៗដែលកើតមានឡើង នៅពេលដែលព្រៃឈើដ៏ស្រស់ត្រកាលត្រូវបានបំផ្លាញ។ ចំពោះបទពិសោធន៍របស់ខ្ញុំ ដែលបានដើរកម្សាន្តនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំយល់ថាវត្តស័ក្តិសិទ្ធិទាំងឡាយពិតជា បានថែរក្សាមនុស្សដែលរស់នៅក្នុងព្រៃយ៉ាងពិតប្រាកដ។ ខ្ញុំសូមចូលរួមនូវការអបអរសាទរទៅកាន់ព្រះតេជគុណ ប៊ុន សាលួត ក៏ដូចជាព្រះសង្ឃឯទៀតដែលបានរួមចំណែកការពារបរិស្ថានព្រៃឈើធម្មជាតិនេះ។

ខ្ញុំក៏សូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ព្រះតេជគុណដែលប្រឆាំង ទៅនឹងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ក៏ដូចជាការធ្វើឲ្យប៉ះពាល់បរិស្ថានធម្មជាតិនៅលើភពផែនដី។»

ឆ្លៀតឱកាសនេះ លោកស្រី បានគូសបញ្ជាក់ទៀតថា ៖ «ខ្ញុំក៏សូមទាញចំណាប់អារម្មណ៍អ្នកចូលរួមដែរថា ក្នុងនាមជាតសាសន៍អាមេរិក ក៏មានការលំបាកដែរចំពោះបញ្ហានៃការថែរក្សាព្រៃឈើនៅក្នុងប្រទេសអាមេរិកដូចគ្នា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រជាជនទាំងអស់នៅក្នុងទឹកដីនៃសហរដ្ឋអាមេរិក បានខិតខំប្រឹងប្រែងការពារតំបន់ព្រៃឈើនិងឧទ្យានជាតិផ្សេងៗដែរ។



លោកស្រី រីប៊ែកា ប្លេក នាយិកាស្តីទីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID)

លោកស្រីបាននិយាយថា៖ «កន្លងមកក្រុមការងាររបស់ខ្ញុំបានចូលរួមក្នុងការ គាំទ្រទៅលើការការពារបរិស្ថានដូចគ្នានេះដែរ។ ហេតុដូច្នេះ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ក៏បានគាំទ្រលើទំហំទឹកប្រាក់ចំនួន២១ លានដុល្លារនៅក្នុងការថែរក្សាព្រៃឡង់ ដែលមនុស្សជាច្រើនបានកំពុងពឹងផ្អែកលើប្រភពធម្មជាតិមួយនេះ។ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ក៏បានសហការជាមួយដៃគូផ្សេងៗទៀត នៅក្នុងខេត្តមណ្ឌលគិរីក្នុងការថែរក្សាសត្វព្រៃនិងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ដែរ។

ដូចនេះ សង្គមមួយដែលរឹងមាំ គឺពឹងផ្អែកទៅលើការការពារនិងការគ្រប់គ្រងព្រៃឈើ ហើយជាពិសេសគឺធនធានធម្មជាតិដែលជា វត្ថុដ៏មានតម្លៃបំផុតសម្រាប់សង្គមកម្ពុជាទាំងមូលដែលធ្វើឲ្យ កម្ពុជាមានផ្លូវដើរដ៏វែងឆ្ងាយមួយក្នុងគោលដៅ និរន្តរភាពពេញបរិបូរណ៍»។

ក្នុងខ្សែភាពយន្តឯកសាររឿង«ឆ្នាំព្រៃ» នេះបានផ្ដល់នូវផ្ទាំងទស្សនីយភាពថ្មីមួយនៃស្រុកអន្លង់វែង ទាក់ទងនឹងប្រវត្តិសាស្ត្រ ដែលបានកើតឡើងនៅក្នុងតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម។ នេះគឺជាការបង្ហាញមួយយ៉ាងល្អិតល្អន់ថា អន្លង់វែង បានក្លាយជាតួអង្គមួយយ៉ាងសំខាន់នៅខាងក្រោយខ្សែភាពយន្តនេះ ដែលបានលើកឡើងពីតម្លៃនៃសន្តិភាពក៏ដូចជាជីវិត នៃការរស់នៅក្នុងពិភពធម្មជាតិបៃតងដ៏ស្រស់ត្រកាលមួយ។

លោកស្រីបានបន្តថា៖ នៅថ្ងៃស្អែកនេះ ខ្ញុំនឹងបន្តទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលមានទីតាំងនៅលើខ្នងភ្នំដងរែក ជាប់ព្រំប្រទល់រវាងប្រទេសកម្ពុជានិងប្រទេសថៃ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនេះបានធ្វើកិច្ចការងារជាច្រើន ដើម្បីរក្សាបាននូវឯកសារប្រវត្តិសាស្ត្រដែល តំបន់នេះបានជួបប្រទះទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍។ តាមរយៈការទស្សនាខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» និងការធ្វើទស្សនកិច្ចនេះ នឹងធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងច្រើនបន្ថែមទៀត។ បច្ចុប្បន្នសហរដ្ឋអាមេរិកបានគាំទ្រ មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចងក្រងនូវមេរៀនពីអតីតកាល ដើម្បីបង្កើតនូវការចេះអត់ឱនអធ្យាស្រ័យ និងការផ្សះផ្សានៅកម្ពុជា។ ខ្ញុំបានមើលឃើញពីតួនាទីរបស់ព្រះពុទ្ធសាសនា ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការផ្សះផ្សាជាតិមួយនេះ បន្ទាប់ពីរបបដ៏ខ្មៅងងឹតបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។»

ជាកិច្ចបន្ទាប់ ជាការសម្ដែងមតិសំណេះរបស់ឯកឧត្តម ហួន វ៉ាន់និត អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ។ ឯកឧត្តម ហួន វ៉ាន់និត បានថ្លែងនាទីកាសចាក់បញ្ចាំងកុននេះថា «ឆ្នាំព្រៃ» គឺជាខ្សែភាពយន្តមួយដែលបង្ហាញអំពីវីរៈភាពរបស់ព្រះអង្គ ប៊ុន សាលួត ដែលព្រះអង្គបានលះបង់កម្លាំងកាយចិត្ត ដើម្បីថែរក្សាប្រភពធនធានធម្មជាតិព្រៃឈើនៅក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន ដែលស្ថិតនៅក្នុងខេត្ត



ឯកឧត្តម ហួន វ៉ាន់និត អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

ឧត្តរមានជ័យនាពេលបច្ចុប្បន្ន។ ឯកឧត្តមបានមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលខ្សែភាពយន្តឯកសារនេះបានបំផុសឡើងនូវបេសកកម្ម នៃការប្តេជ្ញាចិត្តយ៉ាងមុះមុតក្នុងការថែរក្សាធនធានធម្មជាតិ គឺធនធានព្រៃឈើសម្រាប់មនុស្សជំនាន់ក្រោយ ដែលមានសិស្សានុសិស្សគឺជាទំពាំងស្នងឫស្សី និងថាតើខ្សែភាពយន្តនឹងបង្ហាញនូវសារសំខាន់យ៉ាងដូចម្តេចចំពោះមនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ ឯកឧត្តមហ៊ួនវ៉ាន់និតបានបញ្ជាក់ដែរថាការទប់ស្កាត់ និងការអភិរក្សព្រៃឈើនៅក្នុងសហគមន៍សង្ឃរុក្ខាវ័ន្ត គឺជាសកម្មភាពដ៏សំខាន់មួយដែលជាពិសេសគឺមានការសហការ យ៉ាងជិតស្និតជាមួយកម្លាំងអន្តរាគមន៍របស់រាជរដ្ឋាភិបាលកម្ពុជាតែម្តង។ ក្នុងឱកាសនៃការចាក់បញ្ចាំងនូវខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នេះដែរ ឯកឧត្តមហ៊ួន វ៉ាន់និត ក៏បានទាញចំណាប់អារម្មណ៍ អំពីស្រុកអន្លង់វែងដែរថាអន្លង់វែង គឺជាតំបន់តស៊ូចុងក្រោយរបស់ក្រុមខ្មែរក្រហម។ហើយព្រឹត្តិការណ៍ទាំងឡាយដែលកើតឡើងនៅក្នុងតំបន់តស៊ូចុងក្រោយនេះគឺពោរពេញទៅដោយភាពឈឺចាប់ និងភាពសោកសង្រេង នៃការបង្ហូរឈាមរវាងភាគីខ្មែរក្រហម និងខ្មែរ។ ការចាក់បញ្ចាំងខ្សែភាពយន្តនេះ គឺជាព្រឹត្តិការណ៍មួយដ៏អស្ចារ្យ និងដ៏កម្រទម្រាំតែយើងអាចឈានមកដល់ថ្ងៃនេះ។ អ្វីដែលជាគោលបំណងសំខាន់សម្រាប់ព្រឹត្តិការណ៍នៅថ្ងៃនេះ គឺជាការបំផុសឡើងនូវសន្តិភាពតាមរយៈការរួបរួមគ្នា ការសាមគ្គីគ្នាគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថអង្គការជាតិ និងអន្តរជាតិ ដើម្បីការពារធនធានធម្មជាតិព្រៃឈើនៅក្នុងស្រុកចំនួន៣ គឺស្រុកចុងកាល់ ស្រុកសំរោង និងស្រុកអន្លង់វែង ដែលជាព្រៃឈើចុងក្រោយបង្អស់ដែលទទួលបានការ អភិរក្សនៅក្នុងខេត្តឧត្តរមានជ័យ។

ក្នុងឱកាសនោះ ឯកឧត្តម ហ៊ួន វ៉ាន់និត ក៏បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធឲ្យចូលរួមក្នុងការការពារព្រៃឈើ និងទប់ស្កាត់បទល្មើសព្រៃឈើ ដើម្បីអនាគតកូនចៅជំនាន់ក្រោយ។ ជាមួយនឹងព្រឹត្តិការណ៍ នៃការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» នេះក្នុងនាមលោកតំណាងឲ្យអភិបាលខេត្តឧត្តរមានជ័យ ក៏សូមចូលរួមយោបល់មួយចំនួនសម្រាប់ការបំពេញការងារទាំងអស់គ្នា ជាពិសេសប្រជាពលរដ្ឋនៅក្នុងខេត្តឧត្តរមានជ័យ ដែលត្រូវរួបរួមគ្នាក្រោមម្លប់នៃសន្តិភាពត្រូវយកចិត្តទុកដាក់ និងពង្រឹងបន្ថែមទៀតលើបញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈតាមរយៈការអនុវត្តគោលការណ៍ភូមិឃុំមានសុវត្ថិភាពដោយឥតខកខាន។

ឯកឧត្តម ហ៊ួន វ៉ាន់និត ក៏បានក្រើនរំឭកថាបញ្ហាគ្រឿងញៀនជាបញ្ហាប្រឈម និងត្រូវលុបបំបាត់ជាដាច់ខាត ព្រោះវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើក្មួយៗសិស្សានុសិស្ស។ ក្រៅពីនេះបញ្ហាក្មេងទំនើងក៏ជាសញ្ញាណមួយដ៏អាក្រក់ដែរ។ ដូច្នេះការរួបរួមគ្នាក្រោមដំបូលនៃសន្តិភាព គឺជាឆ្អឹងមួយដែលមិនអាចកាច់បំបាក់បាន និងរក្សាបាននូវសន្តិសុខសណ្តាប់ធ្នាប់ក្នុងភូមិ-ឃុំក៏ដូចជាក្រុងទាំងមូលដែរ។

បន្ទាប់ពីឯកឧត្តម ហ៊ួន វ៉ាន់និត ថ្លែងនូវសុន្ទរកថាសំណេះសំណាលចប់ ព្រះតេជគុណ ប៊ុន សាលួត គឺជាព្រះមេគុណនៃខេត្តឧត្តរមានជ័យ បានមានសង្ឃដីកាអំពីការមកដល់ដំបូងរបស់ព្រះអង្គ នៅក្នុងបុព្វហេតុការពារសត្វព្រៃ និងធនធានធម្មជាតិ នៅក្នុងតំបន់ព្រៃសហគមន៍សង្ឃរុក្ខវ័ន ដែលជាព្រះទ័យ នៃការស្រឡាញ់ពេញចិត្តរបស់ព្រះអង្គ។ ព្រះអង្គក៏បានស្វែងយល់ពីដំណើរជីវិតរបស់ព្រះពុទ្ធ ដែលបានផ្សាភ្ជាប់ដំណើរជីវិតរបស់ព្រះអង្គទៅនឹងព្រះពុទ្ធសាសនា និងខិតខំកសាងអ្វីដែលជាប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយ។ ព្រះតេជគុណមិនមានសង្ឃដីកាអ្វីច្រើននោះដែរ ដោយទុកឱកាស និងពេលវេលានេះ ដើម្បីឲ្យពុទ្ធបរិស័ទទស្សនាខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» ដោយខ្លួនឯង។

ខ្សែភាពយន្ត «ឆ្នាំព្រៃ» ប្រៀបបានទៅនឹងកញ្ចក់ឆ្លុះបញ្ចាំងអំពីខ្សែជីវិតបៃតងនៅក្នុងសហគមន៍មួយ ដែលបានពឹងផ្អែកទៅលើធម្មជាតិ ព្រៃឈើដោយឥតស្រាកស្រាន

ហើយពណ៌បៃតងនេះគឺជាសញ្ញាមួយបង្ហាញថា ជាការបើកផ្លូវឲ្យមនុស្ស និងសង្គមជាតិ ឲ្យធ្វើដំណើរទៅមុខ បើទោះបីជាកាលពីអតីតកាលយើងបានជួបនូវគ្រោះហួតហែងដោយសារភ្លើងសង្គ្រាមក៏ដោយ។

បន្ទាប់ពីការចាក់បញ្ចាំងកុនបានបញ្ចប់ មនុស្សម្នាជាច្រើនបានមើលឃើញពីគុណតម្លៃនៃព្រៃឈើ និងភាពស្រស់ត្រកាលនៃធម្មជាតិ ដែលប្រៀបបានទៅនឹងដង្ហើមចេញចូលរបស់មនុស្ស ហើយបានបញ្ចេញនូវចំណាប់អារម្មណ៍ ផ្សេងៗគ្នា ដូចខាងក្រោម ៖«អាត្មាព្រះនាម យន់ យ៉ោង ព្រះជន្មាយុ៧១ព្រះវស្សា គង់នៅវត្តប្រាសាទរាជាសំរោងគឺជាសិស្សគុណរបស់ព្រះមេគុណ ប៊ុន សាលូត មានសង្ឃ ដីកាថា ៖ អាត្មាភាពមានសេចក្តីត្រេកអរណាស់ ប៉ុន្តែដោយវ័យអាត្មា កាន់តែចាស់ជរាពុំអាចទៅជួយលោកបាន។ អាត្មាមានទឹកព្រះទ័យណាស់ក្នុងការថែរក្សាព្រៃឈើប៉ុន្តែអាត្មាពុំអាចធ្វើដំណើរទៅក្នុងព្រៃជាមួយលោកបាន។ អាត្មាសំណូមពរទៅប្រជាជន ដែលអញ្ជើញមកទីនេះសូម ជួយផ្សព្វផ្សាយដល់កូនចៅរបស់ខ្លួនអំពី ការថែក្សាព្រៃឈើ ព្រោះ ព្រៃឈើគឺជាជម្រករបស់មនុស្ស ហើយជី វិត មនុស្សលោកតាំងពីកើតរហូតដល់ស្លាប់គឺត្រូវការ ព្រៃ និងឈើ ជារៀងរហូត។ ដូច្នេះយើងត្រូវដាំ និងថែទាំព្រៃឈើបន្តទៅមុខទៀត ព្រោះសព្វថ្ងៃព្រៃឈើកំពុងតែទទួលរងការវិនាស។ បើយើងមិនថែរក្សាទេនោះព្រៃឈើនឹងសាបសូន្យនៅថ្ងៃក្រោយជាក់ជាពុំខាន»។

សួន សុធា ជាសិស្សនៃវិទ្យាល័យហ៊ុនសែនឧត្តរមានជ័យបង្ហាញចំណាប់អារម្មណ៍ថា«ខ្ញុំពិតជាមានការយល់ដឹងច្រើនអំពីព្រៃឈើ និងសត្វព្រៃដែលទទួលរងនូវការកាប់បំផ្លាញ។ សម្រាប់សកម្មភាពការពារព្រៃឈើរបស់ព្រះសង្ឃព្រះពុទ្ធសាសនា គឺខ្ញុំមានការគាំទ្រ ដើម្បីជីវិតមនុស្ស និងសត្វព្រៃយូរអង្វែងទៅមុខទៀត»។

ម៉ន ស្រីណុច គឺជាសិស្សនៃវិទ្យាល័យតេជោសែនឧត្តរមានជ័យ បានយល់ឃើញថា រឿងនេះពិតជាល្អខ្លាំងណាស់ និងជាកញ្ចក់ឆ្លុះបញ្ចាំងដល់ក្មេងជំនាន់ក្រោយឲ្យបានយល់ដឹងច្រើនពីសារសំខាន់នៃឈើនិងសត្វព្រៃ ដែលមនុស្សជាច្រើនក្នុងសហគមន៍ មិននឹកស្មានថានៅសេសសល់»។

ម៉ៅ អាយុ៣៥ ជាអ្នកភូមិមួយរូបក្នុងសំរោង បានរៀបរាប់ថា «ដោយសារឃើញព្រះសង្ឃក្នុងព្រះពុទ្ធសាសនា មានព្រះទ័យថែរក្សាព្រះឈើ ដូច្នេះខ្ញុំជាពុទ្ធបរិស័ទក៏មានសេចក្តីរីករាយក្រៃលែង។ ខ្ញុំក៏បានចូលរួមក្នុងសកម្មភាពនេះដែរ ហើយខ្ញុំនឹងចូលរួម ផ្សព្វផ្សាយបន្តអំពីការថែរក្សាព្រៃសហគមន៍សង្ឃរុក្ខវ័ន និងព្រៃឈើនៅក្នុងសហគមន៍ផ្សេងៗទៀត។

**សួត វិចិត្រ**



ដើមច្បោះ ក្នុងព្រៃសហគមន៍សង្ឃរុក្ខវ័ន

# ការស្រឡាញ់ព្រៃឈើប្រៀបដូចជាស្រឡាញ់ខ្លួនឯង

ខ្ញុំឈ្មោះ ណាង ស៊ីណា ភេទស្រី អាយុ២៣ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិដាក់ផ្កា ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ខ្ញុំគឺជាកូនទី២ក្នុងចំណោមបងប្អូន៥នៅក្នុងគ្រួសារ។ ក្រុមគ្រួសាររបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ។ឪពុករបស់ខ្ញុំគឺជាអតីតយោធាខ្មែរក្រហម។ គាត់បានពិការជើងខាងឆ្វេងដោយសារតែជាន់គ្រាប់មីន ដែលបានកប់ក្នុងដីនៅអំឡុងពេលសង្គ្រាមទសវត្សរ៍ឆ្នាំ៧០។ បន្ទាប់ពីខ្ញុំប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ខ្ញុំបានផ្អាកពីការសិក្សាអស់រយៈពេល២ ឆ្នាំដើម្បីជួយកិច្ចការងាររបស់គ្រួសារ ដោយសារតែគ្រួសាររបស់ខ្ញុំមានជីវភាពខ្វះខាត។ ប៉ុន្តែសព្វថ្ងៃនេះខ្ញុំ គឺជានិស្សិតឆ្នាំទី១ ផ្នែកទីផ្សារនៅសាកលវិទ្យាល័យបៀលប្រាយនៅក្នុងខេត្តសៀមរាប។ដំបូង ខ្ញុំមានបំណងចង់សិក្សាផ្នែកកសិកម្មប៉ុន្តែដោយសារតែសាកលវិទ្យាល័យ មិនមានសិស្សគ្រប់ចំនួនដើម្បីសិក្សាលើមុខវិជ្ជានេះ ទើបតម្រូវឲ្យខ្ញុំប្តូរទៅសិក្សាខាងផ្នែកទីផ្សារវិញ។

ខ្ញុំសប្បាយចិត្តណាស់ នៅពេលដែលបានទស្សនាការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» ដែលជាខ្សែភាពយន្តមួយរៀបរាប់អំពីធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ ខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» បានប្រាប់ខ្ញុំអំពីអតីតកាល បច្ចុប្បន្នកាល និងជាការដាស់តឿនស្មារតីរបស់ខ្ញុំនៅថ្ងៃអនាគតដែរ។ ឪពុករបស់ខ្ញុំធ្លាប់បានប្រាប់ខ្ញុំថានៅក្នុងប្រទេសកម្ពុជា គឺពិតជាសម្បូរទៅដោយព្រៃឈើ និងសត្វព្រៃ ជាពិសេសនៅតាមជួរភ្នំដែលលាតសន្ធឹងនៅតាមព្រំដែន ហើយក៏មិនសូវមានប្រជាជនរស់នៅច្រើនកុះករដែរនៅតាមតំបន់ទាំងនោះ។ ប៉ុន្តែបច្ចុប្បន្នអ្វីៗបានផ្លាស់ប្តូរអស់ទៅហើយ។ ពីមួយឆ្នាំទៅមួយឆ្នាំ ចំនួនប្រជាជនកាន់តែកើនឡើង ហើយតម្រូវការនៃការប្រើប្រាស់ដីធ្លីក៏មានកាន់តែច្រើនដែរ។ ដូច្នេះ ព្រៃឈើពិតជាប្រឈមមុខខ្ពស់ចំពោះការបាត់បង់ពីភពផែនដីនេះ។ រាល់ពេលដែលខ្ញុំសម្រាកពីការសិក្សា និងទៅលេងស្រុកកំណើត ជារឿយៗខ្ញុំបានឃើញ



និស្សិតនៅក្នុងសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប កំពុងទស្សនាខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»

ប្រជាជនដឹកឈើ និងខុសដែលបានពុះជាចំរៀកដឹកតាមគោយន្តជាបន្តបន្ទាប់គ្នានៅលើដងផ្លូវៗ ខ្ញុំមិនដឹងថាតើប្រជាជនដឹកឈើទាំងអស់នេះទៅលក់ ឬធ្វើអ្វីនោះទេៗ ខ្ញុំពិតជាសោកស្តាយណាស់នៅពេលដែលឃើញសកម្មភាពដូច្នេះៗ ទោះបីជាដើមឈើទាំងនោះគឺជាប្រភេទឈើតូចៗឬក៏ឈើធំៗក៏ដោយ ប៉ុន្តែដើមឈើផ្តល់ផលប្រយោជន៍ដូចៗគ្នាសម្រាប់

សម្រាប់ខ្ញុំ ព្រះតេជគុណ ប៊ុន សាលូត គឺជាព្រះសង្ឃដែលមានទេពកោសល្យដ៏អស្ចារ្យអាចសម្រេចបាននូវកិច្ចការដ៏ធំធេង ដែលកម្រនឹងមានអ្នកធ្វើដូចព្រះអង្គៗ កិច្ចការរបស់ព្រះអង្គ បានបង្ហាញឲ្យពិភពលោកមើលឃើញពីភាពរឹងមាំ និងដំណើរការនៃការដោះស្រាយវិបត្តិដែលនៅសេសសល់ក្នុងប្រទេសកម្ពុជាបន្ទាប់ពីសង្គ្រាមៗ



ព្រះតេជគុណ ប៊ុន សាលូត ថ្លែងសុន្ទរកថាទៅកាន់អ្នកទស្សនាខ្សែភាពយន្តឯកសារ រឿង «ឆ្មាំព្រៃ»

ជីវិតមនុស្ស និងភពផែនដីរបស់យើងៗ សម្រាប់ខ្ញុំ ដើមឈើគឺជាដង្ហើមនៃជីវិតៗ ដូច្នេះការស្រឡាញ់ធម្មជាតិក៏ដូចជាការស្រឡាញ់ខ្លួនឯងដែរៗ

ខ្ញុំពិតជាមានការព្រួយបារម្ភ ចំពោះប្រជាជនដែលរស់នៅពឹងផ្អែកទៅលើការធ្វើកសិកម្មៗ នៅពេលដែលព្រៃឈើត្រូវបានបំផ្លិចបំផ្លាញពីមួយថ្ងៃទៅមួយថ្ងៃអាចបណ្តាលឲ្យមានគ្រោះរាំងស្ងួត និងភ្លៀងធ្លាក់មិនទៀងទាត់ដែលនឹងផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការធ្វើស្រែចម្ការរបស់ប្រជាជនៗ ការបាត់បង់ព្រៃឈើអាចបន្តឲ្យកើតមានគ្រោះធម្មជាតិផ្សេងៗៗ

ខ្សែភាពយន្តឯកសាររឿង« ឆ្មាំព្រៃបានធ្វើឲ្យខ្ញុំរំភើបយ៉ាងខ្លាំង នៅពេលដែលខ្ញុំបានឃើញសត្វព្រៃផ្សេងទៀតដែលខ្ញុំមិនធ្លាប់ស្គាល់ពីមុនមកនិងព្រៃឈើជាច្រើន ដែលខ្ញុំតែងតែគិតថា បានបាត់បង់អស់ទៅហើយៗ ខ្សែភាពយន្តឯកសារនេះក៏បានប្រាប់ខ្ញុំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផលលំបាកបន្ទាប់ពីសង្គ្រាមបានបញ្ចប់ៗ

ខ្ញុំមានក្តីស្រមៃចង់ក្លាយជាអ្នកអភិរក្ស ធនធានធម្មជាតិម្នាក់ហើយខ្ញុំសង្ឃឹមថា ខ្សែភាពយន្តឯកសាររឿង «ឆ្មាំព្រៃ» នឹងលើកទឹកចិត្តមនុស្សគ្រប់រូបឲ្យស្រឡាញ់ និងការពារធនធានធម្មជាតិឲ្យនៅគង់វង្សៗ **អ៊ុន សុដាវី**

# នួន ជា ជានរណា?

នួន ជា មានឈ្មោះដើម ឡៅ គឹមរ៉ន ក្រោយមកបានប្តូរទៅជា ឡៅឌី ដែលប្រជាជនស្គាល់ជាទូទៅថានួនជា ប៉ុន្តែគាត់មានឈ្មោះហៅម្យ៉ាងទៀតហៅថាក្តុច គឺជាឈ្មោះដែលម្តាយរបស់គាត់ស្រឡាញ់បំផុត។ នួន ជាកើតថ្ងៃទី៧ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរស្រុកសង្កែខេត្តបាត់ដំបង ។នួនជាគឺជាកូនទីពីក្នុងចំណោមបងប្អូន៩នាក់។

នួន ជា គឺជាអ្នកទោសប្រវត្តិសាស្ត្រ ដែលបានចូលរួមចំណែកបង្កឲ្យប្រជាជនកម្ពុជាជាង២ លាននាក់បាត់បង់ជីវិតនិងបំផ្លាញប្រទេសកម្ពុជាស្ទើរតែទាំងស្រុង។ មនុស្សភាគច្រើនស្គាល់នួនជាថាគឺជាបងធំទី២ ឬជាមេដឹកនាំទី២ បន្ទាប់ពី ប៉ុល ពត នៅក្នុងអំឡុងនៃរបបខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩។ នួនជាគឺជាថ្នាក់ដឹកនាំស្ថាប័នកំពូលមួយរូប បានដឹកនាំប្រទេសឲ្យធ្លាក់ចូលក្នុងភាពអន្តរាយថែមទាំងបាន ចូលរួមប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនមកលើប្រជាជនស្លូតត្រង់និងបានបន្សល់ទុកនូវភាពឈឺចាប់រាប់មិនអស់ដល់ជនរងគ្រោះ ដែលនៅរស់រានមានជីវិតរហូតដល់បច្ចុប្បន្ន។

នួន ជា ស្ថិតក្នុងវ័យ ៩៣ ឆ្នាំ មានសម្បុរសនិងជាប់ខ្សែស្រឡាយជាជនជាតិចិនដែលជារឿយៗគាត់បានបង្ហាញវត្តមាន នៅក្នុងបន្ទប់សវនាការនៃតុលាការខ្មែរក្រហម ដោយស្លៀកសម្លៀកបំពាក់សមរម្យនិងពាក់វ៉ែនតាពណ៌ខ្មៅ ហើយអង្គុយនៅចំពីខាងមុខកុំព្យូទ័រនិងឧបករណ៍បំពងសម្លេង ថែមទាំងមានសន្តិសុខអង្គុយក្បែរ ដើម្បីជួយសម្រួលដល់ការធ្វើកាយវិការ ដោយសារតែគាត់ស្ថិតក្នុងភាពជរា។ រូបភាពរបស់ នួន ជា ភាគច្រើនត្រូវបានបង្ហាញនៅក្នុងទូរទស្សន៍ ប្រព័ន្ធអ៊ីនធឺណែតថែមទាំងមាននៅលើការសែតទាំងក្នុងប្រទេសនិងអន្តរជាតិដែរ។

តុលាការខ្មែរក្រហមបានសម្រេចចាប់ឃុំខ្លួន នួន ជា ជាបណ្តោះអាសន្ននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដោយ



រូបទី១រាប់ពីស្តាំ (ជួរខាងមុខ) ៖ ស៊ិន ជា
រូបទី២រាប់ពីស្តាំ (ជួរខាងមុខ) ៖ នួន ជា
រូបទី៣រាប់ពីស្តាំ (ជួរខាងមុខ) ៖ នី កន សមាជិកគណៈតំបន់៣២

សារតែគាត់ គឺជាអតីតមេដឹកនាំកំពូលម្នាក់នៅក្នុងរបបខ្មែរក្រហម ដែលមានតួនាទីជាអតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។

បន្ទាប់មក នួន ជា ត្រូវបានក្លាយជាជនជាប់ចោទក្នុងសំណុំ រឿង០០២ ជាមួយនឹងមេដឹកនាំខ្មែរក្រហម៣រូបផ្សេងទៀត គឺ ខៀវ សំផន អៀង សារី និងអៀង ធីរិទ្ធដោយត្រូវបានតុលាការចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា ទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមនិងវៀតណាម។ ប៉ុន្តែដោយសារតែជនជាប់ចោទ ២នាក់គឺអៀងសារីនិងអៀងធីរិទ្ធបានស្លាប់មុនពេលសម្រេចទោស ទើបសំណុំរឿង០០២នេះនៅសល់តែជនជាប់ចោទតែ ២នាក់ប៉ុណ្ណោះគឺ នួន ជា និងខៀវ សំផន។

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការជាបឋមនៅខែមិថុនា ឆ្នាំ២០១១ ហើយមិនយូរប៉ុន្មានសំណុំរឿង០០២ក៏ត្រូវបានបំបែកជាសំណុំរឿងពីរផ្សេងគ្នាគឺសំណុំរឿង០០២/០១ និង ០០២/០២។ ការបំបែកសំណុំរឿង០០២នេះ ពីព្រោះតែទំហំនិងបញ្ហាស្មុគស្មាញនៃដីកាដំណោះស្រាយនិងវ័យចាស់ជរារបស់ជនជាប់ចោទ។

សំណុំរឿង០០២/០១ ត្រូវបានចាប់ផ្តើមបើកសវនាការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានជនជាប់ចោទតែ២រូបគឺនួន ជា និងខៀវ សំផន។ សំណុំរឿងនេះផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដោយបង្ខំចេញពីទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ និងការផ្លាស់ទីលំនៅដំណាក់កាល ទី២ ក្នុងតំបន់ផ្សេងៗទៀតចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥។ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន ត្រូវបានអង្គជម្រះសាលាដំបូងរកឃើញថា មានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ចំណែកឯសវនាការជំនុំជម្រះលើសំណុំរឿង០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ។ សំណុំរឿង ០០២/០២ គឺសំដៅលើការជំនុំជម្រះដំណាក់កាលទី២ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ដែលត្រូវជំនុំជម្រះទៅលើបទចោទចំនួនករណីផ្សេងបន្ថែមទៀតលើសំណុំរឿង ០០២/០២ ដូចជា៖

១) អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម

២) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ(នៅទូទាំងប្រទេស)

៣) ការបោសសម្អាតផ្ទៃក្នុង

៤) មន្ទីរសន្តិសុខ ស-២១មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល

៥) ការដ្ឋានសាងសង់ទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្ម

៦) សហករណ៍ត្រាំកក់

៧) ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន(កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និង

៨) ការកំណត់គោលដៅមកលើអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុណ្ណោះ)។ បន្ទាប់ពីចំណាយអស់រយៈពេលប្រហែល៤ឆ្នាំ ក្នុងការជំនុំជម្រះចំពោះសំណុំរឿង០០២/០២ ដែលសំដៅទៅលើការជំនុំជម្រះលើដំណាក់កាលទី២ប្រឆាំងនឹងជនជាប់ចោទ២រូបគឺនួន ជា និងខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការខ្មែរក្រហមបានសម្រេចកំណត់យកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺជាថ្ងៃ ប្រកាសសាលក្រមសម្រាប់សំណុំរឿង០០២/០២។ អង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យល់ឃើញថា នួន ជាត្រូវតែទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំម្នាក់នៅក្នុង

របបខ្មែរក្រហម ដែលបានប្រព្រឹត្តតាមគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ នួន ជា ត្រូវបានអង្គជំនុំជម្រះសាលាដំបូងនៃតុលាការខ្មែរក្រហមរកឃើញថា មានពិរុទ្ធចំពោះបទចោទចំនួន៣ ក្នុងចំណោមបទចោទទាំង៨ គឺ១) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ២)ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ៣)ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ជាចុងក្រោយអង្គជំនុំ ជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ នួន ជា ដោយសម្រេចរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរក្នុងករណី០០២/០១ និង០០២/០២ ដោយដាក់ពន្ធនាគារអស់មួយជីវិតតែមួយ ក្រោយពិចារណាទៅលើការផ្តន្ទាទោសដាក់គុកអស់មួយជី វិតចំពោះគាត់នៅក្នុងសំណុំរឿង០០២/០១។ ទោះបីជា នួន ជា គឺជាឧក្រិដ្ឋជនក៏ដោយ ប៉ុន្តែគាត់ត្រូវបានមើលថែរក្សាយ៉ាងយកចិត្តទុកដាក់ពីគ្រូពេទ្យជំនាញរហូតដល់គាត់បានស្លាប់ ដោយសារជំងឺនៅមន្ទីរពេទ្យរុស្ស៊ីវេលាល្ងាចថ្ងៃ៤ទី ខែសីហា ឆ្នាំ២០១៩។

ខាងក្រោមនេះគឺជារឿងរ៉ាវដែលទាក់ទងនឹងខ្សែជីវិតរបស់នួនជារួមមានការសិក្សាអប់រំការងារក្រុមគ្រួសារការចូលរួមចំណែកក្នុងអំពើឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហម៖

រឿងរ៉ាវរបស់ នួន ជា និងក្រុមគ្រួសារឪពុករបស់ នួន ជា ឈ្មោះ ឡៅ លីវ និងម្តាយឈ្មោះ ដុស ពាញ។ឪពុករបស់គាត់គឺជាអាជីវករជួញដូរដាំពោត និងប្រកបអាជីវកម្មផ្សេងៗទៀត។ ចំណែកឯម្តាយរបស់គាត់វិញ គឺជាជាងកាត់ដេរ និងធ្វើជួយការងារឪពុករបស់គាត់ដែរ។ ក្រុមគ្រួសាររបស់នួនជាគឺជា ក្រុមគ្រួសារដែលមានជីវភាពធូរធា ប៉ុន្តែក្រុមគ្រួសារគាត់ ក៏បានធ្លាក់ខ្លួនជំពាក់បំណុលយ៉ាងច្រើនបន្ទាប់ពីសេដ្ឋកិច្ច បានធ្លាក់ចុះក្រោយសង្គ្រាមលោកលើកទី១។

ជីតារបស់ នួន ជា គឺជាចិនទាជីវមកពីសានតូនៃប្រទេសចិន ចំណែកឯជីដូនរបស់គាត់វិញគឺជាជនជាតិខ្មែរ។ ដោយសារតែមានឈាមជ័រជាចិនផងនិងខ្មែរផង នួន ជាត្រូវបានចិញ្ចឹមបីបាច់នៅក្នុងគ្រួសារចម្រុះវប្បធម៌ និងប្រើប្រាស់ភាសាខ្មែរក្នុងការប្រាស្រ័យទាក់ទងគ្នា។ រាល់រដូវបុណ្យសាសនារបស់ប្រទេសទាំងពីរម្តងៗ ក្រុមគ្រួសាររបស់គាត់តែងតែរៀបចំសែនព្រេនទៅតាម ប្រពៃណីទំនៀមទម្លាប់របស់ប្រទេសនីមួយៗ។ នៅពេលបុណ្យសំពះព្រះខែឬបុណ្យឆេងម៉េង ក្រុមគ្រួសាររបស់ នួន ជា បានបន់ស្រន់តាមបែបចិនថ្វាយដល់ដូនតារបស់គាត់ ហើយក្រុមគ្រួសារ របស់គាត់ក៏បានគោរពបូជាព្រះពុទ្ធសាសនា និងសែនព្រេនទៅតាមទំនៀមទម្លាប់ខ្មែរដែរ។ នួន ជា បានរៀនភាសាចិន តិចតួចបំផុតទោះបីជាគាត់មានខ្សែស្រឡាយជាជនជនចិនក៏ដោយ។

នួន ជា បានរៀបការជាមួយ លី គឹមសេង ដែលមានស្រុកកំណើតនៅក្នុងខេត្តកំពង់ឆ្នាំង និងជាប់ខ្សែស្រឡាយជាជនជាតិចិនដែរ។ គាត់មានកូនចំនួន៤នាក់ ដោយកូនចំនួន៣នាក់ជាកូនបង្កើតនិង១នាក់គឺជាកូនចិញ្ចឹម។ នៅក្នុងរបបខ្មែរក្រហម នួន ជា ត្រូវបានគេហៅឈ្មោះខុសៗគ្នាដោយប្រើនាមត្រកូលរបស់គាត់ នួន ហៅថា បង នួន ឬ អ៊ំនួន រីឯអ្នកខ្លះទៀតហៅគាត់ថា តាប្រហុក ព្រោះគាត់ចូលចិត្តហូបប្រហុក។ បន្ទាប់ពីរបបខ្មែរក្រហម នួន ជា ត្រូវបានគេស្គាល់ថា ជាបងធំទី២ ឬជាឧក្រិដ្ឋជននៅក្នុងរបបខ្មែរក្រហម។ ប្រវត្តិនៃការសិក្សារបស់ នួន ជា

នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងដោយប្រទេសថៃ។ ក្នុងចំណោមខេត្តទាំងនោះ ខេត្តបាត់ដំបងក៏ជាខេត្តមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ថៃដែរ។ ប្រជាជននៅក្នុងខេត្តបាត់ដំបងនាពេលនោះ ត្រូវបានរដ្ឋាភិបាលថៃផ្តល់ សញ្ជាតិជាជនជាតិថៃឲ្យដោយស្វ័យប្រវត្តិ។ នួន ជា ក៏បានទទួលសញ្ជាតិថៃដែរ។ ក្នុងកំឡុងពេលនោះ នួន ជា មានអាយុប្រហែល១៥ឆ្នាំតែប៉ុណ្ណោះ ហើយគាត់ក៏មិនសូវបានចាប់អារម្មណ៍នឹងព្រឹត្តិការណ៍ដែលបានកើតឡើង នៅក្នុងប្រទេសកម្ពុជាដែរ។ បន្ទាប់ពី នួន ជា បានបញ្ចប់សាលាមធ្យមសិក្សានៅក្នុងខេត្តបាត់ដំបងគាត់ក៏បានចាកចេញទៅទីក្រុង

បាងកក ប្រទេសថៃ ដើម្បីរស់នៅនិងបន្តការសិក្សារបស់គាត់។ នៅពេលទៅដល់ប្រទេសថៃ នួន ជា បានរស់នៅជាមួយព្រះសង្ឃ នៅក្នុងវត្តបិនចាម៉ាបូភីត ដែលព្រះសង្ឃទាំងនោះក៏បានធ្វើដំណើរមកពីខេត្តបាត់ដំបងដូច នួន ជា ដែរ។ នួន ជា បានរស់នៅក្រោមការមើលថែរក្សារបស់ព្រះសង្ឃទាំង៣អង្គនោះ បន្ទាប់មកក៏បានចុះឈ្មោះចូលរៀននៅក្នុងសាលាមធ្យមសិក្សារបស់រដ្ឋាភិបាលថៃ ដែលមានឈ្មោះថា



រូបទី១រាប់ពីខាងឆ្វេង ៖ ប៉ុល ពត ជានាយករដ្ឋមន្ត្រី និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា
រូបទី២រាប់ពីខាងឆ្វេង ៖ នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា
រូបទី៣រាប់ពីខាងឆ្វេង ៖ អៀង សារី ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស
រូបទី៤រាប់ពីខាងឆ្វេង ៖ សុន សេន ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
រូបទី៥រាប់ពីខាងឆ្វេង (ឈរពីក្រោយ សុន សេន) ៖ វ៉ន វេត ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

សាលាវត្តបិនចាម៉ាបូភីត ដែលស្ថិតនៅក្នុងបរិវេណវត្តដែលគាត់បានរស់នៅក្នុងកំឡុងពេលនោះ។ នួន ជាបានចាប់ផ្តើមការសិក្សារបស់គាត់ត្រឹមកម្រិតថ្នាក់មធ្យមឆ្នាំទី៥ និងទី៦ ដែលការសិក្សានេះជាជំហានទូទៅរបស់សិស្សនីមួយៗដែលមានបំណងចង់បន្តការសិក្សារបស់ខ្លួន សម្រាប់ថ្នាក់ត្រៀមចូលសាកលវិទ្យាល័យ។

នៅពេលចាប់ផ្តើមចូលសិក្សានៅសាលា នួន ជា បានប្រើឈ្មោះរបស់គាត់ជាភាសាថៃថា “រុងឡឺត ឡៅខី”។ នួន ជាបានសិក្សានៅក្នុងសាលានោះអស់រយៈពេល២ឆ្នាំ គឺចន្លោះឆ្នាំ១៩៨២ ដល់១៩៨៣ ដោយបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សានៅដើមឆ្នាំ១៩៨៤។ នួន ជា បានទទួលការឧបត្ថម្ភពីឪពុករបស់គាត់ រាល់ការចំណាយលើការរស់នៅនិងការសិក្សានៅក្នុងប្រទេសថៃ។

មិនយូរប៉ុន្មាន នួន ជា ក៏បានចុះឈ្មោះចូលសិក្សាថ្នាក់ទី៧ សម្រាប់វគ្គត្រៀមនៅសាកលវិទ្យាល័យធម្មាសាធ និងបញ្ចប់ការសិក្សាសម្រាប់វគ្គនេះនៅឆ្នាំ១៩៨៦ ជាមួយលទ្ធផលល្អប្រសើរ។ នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៨៦ នួន ជា ក៏បានចុះឈ្មោះចូលរៀនផ្នែកច្បាប់នៅសាកលវិទ្យាល័យធម្មាសាធ។ ការសិក្សារបស់ នួន ជា លើមុខវិជ្ជាច្បាប់របស់គាត់មិនសូវទទួលបានលទ្ធផលល្អទេ ព្រោះគាត់តែងតែប្រឡងធ្លាក់មុខវិជ្ជាមួយចំនួន។ មូលហេតុនៃការធ្លាក់ចុះខ្សោយនៃការសិក្សារបស់គាត់ អាចថាគាត់មិនសូវមានពេលវេលាសម្រាប់ការសិក្សា ដោយសារតែគាត់បានចូលប្រ

លូកក្នុងកិច្ចការនយោបាយ និងបម្រើការងារផ្សេងៗនៅក្នុងប្រទេសថៃក្នុងកំឡុងពេលដែលគាត់កំពុងតែសិក្សា។

ចុងក្រោយ នួន ជា បានបោះបង់ទាំងការងារនៅក្នុងប្រទេសថៃ និងការសិក្សានៅសាកលវិទ្យាល័យធម្មសាធ ហើយ ត្រឡប់មកចូលរួមធ្វើកិច្ចការនយោបាយនៅក្នុងប្រទេសកម្ពុជាវិញនៅកំឡុងឆ្នាំ១៩៥០។ ប្រវត្តិការងាររបស់ នួន ជា មុនឆ្នាំ១៩៧៥នួន ជា បានចាប់ផ្តើមចូលក្នុងកិច្ចការងារនយោបាយយ៉ាងសកម្មចាប់តាំងពីឆ្នាំ១៩៤០ នៅពេលដែលគាត់បានទៅរស់នៅក្នុងប្រទេសថៃ។ ក្នុងអំឡុងពេលរស់នៅទីនោះ នួន ជា បានចូលរួមក្នុងអង្គការយុវជនថៃដែលជាអង្គការមួយស្ថិតនៅក្រោម បក្សកុម្មុយនីស្ត និងជាទីកន្លែងមួយដែលបុរស និងស្ត្រីវ័យក្មេងៗប្រមូលផ្តុំគ្នាដើម្បីធ្វើសកម្មភាពសង្គមជួយគ្នាទៅវិញទៅមក ព្រមទាំងធ្វើការផ្លាស់ប្តូរទស្សនយោបល់រួមៗ វង់ផាន គឺជាអតីតសិស្សនៃសាកលវិទ្យាល័យធម្មសាធនិងជាអ្នកដែលធ្លាប់បានរស់នៅជាមួយ នួន ជា ក្នុងបន្ទប់ជួលជាមួយគ្នា គឺជាអ្នកអញ្ជើញ នួន ជា ឲ្យចូលរួមក្នុងអង្គការយុវជនថៃ រហូតបានក្លាយជាសមាជិកបក្សកុម្មុយនីស្តថៃ។

ក្រៅពីការងារនេះ នួន ជា ក៏បានបម្រើការងារជាមន្ត្រីរដ្ឋាភិបាលថៃធម្មតាម្នាក់ ដែលមានតួនាទីជាស្មៀននៅក្នុងការិយាល័យគណនេយ្យ ក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅរបស់ក្រសួងហិរញ្ញវត្ថុថៃនៅចុងឆ្នាំ១៩៤៧។ ក្រោយមក នួន ជាបានប្រឡងជាប់ធ្វើការងារនៅក្នុងក្រសួងការបរទេសថៃ ហើយបានលាឈប់ពីការងារនៅក្នុងក្រសួងហិរញ្ញវត្ថុ។ រយៈពេលប្រហែល១ខែប៉ុណ្ណោះ បន្ទាប់ពី នួន ជា បានបំពេញការងារនៅក្រសួងការបរទេសថៃ គាត់ក៏បានលាឈប់ ដែលនៅពេលនោះ គាត់ក៏បានបោះបង់ចោលការសិក្សានៅសាកលវិទ្យាល័យធម្មសាធដែរ។ ក្រោយមក នួន ជា បានផ្ទេរសមាជិកភាពរបស់គាត់ពី សមាជិកបក្សកុម្មុយនីស្តថៃទៅជាបក្សកុម្មុយនីស្តឥណ្ឌូចិន ដើម្បីត្រឡប់មកប្រទេសកម្ពុជាវិញសម្រាប់ចូលរួមក្នុងការតស៊ូប្រឆាំងនឹង បារាំងដែលកំពុងតែដាក់អាណានិគមនៅក្នុងប្រទេសកម្ពុជា។



នួន ជា និង គណៈប្រតិភូបរទេស

បន្ទាប់ពីប្រឡូកក្នុងវិស័យនយោបាយនៅក្នុងប្រទេសថៃ នួន ជាបានត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីចូលរួមក្នុងចលនាតស៊ូរបស់បក្សកុម្មុនីស្ត ដោយទទួលបន្ទុកខាងឃោសនាបក្សក្នុងឆ្នាំ១៩៥០។ នៅក្នុងឆ្នាំ១៩៥៩ ទូ សាមុត នួន ជា និង ប៉ុល ពត បានចាប់ផ្តើមដំណើរការបង្កើតបក្សកុម្មុយនីស្តថ្មីមួយ ដែលគោលការបក្សនេះគឺប្រជាធិបតេយ្យប្រមូលផ្តុំ និងម៉ាក្សលេនីននិយម។ នៅក្នុងពេលចូលរួមក្នុងចលនាតស៊ូរបស់បក្សកុម្មុយនីស្ត នួន ជា បាន ទាក់ទងយ៉ាងសកម្មជាមួយពួកកុម្មុយនីស្តវៀតណាម និងចលនាខ្មែរឥស្សរៈ។ នួន ជា ក៏បានទៅសិក្សាវគ្គនយោបាយនៅភាគខាងត្បូង និងភាគខាងជើងនៃប្រទេសវៀតណាមដែរ។ ទោះបីជាមានការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជាក៏ នួន ជា នៅតែជាសមាជិកក្នុងចលនាកុម្មុនីស្តដដែល។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ នួន ជា ត្រូវបានជ្រើសរើសជា អនុលេខាបក្សប្រជាជនបដិវត្តន៍កម្ពុជាដែលក្រោយមកបានប្តូរឈ្មោះថា បក្សពលករកម្ពុជា និងបន្ទាប់មកទៀតប្តូរទៅជាឈ្មោះបក្សកុម្មុនីស្តកម្ពុជាជាមួយ សាឡុត ស និង ទូ សាមុត។ ប៉ុន្តែបន្ទាប់ពីបាត់ខ្លួន ទូ សាមុត នៅក្នុងឆ្នាំ១៩៦២ នួនជានៅតែកាន់តំណែងជាអនុលេខាបក្សដែលនៅពេលនោះ ប៉ុល ពត បានក្លាយជាលេខាបក្ស និងប្រលូកក្នុងវិស័យនយោបាយរហូតដល់ដណ្តើមបានជ័យជម្នះពី លន់ នល់ និងឡើងកាន់កាប់អំណាចនៅក្នុងឆ្នាំ១៩៧៥។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ នៅក្នុងឆ្នាំ១៩៧០ នួន ជា បានចាកចេញពីទីក្រុងភ្នំពេញដើម្បីចូលរួមចលនាព្រៃម៉ាគីជាមួយមេដឹកនាំបក្សបក្សកុម្មុយនីស្តកម្ពុជា ដូចជា ប៉ុល ពត សុន សេន តា ម៉ុក និង សោ ភឹម ដោយបានបង្កើតទីស្នាក់ការកណ្តាលរបស់ខ្លួននៅតាមខេត្ត មួយចំនួនដូចជា ខេត្តកំពង់ធំ ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង។ នៅរវាងឆ្នាំ១៩៧០ ដល់១៩៧៥ នួន ជា បានក្លាយជាអនុបញ្ជាការយោធាជាន់ខ្ពស់កងទ័ពប្រជាជន នៃចលនារំដោះជាតិកម្ពុជា និងជាប្រធានផ្នែកនយោបាយរបស់កងទ័ពហើយ ថែមទាំងទទួលបន្ទុកក្នុងការទំនាក់ទំនងជាមួយវៀតណាម។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)នៅកំឡុងខែមេសា ឆ្នាំ១៩៧៥ នួន ជា នៅជាមួយ ប៉ុល ពត និងមេដឹកនាំយោធា និងនយោបាយសំខាន់ៗមួយចំនួនទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា កុយ ធួន សោភឹម តាម៉ុក និង សុន សេន ដើម្បីដឹកនាំកម្លាំងវាយកាន់កាប់ទីក្រុងភ្នំពេញ។ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះ និងកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង ប្រជាជនទាំងអស់ត្រូវបាន ខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែងដោយបង្ខំ។ ប្រជាជនខ្លះបានស្លាប់នៅតាមផ្លូវ រីឯអ្នកខ្លះទៀតត្រូវបានបែកពីក្រុមគ្រួសាររបស់ខ្លួន។ នួន ជា ត្រូវបានប្រជាជនស្គាល់ថា ជាបងធំទី២ បន្ទាប់ពី ប៉ុល ពត ដែលមានតួនាទីជាអនុលេខាបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិនៃគណកម្មាធិការមជ្ឈិម និងជាគណកម្មាធិការ អចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាជាសភាតំណាងឲ្យប្រជាជនថែមទាំងពេលខ្លះជានាយករដ្ឋមន្ត្រីស្តីទី នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

ក្នុងឋានៈជាអនុលេខាមជ្ឈិមបក្សនួន ជាគឺជាមនុស្សទីនៅក្នុងឋានានុក្រមបក្សនិងត្រូវបានស្គាល់ថា ជាបងធំទី២ និងជាដៃស្តាំរបស់ ប៉ុល ពត។ ក្នុងនាមជា សមាជិកពេញសិទ្ធិ នួន ជា អាចពិគ្រោះយោបល់ និងរួមមតិសម្រេចពាក់ព័ន្ធនឹងបញ្ហាទាំងអស់។ ចំពោះតួនាទីជា សមាជិកគណអចិន្ត្រៃយ៍ និងជាសមាជិកគណមជ្ឈិម នួន ជា បានចូលរួមប្រជុំកម្រិតខ្ពស់នានារបស់បក្សកុម្មុយនីស្តកម្ពុជាជាទៀងទាត់ ដែលធ្វើជាប្រចាំនៅមន្ទីរក-១និងមន្ទីរក-៣ និងថែមទាំងបានជួបប្រជុំប្រចាំខែនៅមន្ទីរក-១ ជាមួយនឹងកម្មាភិបាលថ្នាក់ដឹកនាំមកពីបណ្តាភូមិភាគតំបន់ ព្រមទាំងគណស្រុកដែរ។ នួន ជា ក៏បានជួបជាញឹកញាប់នៅក្រៅទីក្រុងភ្នំពេញជាមួយមេដឹកនាំស្វយ័ត និងមេដឹកនាំភូមិភាគជាពិសេសនៅពេលសន្និបាតតាមតំបន់ និងភូមិភាគ។ **អ៊ុន សុដាវី**

# សៀវភៅប្រវត្តិសាស្ត្រដែលបកប្រែជាខេមរភាសាដំបូង «បូជាភ្លើង»

ពាក្យ «ហូឡូខសត៍» ត្រូវបានអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាច្រើនបានលើកមកបកស្រាយខុសៗគ្នា។ នៅសតវត្សរ៍ទី៥ ពាក្យ «ហូឡូខសត៍» ត្រូវបានរកឃើញនៅក្នុងគម្ពីរសាសនាផ្សេងៗ ដែលមានន័យថាបូជាដោយភ្លើងចំពោះ «ព្រះ»។ នៅឆ្នាំ១៩៤១ពាក្យ «ហូឡូខសត៍» គឺជាការសម្លាប់រង្គាលនៅអឺរ៉ុបជាលើកដំបូងហើយភាសាក្រិចដែលមានន័យថា «បូជាដោយភ្លើង» ឬ «បូជាភ្លើង»។

« សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប» នេះគឺជាប្រយោគដែលបានលើកឡើងនៅក្នុងសៀវភៅ «បូជាភ្លើង» ដែលមជ្ឈមណ្ឌលឯសារកម្ពុជាបានបកប្រែចេញពីសៀវភៅសរសេរជា ភាសាអង់គ្លេសរបស់អាលីស អ៊ី អ៊ុលស៊ុន ដែលបានបកប្រែចេញពីសៀវភៅដើមជាភាសា ស៊ុយអែត។ សៀវភៅនេះបានរៀបរាប់អំពីកំណត់ត្រាសំណួររបស់យុវជនជាច្រើនរយនាក់ដែលបានសួរមក កាន់លោកស្រី ហេឌី ហ្វ្រាយគឺជាអ្នកនិពន្ធ និងអ្នកចិត្តវិទូ និងជាអ្នករស់រានមានជីវិតអំពីការសម្លាប់រង្គាលនៅអឺរ៉ុប។


លោក អេនទ្រី ណេលសុន តំណាងស្ថានទូតស៊ុតអែត ប្រចាំប្រទេសកម្ពុជា

សៀវភៅ «បូជាភ្លើង» ក៏មានសទ្ទានុក្រមដែលបានពន្យល់ពាក្យគន្លឹះសំខាន់ៗ ដើម្បីធ្វើឲ្យអ្នកអានងាយស្រួលយល់អំពីតំបន់នៃព្រឹត្តិការណ៍ និងអំពើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងសង្គ្រាមលោកលើកទី២(ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៥) ដែរ។ សៀវភៅ «បូជាភ្លើង» នេះត្រូវបានចេញផ្សាយជាលើកដំបូងនៅក្នុងឆ្នាំ២០១៧ ជាភាសា ស៊ុយអែត និងពីរឆ្នាំបន្ទាប់មក ស្នាដៃរបស់លោក ស្រី ហេឌី ហ្វ្រាយ ត្រូវបានបកប្រែទៅជាភាសាអង់គ្លេស។

សៀវភៅ «បូជាភ្លើង» ត្រូវបានសម្ពោធនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ, លោក អេនទ្រី ណេលសុន តំណាងស្ថានទូតស៊ុតអែត ប្រចាំប្រទេសកម្ពុជា, លោក ហ្សង ម៉ាក តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ, លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោកគ្រូ-អ្នកគ្រូ គរុសិស្ស និងនិស្សិតជាច្រើនរូបទៀត។ ការសម្ពោធសៀវភៅ « បូជាភ្លើង» នេះមានគោលបំណងដើម្បីរំឭកទៅដល់របបខ្មែរក្រហមដែលបានដួលរលំអស់រយៈពេល៤០ឆ្នាំ និងស្របពេលជាមួយគ្នានឹងការបិទបញ្ចប់នៃការសម្លាប់រង្គាល, ការដាក់ទណ្ឌ កម្មចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ដែលត្រូវបានអនុម័ត ព្រមទាំងផ្តល់សច្ចាប័នដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨។

នៅក្នុងសៀវភៅនេះ ហេឌី ហ្វាយ្រ បានចែករំលែករឿងរ៉ាវរបស់ខ្លួន តាមរយៈការបង្រៀនទៅកាន់សិស្សានុសិស្សដោយផ្តោតសំខាន់ទៅលើពាចំណុចៈ ១) លោកស្រីបានចាប់ផ្តើម ពីការព្យាយាមបង្ហាញអំពីមនុស្សរស់នៅអតីត កាលដែលជាចំណែកមួយ ធ្វើឱ្យណាហ្ស៊ីស្អប់ជនជាតិជ្វីហ្វ ២) ការចែករំលែកបទពិសោធន៍ជីវិត ៣) ការអនុញ្ញាតឲ្យមានការសួរសំណួរបើកទូលាយ ក្រោយពីបញ្ចប់ការបង្រៀន។ សំណួរមួយចំនួនដែលយុវជនទូទាំងពិភពលោកមានការងឿងឆ្ងល់ហើយបានលើកឡើងនៅក្នុងសៀវភៅនេះគឺ ៖ តើហេតុអ្វីបានជាហ៊ីត្លែរស្អប់ជនជាតិជ្វីហ្វ? តើប្រជាជនអាល្លឺម៉ង់ទាំងអស់គាំទ្រហ៊ីត្លែរដោយរបៀបណា? ហេតុអ្វីបានជាអ្នកមិនប្រឆាំងតបវិញ? តើអ្វីដែលបានជួយឲ្យអ្នករួចជីវិត? តើអ្នកដឹងនៅពេលណាថាអំពើប្រល័យពូជសាសន៍បានកើតឡើង? តើអ្នកដោះស្រាយជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តបានដោយរបៀបណា? តើអ្វីដែលជំរុញឲ្យអ្នកចាប់ផ្តើមបង្រៀន? តើអ្នកស្អប់ជនជាតិអាល្លឺម៉ង់ដែរឬទេ? តើអ្នកអាចអត់ទោសបានដែរឬទេ? តើសាលារៀនអាចជួយយើងឲ្យជៀសផុតពីរឿងដែលស្រដៀងនេះបានយ៉ាងដូចម្តេច? តើយើងអាចរៀនសូត្របានអ្វីខ្លះអំពីហូឡូខស្ត? តើអ្វីៗអាចនឹងកើតឡើងម្តងទៀតដែរឬទេ?

នៅដើមទសវត្សរ៍ទី២០ ជនជាតិជ្វីហ្វត្រូវបានបញ្ជូនតាមរទេះភ្លើងទៅកាន់ជំរំអូសឈ្វិច ដែលជាជំរំប្រមូលផ្តុំដ៏ធំជាងគេរបស់ណាហ្ស៊ី។ គ្រួសាររបស់ ហេឌី ហ្វ្រាយ និងប្រជាជនផ្សេងទៀតប្រមាណជា ៣.០០៧នាក់ ក៏ត្រូវបានបញ្ជូនទៅកាន់ជំរំអូសឈ្វិចដែរ។ ក្រោយមកប្រជាជនត្រូវបានបំបែកចេញពីគ្រួសារជាទីស្រឡាញ់។ ម្តាយឪពុករបស់ ហេឌី ហ្វាយ្រ ត្រូវបានណាហ្ស៊ីបោកបញ្ឆោតឲ្យទៅងូតទឹក ប៉ុន្តែដោយជំនួសឲ្យការងូតទឹក គាត់ត្រូវបានឃុំនៅក្នុងបន្ទប់ផ្សែងពុលដែលមានសារធាតុគីមី ហ្ស៊ីក្លូប៊ី។ ណាហ្ស៊ីបានប្រើវិធីសាស្ត្រក្នុងការសម្លាប់បែបនេះ ក្នុងគោលបំណងធ្វើយ៉ាងណាសម្លាប់ជនជាតិជ្វីហ្វឲ្យបានច្រើន ចំណេញពេលវេលា និងកាត់បន្ថយការចំណាយ។

ដោយឡែកប្រទេសកម្ពុជាអំពើសម្លាប់យ៉ាងសាហាវយង់ឃ្នង បានកើតឡើងនៅចុងសតវត្សរ៍ទី២០ គឺមានរយៈ៣០ឆ្នាំបន្ទាប់ពីការកើតឡើង«ហូឡូខស្ត»។ ជនរងគ្រោះដែលនៅរស់រានមានជីវិតអំពីរបបខ្មែរក្រហមបានចែករំលែកបទពិសោធន៍របស់ខ្លួន និងការចងចាំមកកាន់មនុស្សជំនាន់ក្រោយតាមរយៈការអប់រំនៅក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។ ទោះបីជាយ៉ាងនេះក្តីក្រោយរបបកម្ពុជាធិបតេយ្យដួលរលំ យន្តការនៃការផ្សះផ្សាជាតិក៏ត្រូវបានរៀបចំ


លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

ឡើងជាបន្តបន្ទាប់ ខណៈដែលការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៅតែជាតម្រូវការចាំបាច់ រហូតដល់មានការបង្កើតឡើងនូវតុលាការអន្តរជាតិ ដើម្បីកាត់ទោសមេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមទាំងនេះត្រូវបានកត់ត្រាទុក ហើយក៏គួរត្រូវបានចាំចងចាំនិងបង្រៀនដល់មនុស្សជំនាន់ក្រោយដែរ។

លោកជំទាវ ទន់ សាអ៊ីមអនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡាបានមានប្រសាសន៍នៅក្នុងថ្ងៃសម្ពោធសៀវភៅ «បូជាភ្លើង» ថា «យើងគួរតែចងចាំពីអ្វីដែលជាអតីតកាល ហើយដោយសារតែមានការចងចាំរបស់អ្នកជំនាន់មុននេះ ទើបមានការចែករំលែកឲ្យក្មេងជំនាន់ក្រោយបានដឹងអំពីព្រឹត្តិការណ៍អតីតកាល»។

ចំណែកលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងអំពីកាតព្វកិច្ច នៃការចងចាំនៅក្នុងកថាមុខនៃសៀវភៅ «បូជាភ្លើង» ថា «អ្នកដែលបានហែលឆ្លងកាត់ប្រវត្តិសាស្ត្រទាំងឡាយ ត្រូវតែចែករំលែកចំណេះដឹងរបស់ខ្លួនទៅមនុស្សជំនាន់ក្រោយ ហើយមនុស្សជំនាន់ក្រោយ មានកាតព្វកិច្ចក្នុងការរៀនសូត្រ និងផ្សព្វផ្សាយចំណេះដឹងនេះជាបន្តបន្ទាប់។ការចងចាំគឺជាការចាប់ផ្តើម និងសេចក្តីបញ្ចប់ចំពោះបេសកម្ម ក្នុងការស្វែងរកយុត្តិធម៌ សន្តិភាព និងការពិត។រីឯកាតព្វកិច្ចក្នុងការចងចាំគឺចាប់ផ្តើមនិងបញ្ចប់ដោយបុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តអំពីសារសំខាន់របស់ប្រវត្តិសាស្ត្រ មិនត្រឹមតែចំពោះខ្លួនឯងផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះមនុស្សជំនាន់ក្រោយឯទៀតដែរ»។

ឈុំ ស្រីតូច គឺជានិស្សិតផ្នែកប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានចូលរួមក្នុងកម្មវិធីសម្ពោធសៀវភៅ «បូជាភ្លើង» បានឲ្យដឹងថា សៀវភៅនេះពិតជាមានសារសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវ។ សៀវភៅនេះបានបន្ថែមនូវចំណេះដឹងថ្មីដល់ខ្ញុំ ដែលកាលពីមុនខ្ញុំមិនដែលដឹងទាល់តែសោះអំពីអំពើប្រល័យពូជសាសន៍ សាហាវយង់ឃ្នង កើតមានក្នុងទ្វីបអឺរ៉ុប។ កាលពីមុនខ្ញុំគិតថា មានតែប្រជាជនកម្ពុជាតែប៉ុណ្ណោះដែលបានឆ្លងកាត់អំពើ ប្រល័យពូជសាសន៍។ ខ្ញុំសូមគាំទ្រចំពោះការបកប្រែសៀវភៅពីភាសាបរទេសមកជាភាសាខ្មែរសម្រាប់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ និងប្រជាជនខ្មែរអាន។ ខ្ញុំសង្ឃឹមថាមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានការបកប្រែសៀវភៅភាសាបរទេសមកជាខេមរៈភាសាកាន់តែច្រើនថែមទៀត។

សំអុល ច័ន្ទសិលា គឺជាគរុសិស្សឯកទេសជីវវិទ្យាបានចាប់អារម្មណ៍ការរចនាក្របសៀវភៅខាងមុខៗ សៀវភៅនេះមានទំហំតូចល្មមដែលទាក់ទាញចិត្តខ្ញុំឲ្យចង់អាន។

សៀវភៅនេះគឺជាតម្លៃនៃប្រវត្តិសាស្ត្រ និងមានការកាប់សម្លាប់ប្រជាជនដូចនៅក្នុងរបបខ្មែរក្រហមដែរ។ ទោះបីជាមិនអាចប្រៀបធៀបសេចក្តីឈឺចាប់ រវាងជនជាតិទាំងពីរបានប៉ុន្តែខ្ញុំជឿជាក់ថាប្រជាជនកម្ពុជា និងជនជាតិជ្វីហ្វទទួលរងនូវការឈឺចាប់ខ្លោចផ្សាដូចគ្នា។ ស្ត្រីជនជាតិជ្វីហ្វត្រូវបានកោរសក់និងត្រូវបានទាហានចាប់រំលោភ ឬបង្ខំឲ្យបម្រើផ្លូវភេទ។នៅពេលប្រជាជនមានជំងឺ ត្រូវណាហ្ស៊ីសម្រាតខោអាវចេញហើយប្រសិនបើអ្នកជំងឺស្គមមើលទៅឃើញតែឆ្អឹងមិនត្រូវបាននាំទៅព្យាបាលឡើយ។ អ្នកជំងឺនោះត្រូវបានណាហ្ស៊ីយកទៅសម្លាប់ឬដាក់នៅក្នុងបន្ទប់ផ្សែងពុល។

ខ្ញុំយល់ថា គួរតែបញ្ចូលសៀវភៅនេះទៅក្នុងការអប់រំនៅតាមសាលា។ ទោះបីព្រឹត្តិការណ៍ខ្លះ ឃោរឃៅយង់ឃ្នងធ្វើឲ្យផលប៉ះពាល់អារម្មណ៍អ្នកអាន ប៉ុន្តែវាមានប្រយោជន៍ដើម្បីទប់ស្កាត់បទឧក្រិដ្ឋទាំងនេះកុំឲ្យកើតឡើងម្តងទៀត។

សៀវភៅ «បូជាភ្លើង» ដែលបានបកប្រែចេញពីភាសាអង់គ្លេស «Holocaust» ឬ «ហូឡូខសត៍» ដោយកញ្ញាសូវិចិត្រ មេត្តា នឹងធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវ គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកអាន មានការយល់ដឹងកាន់តែទូលំទូលាយអំពីខ្លឹមសារនៃពាក្យនេះជាភាសាជាតិ និងយល់ដឹងពីហេតុការណ៍នៃការកាប់សម្លាប់យ៉ាងរង្គាលនៅក្នុងទ្វីបអឺរ៉ុបផងដែរ។

**ដារ៉ារដ្ឋ មេត្តា**

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ឆ្នាំ២០១៩ ដល់ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១មួយច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

សូមអរគុណ!

# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២

## *ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម*

**(តពីលេខមុន)**

៤៩. សរុបមកវិញអង្គជំនុំជម្រះយល់ឃើញថា នួន ជា បានចូលរួមក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមៗ នួន ជាបានចូលរួមបង្កើតអនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនេះតាមរយៈការពន្យល់ ជាសាធារណៈការឯកភាព និងជំរុញគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាៗ គាត់បានធ្វើដូចច្នេះតាមរយៈតួនាទីដឹកនាំក្នុងនាមជាដៃស្តាំរបស់ ប៉ុល ពត ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍បក្សនិងតាមរយៈការចូលរួមយ៉ាងសកម្មរបស់គាត់ក្នុងការឃោសនានិងអប់រំៗ លើសពីនេះទៀត តាមរយៈការចូលរួមដោយផ្ទាល់និងយ៉ាងទូលំទូលាយរបស់គាត់ក្នុងការបោសសម្អាត និងដំណើរការរបស់មន្ទីរសន្តិសុខ ស-២១ នួន ជាបានអនុវត្តគោលបំណងរួមនេះដោយប្រើអន្តរការី ដូចជា ឌុច និងចារីផ្ទាល់ផ្សេងៗទៀត ដូចជា បុគ្គលិកមន្ទីរសន្តិសុខ ស-២១ជាឧបករណ៍នៃសហឧក្រិដ្ឋកម្មរួមៗ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានចូលរួមចំណែក យ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុង វិសាលភាពនៃសំណុំរឿង ០០២/០២ៗ

៥០. ម្យ៉ាងវិញទៀតដូចបានរៀបរាប់ខាងលើមកហើយ អង្គ ជំនុំជម្រះយល់ឃើញថា នួន ជា មានចេតនាដែលជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងៗទៀតរួម ទាំង ចេតនាជាក់លាក់ និងចេតនារើសអើងដែលជា



នួន ជា និង ខៀវ សំផន ជនជាប់ចោទនៅក្នុងសំណុំរឿង០០២

លក្ខខណ្ឌកំណត់ក្នុងការប្រព្រឹត្តខក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនអាចកំណត់ ឬសន្និដ្ឋានពីចេតនាប្រល័យពូជសាសន៍របស់ នួន ជា ទាក់ទងនឹងជនជាតិចាមនោះទេ ហើយក៏មិនអាច សន្និដ្ឋានឲ្យហួសពីវិមតិសង្ស័យថា នួន ជា បានដឹងថាអំពើប្រល័យពូជសាសន៍ត្រូវបាន ប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាមដែរ។ យ៉ាងណាក៏ដោយអង្គជំនុំជម្រះជឿជាក់ថា នួន ជា យ៉ាងហោចណាស់ក៏មានហេតុផលដឹង ថាអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឬគ្រោងនឹងប្រព្រឹត្តលើជនជាតិចាម។

៥១. អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានប្រព្រឹត្តតាមរយៈសហក្រិដ្ឋកម្មរួម (ក) ខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតការសម្លាប់រង្គាលការនិរទេសការធ្វើឲ្យទៅជាទាសករការដាក់ក្នុងមន្ទីរឃុំឃាំងការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានិងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀស ដោយបង្ខំអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ(ខ) ខក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈ ការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុពូជសាសន៍វៀតណាម និង(គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ការបង្ករ ដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោស ដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយដែលត្រូវទទួលបានការការពារ ស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តខក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋរួមត្រង់ចំណុចដែលនួនជា មានចេតនាដោយផ្ទាល់ចេតនារើសអើង និងចេតនាជាក់លាក់ដូចចេតនារបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀតដែរ។

៥២. លើសពីនេះទៅទៀតពាក់ព័ន្ធនឹងការស្លាប់នៅសហករណ៍ការដ្ឋានការងារនិងមន្ទីរសន្តិសុខដោយសារតែចេតនា ដោយប្រយោលដែលមិនស្ថិតក្នុងគោលបំណងរួម)អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានជួយ និងជំរុញឲ្យប្រព្រឹត្តខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលត្រូវបាន អនុវត្តដោយចេតនាដោយប្រយោលនៅសហករណ៍ត្រាំកក់ការដ្ឋានការងារទំនប់មករាការដ្ឋាន ការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថាការប្រព្រឹត្តរបស់នួនជាត្រូវបានចាត់ទុកថាជាទម្រង់នៃការជួយ និងជំរុញ។ គាត់បានផ្តល់ការលើទឹកចិត្តនិងគាំទ្រផ្លូវចិត្ត ដោយលើកទឹកចិត្តឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា អនុវត្តគោលនយោបាយរបស់មជ្ឈិមបក្សយ៉ាងក្លៀវក្លា តាមរយៈតួនាទីដ៏សំខាន់របស់គាត់ក្នុងការឃោសនា ព្រមទាំងបង្ហាញខ្លួនជាច្រើនលើកនៅក្នុងកិច្ចប្រជុំនិងថ្ងៃងសុន្ទរកថានៅក្នុងវគ្គអប់រំទូទាំងប្រទេស។ អង្គជំនុំជម្រះយល់ឃើញថាទង្វើនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តខក្រិដ្ឋកម្មហើយនួនជាបានដឹងអំពីរឿងនេះ។ អាស្រ័យហេតុនេះអង្គជំនុំជម្រះសម្រេចផ្តន្ទាទោសចំពោះការជួយនិងជំរុញឲ្យមានការប្រព្រឹត្តខក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិតាមរយៈការធ្វើមនុស្សឃាតដោយចេតនា ដោយប្រយោលនៅទីតាំងដែលកើតមានខក្រិដ្ឋកម្មខាងលើនេះ។

៥៣. ជាចុងក្រោយអង្គជំនុំជម្រះយល់ឃើញថា

នួន ជា បានប្រើអំណាចសម្រេចចិត្តចុងក្រោយជាមួយនឹង ប៉ុល ពត ហើយមានសិទ្ធិអំណាចក្នុងការ ដាក់វិន័យសមាជិកថ្នាក់ក្រោមនៅក្នុងបក្សនិងនៅក្នុងជួរយោធា។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលបានប្រព្រឹត្តឡើងតាមគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ ឧក្រិដ្ឋកម្ម ទាំងនេះរួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។យ៉ាងណាក៏ដោយដោយយល់ឃើញថាទីមួយ នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបទល្មើសទាំងនេះតាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមលើកលែងតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយចេតនាដោយប្រយោលដូចបានបញ្ជាក់ច្បាស់ខាងលើ ហើយទីពីរ នួន ជា ត្រូវទទួលខុសត្រូវចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយ ចេតនាដោយប្រយោលអង្គជំនុំជម្រះសម្រេចផ្តន្ទាទោសក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។ ចំពោះចំណុចផ្សេងៗទៀត អង្គជំនុំជម្រះបានពិចារណាលើតួនាទីរបស់ នួន ជា នៅក្នុងការកំណត់ទោស។

### ១.៤.២. ការទទួលខុសត្រូវរបស់ ខៀវ សំផន

៥៤. នៅឆ្នាំ១៩៧១ ខៀវ សំផនបានក្លាយជាសមាជិកត្រៀម នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយនៅឆ្នាំ១៩៧៦គាត់បានក្លាយជាសមាជិកពេញសិទ្ធិ។ នៅឆ្នាំ១៩៧០ខៀវសំផនត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។

ជាក់ស្តែងខៀវ សំផនពុំមានអំណាចផ្នែកយោធាដោយផ្ទាល់នោះឡើយហើយ ប៉ុល ពត ឯណោះទេដែលទទួលបន្ទុកលើកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានោះ។ ខៀវ សំផន ក៏បាន កាន់ដំណែងជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីការពារជាតិនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផងដែរ។ ក្រោយពេលដួល រលំទីក្រុងភ្នំពេញ ក្នុងខែមេសាឆ្នាំ១៩៧៥ ខៀវ សំផនបានរក្សាតួនាទីរបស់ខ្លួនជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ដូច្នេះហើយគាត់បានបន្តបំពេញមុខងារការទូតមួយចំនួន ដូចជាការជួបជាមួយគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា និងការដឹកនាំគណៈប្រតិភូកម្ពុជាទៅធ្វើទស្សនកិច្ចនៅឯបរទេស។

៥៥. នៅក្នុងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានតែងតាំង ខៀវ សំផន ឲ្យទទួលខុសត្រូវផ្នែក “រណសិរ្ស និងរាជរដ្ឋាភិបាល និងពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ”។ ក្នុងអំឡុងខែតុលាឆ្នាំ១៩៧៥ ខៀវ សំផន បានក្លាយជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៃមន្ទីរ ៨៧០ ដែលត្រួតពិនិត្យលើការ អនុវត្តរាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ទោះបីជាយ៉ាងណាអង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនធ្លាប់បានធ្វើជា ប្រធានមន្ទីរ ៨៧០ ដូចដែលគាត់ត្រូវបានចោទប្រកាន់នោះឡើយ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋដែល គ្រាន់តែជាតួនាទីនិមិត្តរូបតែប៉ុណ្ណោះដោយគាត់ពុំមានអំណាចផ្នែកប្រតិបត្តិនោះឡើយ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋខៀវសំផនបានបន្តបំពេញមុខងារផ្នែកការទូតនិងក្នុងពិធីការផ្សេងៗ។

**(នៅមានត)**

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# និស្សិតមកពីឃ្វីនស៍លែន ស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

នាព្រឹកថ្ងៃសុក្រ ទី៩ ខែកក្កដា ឆ្នាំ២០១៩ និស្សិតអន្តរជាតិចំនួន២៣នាក់មកពីសាកលវិទ្យាល័យឃ្វីនស៍លែន នៃប្រទេសអូស្ត្រាលី បានបំពេញទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានបំណងសិក្សាស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។

ក្នុងដំណើរទស្សនកិច្ចសិក្សានេះ ក្រុមការងារវិចិត្រសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានស្វាគមន៍ និងមានភាពសប្បាយរីករាយក្នុងការណែនាំនិស្សិតទាំងអស់ ឲ្យស្វែងយល់បន្ថែមអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមតាមរយៈការដាក់តាំងពិព័រណ៍សិល្បៈ ការចាក់ បញ្ចាំងខ្សែភាពយន្តឯកសារក្រោមចំណងជើង «ឆ្នាំព្រៃ» និងការពិភាក្សាស្តីពីប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ជាមួយលោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាព អន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

ពិព័រណ៍សិល្បៈរបស់វិចិត្រសាលស្លឹករឹត រួមមាន «មិនដុតរលត់» «សំណល់សង្គ្រាម» និង«ភក់» ដែលពិពណ៌នាពីរឿងរ៉ាវ ដែលបានកើតឡើងក្នុងអំឡុងរបបខ្មែរក្រហមក៏ប៉ុន្តែបង្ហាញអំពីសុទិដ្ឋិនិយមចំពោះអនាគតនៃប្រទេសដែលបានឆ្លងកាត់សង្គ្រាម និងអំពើប្រល័យពូជសាសន៍។



និស្សិតមកពីសាកលវិទ្យាល័យឃ្វីនស៍លែន ទស្សនាពិព័រណ៍នៅសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត



និស្សិតមកពីសាកលវិទ្យាល័យឃ្វីនស៍លែន កំពុងទស្សនាខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ»

ពិព័រណ៍ទាំងនេះ ចូលរួមចំណែកក្នុងការលើកកម្ពស់ការស្វែងយល់ និងការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ បន្ទាប់ពីស្តាប់ការ ធ្វើបទបង្ហាញពីពិព័រណ៍សិល្បៈនិស្សិតទាំងអស់បានទស្សនាខ្សែភាពយន្តឯកសាររឿង «ឆ្នាំព្រៃ» រយៈពេលមួយម៉ោង ដែលបានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់ ព្រះតេជគុណ ប៊ុន សាលួត និងការជំរុញចិត្តដល់ការចូលរួម ក្នុងការការពារព្រៃឈើរបស់កម្ពុជា។

បន្ទាប់មក លោកបណ្ឌិត លី សុខឃាង បានបើកកិច្ចពិភាក្សា ជាមួយក្រុមនិស្សិតចម្រុះជាតិសាសន៍ជុំវិញប្រធានបទប្រវត្តិសាស្ត្រខ្មែរក្រហម និងតំបន់តស៊ូចុងក្រោយខ្មែរក្រហមអន្លង់វែង។ និស្សិតសាលកវិទ្យាល័យឃ្វីនស៍លែន បានចោទសួរសំណួរមួយចំនួន ដូចខាងក្រោម ៖

**សំណួរទី១ ៖**

ខ្ញុំបានឃើញរូបភាពស្តីពីគម្រោងអេកូទេសចរណ៍ ដែលអនុញ្ញាតឲ្យភ្ញៀវទេសចរ អាចមកលេងនៅទីនោះ។ តើគម្រោងនេះកំពុងកើតឡើងនៅពេលនេះ ឬនាពេលអនាគត?

**សំណួរទី២ ៖**

តើមានតំបន់អភិរក្សផ្សេងទៀតទេនៅក្នុងខ្សែភាពយន្តឯកសារនេះ?

**សំណួរទី៣ ៖**

តើការគម្រាមកំហែងពីគ្រាប់មីននៅក្នុងដី ដែលជាសំណេះសំណល់សង្គ្រាមស៊ីវិលអតីតកាល នៅតែជាបញ្ហាប្រ ឈមនៅក្នុងប្រទេសកម្ពុជា? ដំណើរទស្សនកិច្ចស្វែងយល់ អំពីប្រវត្តិសាស្ត្រខ្មែរក្រហមរបស់សាកលវិទ្យាល័យឃ្វីនស៍លែននៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ចប់ដោយ និស្សិតទាំងអស់ទទួលបានចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រ និងបានថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារ។ **លីម អ៊ិភីង**

# សិស្សអនុវិទ្យាល័យតាំងយ៉ចំនួន៩៣នាក់ ទទួលការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ (១៩៧៥-១៩៧៩)

នៅព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា រៀបចំវេទិកាថ្នាក់រៀនស្តីអំពីសារសំខាន់ នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាលើកទី២នៅអនុវិទ្យាល័យតាំងយ៉ ដែលមានទីតាំង នៅភូមិតាំងយ៉ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៩៣នាក់ (ស្រី ៤៣នាក់) និងលោកគ្រូអ្នកគ្រូចំនួន៣នាក់ (ស្រី២នាក់)។ វេទិកាថ្នាក់រៀននេះ បានរៀបចំឡើងក្នុងគោលបំណងបង្កើនការយល់ដឹងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សានុសិស្ស។ សិស្សានុសិស្សរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺក្នុងន័យផ្សះផ្សា អត់ទិនអធ្យាស្រ័យយោគយល់គ្នា និងការពារកុំឲ្យមានអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀត។

លោក នី សុផល នាយកសាលាអនុវិទ្យាល័យតាំងយ៉បានលើកឡើងនៅក្នុងវេទិកាថ្នាក់រៀនថាខ្ញុំពិតជាសប្បាយរីករាយ និងពេញចិត្តដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាថ្នាក់រៀននៅសាលាអនុវិទ្យាល័យតាំងយ៉។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានជំនាញខាងប្រវត្តិសាស្ត្រខ្មែរក្រហម និងមានឯកសារដែលអាចឲ្យជឿទុកចិត្តបាន ដូច្នេះការចែករំលែកបទពិសោធន៍ពីរបបខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយដែលមិនបានដឹង និងឆ្លងកាត់ពិតជាមានសារសំខាន់ ដើម្បីឲ្យសិស្សានុសិស្សចេះស្រាវជ្រាវស្វែងយល់ពីរបបខ្មែរក្រហម ដែលជាប្រវត្តិសាស្ត្រមួយទាមទារឲ្យក្មេងជំនាន់ក្រោយមានត្រូវយល់ដឹង និងចងចាំ។ ខ្ញុំមានស្រុកកំណើតនៅស្រុកស្រីសន្ធរ



លោក ឡុង ដានី និងកូនសិស្សថតរូបជុំគ្នាបន្ទាប់ពីចប់វេទិកាថ្នាក់រៀន

ខេត្តកំពង់ចាម។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ (១៩៧៥-១៩៧៩) ខ្ញុំត្រូវបានចាត់តាំងឲ្យរស់នៅក្នុងកងកុមារដែលស្ថិតនៅឆ្ងាយពីក្រុមគ្រួសារ។ ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការងារដូចជា ៖ កាប់ដើមទន្ទ្រានខែត្រ ដើម្បីធ្វើជីដាក់ស្រែរើសអាចម៍គោ និងឃ្វាលគោ។ ក្រោយពីរបបខ្មែរក្រហមបានដួលរលំខ្ញុំបានត្រឡប់ទៅស្រុកកំណើត។ នៅឆ្នាំ ១៩៨១ ខ្ញុំបានចូលរៀនថ្នាក់ទីមួយ រហូតប្រឡងចូលរៀនធ្វើជាគ្រូប ង្រៀន។ នៅឆ្នាំ២០១២ ខ្ញុំបានផ្លាស់មកធ្វើជានាយកសាលាអនុវិទ្យាល័យតាំងយ៉ មកសព្វថ្ងៃនេះ។

បន្ទាប់ពីសិស្សានុសិស្ស បំពេញតារាងស្ទាប់ស្ទង់មតិមុនវេទិកាថ្នាក់រៀន, ឡើងសរសេរនូវអ្វីដែលខ្លួនបានដឹងនិងចង់ដឹងអំពីរបបខ្មែរក្រហម និងទស្សនាខ្សែភាពយន្តឯកសារស្តីពីតំបន់រំដោះខ្មែរក្រហមឆ្នាំ១៩៧៣ និងកុមារកម្ពុជារួចមក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងរបស់មជ្ឈមណ្ឌឯកសារកម្ពុជា បានធ្វើបទបង្ហាញអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងឆ្លើយសំណួរដែលសិស្សានុសិស្សចង់ដឹងពីរបបនោះ។ នៅចុងបញ្ចប់នៃ វេទិកាថ្នាក់រៀនសិស្សានុសិស្សបានបំពេញតារាងស្ទាបស្ទង់មតិម្តងទៀត ហើយបុគ្គលិកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ក៏បានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៩៣ក្បាលដល់សិស្សានុ សិស្សដែលបានចូលរួមវេទិកាថ្នាក់រៀននេះ។

គួន ស្រីក្ខណ៍ ភេទស្រី អាយុ១៦ឆ្នាំ គឺជា សិស្សថ្នាក់ទី៩«A» នៃអនុវិទ្យាល័យតាំងយ៉ បាននិ យាយថា ខ្ញុំពិតជាមានការសប្បាយចិត្តយ៉ាងខ្លាំង នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានមកបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលធ្វើឲ្យខ្ញុំនិងសិស្សដទៃទៀតបានយល់កាន់តែច្បាស់ពីរបបដ៏ជូរចត់នេះ។ ខ្ញុំធ្លាប់បានស្តាប់ជីតានិយាយពីរបបខ្មែរក្រហមថា សម័យនោះគ្មានសាលារៀន ហើយការរស់នៅរបស់គាត់ជួបការលំបាកយ៉ាងខ្លាំង ចំណែកប្រជាជនត្រូវបានសម្លាប់ដោយគ្មានកំហុស។ ការចូលរួមវេទិការថ្នាក់រៀនរបស់ខ្ញុំនៅថ្ងៃនេះ បានធ្វើឲ្យខ្ញុំនឹកឃើញដល់បទពិសោធន៍ជីតាដែលជាជនរងគ្រោះ និងធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមនេះ។ នៅពេលស្តាប់រឿងជីតាបាននិយាយប្រាប់ ធ្វើឲ្យខ្ញុំមានចិត្តអាណិតជីតាយ៉ាងខ្លាំង។ ទោះបីយ៉ាងណា ខ្ញុំមិនស្អប់គុំគួនចំពោះកម្មាភិបាលខ្មែរក្រហមទេ ប៉ុន្តែខ្ញុំនៅតែមិនសប្បាយចិត្ត និងមានសេចក្តីអាណិតដល់ជនរងគ្រោះដែលកម្មាភិបាលខ្មែរក្រហមបានធ្វើបាប។ ខ្ញុំចង់ឲ្យប្រជាជនខ្មែរសាមគ្គីគ្នា និងទប់ស្កាត់កុំឲ្យមានរបបនេះកើតឡើងម្តងទៀត។ ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំងនៅពេលឃើញប្រជាជនកម្ពុជា ចេះអត់ឱនឲ្យគ្នា។

ប្រាក់ លាងភា ភេទស្រី អាយុ១៥ឆ្នាំ ជាសិស្សថ្នាក់ទី៩ «A» នៃអនុវិទ្យាល័យតាំងយ៉ បានរៀបរាប់ថា ខ្ញុំមានឪពុកម្តាយជាអ្នកស្រុកកំពង់ចាម និងបានចំណាក់ ស្រុកមករស់នៅភូមិតាំងយ៉ នៅដើមឆ្នាំ២០០០។ វាគឺជាឱកាសល្អសម្រាប់ខ្ញុំក៏ដូចជាសិស្ស ដ៏ទៃទៀតដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានមករៀបចំវេទិកាថ្នាក់រៀននេះឡើង។ វេទិកាថ្នាក់រៀននេះបានធ្វើឲ្យខ្លួនខ្ញុំ និងសិស្សផ្សេងៗទៀតបានយល់ដឹងពីប្រវត្តិសាស្ត្រឈឺចាប់របស់ប្រជាជនខ្មែរទាំងអស់ ហើយអាចជៀងវាងកុំឲ្យប្រវត្តិសាស្ត្រនេះត្រឡប់មកវិញម្តងទៀត។ ខ្ញុំធ្លាប់បានស្តាប់រឿងរ៉ាវរបស់ឪពុកខ្ញុំដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ ខ្ញុំមានចិត្តអាណិតឪពុករបស់ខ្ញុំនៅពេលដឹងថាគាត់បានឆ្លងកាត់រឿងរ៉ាវដ៏អាក្រក់នេះ។ ខ្ញុំមិនពេញចិត្តចំពោះទង្វើអតីតកម្មាភិបាល ខ្មែរក្រហមដែលធ្វើឲ្យប្រជាជនឲ្យរងទុក្ខវេទនា និងប្រជាជនស្លាប់យ៉ាងច្រើន។ ប៉ុន្តែខ្ញុំមិនបានគុំគួនកម្មាភិបាលខ្មែរក្រហម ឬស្អប់ខ្ពើមចំពោះកូនកម្មាភិបាលខ្មែរក្រហមទេ។ តាមរយៈការអប់រំអំពីប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជាគឺមានន័យថាឲ្យយើងចេះអធ្យាស្រ័យគ្នា និងសាមគ្គីគ្នាដើម្បីទប់ស្កាត់មិនឲ្យរបបដ៏ឃោរឃៅនេះកើតឡើងជាថ្មីម្តងទៀត។

ប្រវត្តិភូមិតាំងយ៉ និងអនុវិទ្យាល័យតាំងយ៉ ភូមិតាំងយ៉ (ភូមិស្រែតាំងយ៉) ត្រូវបានអ្នកភូមិ ឬអ្នកដំណើរដែលធ្វើ

ដំណើររឿងកាត់ចំណុចតាំងយ៉និយាយតៗគ្នាថា កាលពីមុនមានបុរសម្នាក់ដែលជាជនជាតិភាគតិចមានឈ្មោះ តាតាំង (មានប្រជាជនខ្លះបានលើកឡើងថា តាតាំង គឺជាជនជាតិចិន) ដែលជា អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់តែងតែទទួលយកដីស្រែដែល អ្នកភូមិជាជនជាតិព័រនិងជជង់ខ្នងភ្នំដាក់បញ្ចាំៗ ក្រោយមកអ្នកភូមិមិនមាន ប្រាក់បង់រំលួសបំណុលហើយ ដីស្រែទាំងអស់បានក្លាយជាកម្មសិទ្ធិរបស់តាតាំងៗ បន្ទាប់ពីតាតាំងបានស្លាប់ទៅ ជនជាតិព័រ និងជជង់ខ្នងភ្នំបានត្រឡប់មករស់នៅក្នុងតំបន់នេះវិញដោយបានដាក់ឈ្មោះថា ភូមិស្រែតាំងយ (តាំង ជាឈ្មោះរបស់តាតាំងហើយអក្សរ «យ» គឺមកពីអ្នកភូមិយកដីស្រែទៅបញ្ចាំនឹងតាតាំង ហើយតាតាំងបានទទួលយកដីស្រែទាំងអស់នោះៗ

រយៈពេលបានកន្លងទៅយូរទៅៗ ពាក្យ «យ» ក៏បានក្លាយទៅជាពាក្យ «យ៉» វិញៗ បន្ទាប់មកអ្នកភូមិក៏បានហៅកម្លាយកាត់ពីឈ្មោះភូមិស្រែតាំងយ៉មកជាភូមិតាំងយ៉រហូតមកដល់សព្វថ្ងៃៗ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ នៅក្នុងឆ្នាំ១៩៩៨ មានប្រជាជនប្រមាណជា២០គ្រួសារបានមករស់នៅក្នុងភូមិតាំងយ៉ៗ នៅឆ្នាំ២000អ្នកភូមិបានស្នើសុំជំនួយអង្គការ បារាំងឈ្មោះអាកាមី ដើម្បីសាងសង់សាលាបឋមសិក្សា តាំងយ៉ដែលមានអាគារមួយខ្នងសម្រាប់កូនចៅបានរៀនសូត្រៗ

នៅឆ្នាំ២00៨ ប្រជាជនបានបន្តស្នើសុំឯកឧត្តម ស៊ុយ សែម ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយ ខេត្តពោធិ៍សាត់របស់គណបក្សប្រជាជនកម្ពុជា ដើម្បីសាងសង់អគារមួយខ្នងទៀតមានចំនួន៥បន្ទប់ ដើម្បីបង្កើតជាអនុវិទ្យាល័យតាំងយ៉ៗ សាលាបឋមសិក្សា និងអនុវិទ្យាល័យតាំងយ៉មានផ្ទៃដីសរុបចំនួន១១ហិកតាៗ ផ្ទៃដីសាលារៀននេះ គឺជាអតីតបន្ទាយនៃកងទ័ពវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគ្របដណ្តប់ទៅដោយ រណ្តៅត្រង់សេ និងគ្រាប់មីនជាច្រើនគ្រាប់ដែលកងទ័ពបានដាក់ការពារបន្ទាយរបស់ខ្លួនៗ នៅក្នុងបរិវេណសាលាក៏មានផ្នូរសាកសពកងទ័ព ជាច្រើនដែលបានកប់នៅអំឡុងសង្គ្រាមរវាងកងទ័ពវៀតណាមដែលសហការជាមួយកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវាយប្រឆាំង នឹងកងទ័ពខ្មែរក្រហមនៅក្នុងទសវត្សរ៍ឆ្នាំ៨០ និងដើមឆ្នាំ១៩៩០ៗ

បន្ទាប់ពីសាងសង់រួចរាល់នៅឆ្នាំ២០១២ អនុវិទ្យាល័យតាំងយ៉មានថ្នាក់រៀនតែមួយបន្ទប់ គឺថ្នាក់ទី៧ និងមានគ្រូបង្រៀនចំនួន៣នាក់ ប្រុស២នាក់ ប្រុស១នាក់ ក្នុងនោះមានគ្រូប្រវត្តិវិទ្យាម្នាក់ៗ អនុវិទ្យាល័យតាំងយ៉ចាប់ផ្តើមបង្រៀនបានប្រហែល២ខែក៏ត្រូវផ្អាក ដោយមានហេតុការណ៍អរូបីចម្លែកមួយ គឺករណីខ្មោចចូលសន្ថិតក្នុងខ្លួនកូនសិស្សស្រីម្នាក់ ដែលបង្កឲ្យមានការភ័យខ្លាចចំពោះសិស្សដ៏ទៃទៀត និងបានឈប់មកសាលារៀនៗ ថ្នាក់ដឹកនាំសាលាក៏បានសម្រេចបិទទ្វារសាលាជាបណ្តោះអាសន្នៗ

នៅឆ្នាំសិក្សា២០១៣ - ២០១៤សាលាអនុវិទ្យាល័យតាំងយ៉បានដំណើរការវិញ ដោយមានសិស្សថ្នាក់ទី៧ចំនួន៦១នាក់ (ស្រី៤១នាក់) ដោយមានលោក នី សុផលជានាយកសាលាៗ បន្ទាប់មក លោកសុផល បានដាក់ស្នើទៅក្រសួងអប់រំ យុវជន និងកីឡា សាងសង់អគារមួយខ្នងទៀតមាន៥បន្ទប់ៗ នៅឆ្នាំសិក្សា២០១៤-២០១៥ ចំនួនសិស្សានុសិស្សបានកើនឡើង ដោយមានសិស្សសរុបចំនួន៨៦នាក់ (ស្រី៥១នាក់) បានរៀននៅថ្នាក់ទី៧ និងថ្នាក់ទី៨ និងមានគ្រូបង្រៀនចំនួន៥នាក់ ប្រុស១នាក់ និងស្រី៤នាក់ៗ ឆ្នាំសិក្សា២០១៥-២០១៦ មានសិស្សសរុបចំនួន៨៦នាក់ (ស្រី៥៦នាក់) និងមានចំនួន៣ថ្នាក់ គឺថ្នាក់ទី៧ ចំនួន២បន្ទប់, ថ្នាក់ទី៨ចំនួន១បន្ទប់ និងថ្នាក់ទី៩ចំនួន១បន្ទប់ៗ នៅឆ្នាំសិក្សា ២០១៦-២០១៧ មានសិស្សសរុបចំនួន៩៦នាក់ (ស្រី៥៧ នាក់) និងឆ្នាំសិក្សា ២០១៧-២០១៨ មានសិស្សចំនួន១១៩ នាក់ (ស្រី៦៣នាក់)ៗ នៅឆ្នាំ២០១៨-២០១៩ នេះមានសិស្សសរុបចំនួន១២៩នាក់ (ស្រី៩៦នាក់) និងគ្រូបង្រៀន៧នាក់ (ស្រី២នាក់)ៗ

*សុង ថាណៃ*

# ដំណើរដ៏វែងឆ្ងាយ ឆ្ពោះទៅរកការយោគយល់ និងការរើសអើង

ទោះបីជាសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៃរបបខ្មែរក្រហមបានផុតរលត់ទៅហើយយ៉ាងណាក្តី ក៏ផលអាក្រក់នៃរបបនេះ នៅតែបន្តជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរមកលើការរស់នៅរបស់ប្រជាជន កម្ពុជាមកទល់ពេលបច្ចុប្បន្ន។ ការស្លាប់របស់ប្រជាជនកម្ពុជាប្រៀបបានទៅនឹងទន្លេឈាមដ៏ធំធេង ដែលបានជន់លិចទឹកដីសុវណ្ណភូមិអស់រយៈពេលជាច្រើនទសវត្សរ៍ ដែលប្រជាជនប្រមាណ២លាននាក់ត្រូវបានជឿជាក់ថា បានស្លាប់ដោយសារជំងឺ គ្រោះអត់ឃ្លាន ធ្វើការហួសកម្លាំង និងការសម្លាប់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ត្រូវបានទទួលស្គាល់ថា ជាជនរងគ្រោះ ហើយទន្ទឹមនឹងនោះដែរ ក្រុមអតីតអ្នកតស៊ូនៃចលនាខ្មែរក្រហមមួយចំនួន ដែលធ្លាប់ប្រព្រឹត្តិអំពើឃោរឃៅ និងអំពើអមនុស្សធម៌មកលើប្រជាជនកម្ពុជា ក៏បានសម្របខ្លួនទៅនឹងបរិបទសង្គមថ្មី ដោយបានលាក់បាំងនូវអត្តសញ្ញាណរបស់ខ្លួន និងបន្តរស់នៅក្នុងនាមជាជនរងគ្រោះដូចប្រជាជនដទៃទៀតដែរ។ ទោះបីជា រូបភាពខាងក្រៅត្រូវបានបង្ហាញឲ្យឃើញដូចនេះក្តីក៏ការឈឺចាប់ និងវិប្បដិសាររបស់ក្រុមអតីតខ្មែរក្រហមទាំងនោះ នៅតែបន្តដិតដាមចំពោះជាតិសាសន៍របស់ខ្លួនដែលខុសប្លែកពីឥរិយាបថប្រជាជន ធម្មតា។

ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំផុតទៅនៅឆ្នាំ១៩៧៩ ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ខ្មែរក្រហមនៅតែបន្តមនោគមវិជ្ជារបស់ខ្លួន ដោយបានជម្លៀសប្រជាជន និងយោធារាប់សែននាក់ទៅជាមួយ ដើម្បីរៀបចំ



ទេសភាពបឹងអន្លង់វែង ក្នុងខេត្តឧត្តរមានជ័យ

កម្លាំងនៅតាមបណ្តោយព្រំដែនជួរភ្នំដងរែក ដើម្បីក្នុងការវាយប្រហារ និងគ្រប់គ្រងប្រទេសកម្ពុជាម្តងទៀត។

តំបន់ជាច្រើនដែលមានប្រវត្តិតស៊ូតាមទល់ដែនខ្មែរ-ថៃ ក្នុងនោះតំបន់អន្លង់វែងក៏ជាតំបន់មួយដែលត្រូវបានចាត់ទុកថា ជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមដែលបានឆ្លុះបញ្ចាំងពីរឿងរ៉ាវជាច្រើនរាប់មិនអស់ នៃចលនាតស៊ូក្នុង តំបន់អន្លង់វែងក្រោមការគ្រប់គ្រងរបស់តាម៉ុក (ឈិត ជឿន)។ រស់នៅប្រចាំថ្ងៃរបស់ខ្លួនអស់រយៈពេល៤០ឆ្នាំមកហើយ។

សួន យឿន ភេទប្រុស អាយុ ៦៤ឆ្នាំ គឺជាអតីតយោធាខ្មែរក្រហមមួយរូបបានលើកឡើងពីមកដល់របស់ខ្លួននៅតំបន់អន្លង់វែង ថា ៖ «នៅឆ្នាំ១៩៧៣ខ្ញុំបានធ្វើដំណើរពីសមរភូមិខាងក្នុងប្រទេសជាមួយនឹងកងកម្លាំងយោធាក្នុងក្រុម ដើម្បីមកវាយប្រយុទ្ធជាមួយទាហាន លន់ នល់ នៅ ជាប់ទល់ដែនតាមបណ្តោយជួរភ្នំដងរែក។ ក្រោយមកខ្ញុំ និង



ចម្ការចេកមួយកន្លែងដែលស្ថិតនៅជាប់ជើងភ្នំដងរែក

ទឹកដីអន្លង់វែង ប្រៀបបានជាទីតាំងមួយដ៏វិសេសវិសាល ដែលបន្តប់ទៅដោយប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅ នៃការចងចាំរបស់ប្រជាជនកម្ពុជាគ្រប់ជំនាន់។ ប្រជាជនដែលរស់នៅអន្លង់វែងភាគច្រើនគឺជាអតីតខ្មែរក្រហម និងក្រុមគ្រួសាររបស់យោធាខ្មែរក្រហម ដែលបានបន្តរស់នៅដោយពឹងផ្អែកទៅលើរបរកសិកម្ម ធ្វើស្រែ ចម្ការ ដើម្បីទ្រទ្រង់ជីវភាព កងកម្លាំងក្នុងក្រុម ក៏បានធ្វើដំណើរមកដល់តំបន់អន្លង់វែង។ ពេលនោះខ្ញុំបានទៅឈរជើងនៅត្រង់ភូមិចម្ការចេក ដែលដើមឡើយជាភូមិចាស់របស់ខ្មែរក្រហម ហើយក្លាយជាភូមិសន្តិភាពក្នុងស្រុកអន្លង់វែងនាពេលបច្ចុប្បន្ន។

នៅអន្លង់វែង ខ្ញុំបានប្រកបរបរជាកសិករចាប់តាំងពីសមាហរណកម្មឆ្នាំ ១៩៩៨មក ៖ រួមមានទាំងដំណាំស្រូវ

និងដំណាំប្រភេទបន្លែផ្សេងទៀតដើម្បីលក់យកកម្រៃមកផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារ។ សម្រាប់ប្រភេទដំណាំបន្លែរួមមាន៖ ត្រឡាច ននោង ប៉េងប៉ោះ និងផ្កាខាត់ណា ជាដើម។ ខ្ញុំបានប្រើប្រាស់ជីធម្មជាតិ ដែលខ្ញុំបានធ្វើវាដោយខ្លួនឯងមកថែបំប៉នដំណាំដែលខ្ញុំដាំ ហើយបន្ទាប់មក ខ្ញុំតែងតែដឹកជញ្ជូនកសិផលដែលទទួលបាន ទៅលក់នៅឯផ្សារអន្លង់វែង ដោយឆ្លងកាត់ស្ពានចំណាស់មួយរបស់ តាម៉ុក»។

ប្រជាជនទាំងឡាយដែលរស់នៅតំបន់នេះភាគច្រើនជាជនពិការដោយសារបុព្វហេតុតស៊ូក្នុងចលនាខ្មែរក្រហម។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះគឺសហគមន៍ដ៏កម្សត់មួយនេះ ពុំទាន់ទទួលបានការផ្សះផ្សាឲ្យកាន់តែស៊ីជម្រៅនិងទូលំទូលាយនៅឡើយទេ។ ប្រជាជននៅសហគមន៍អន្លង់វែង ភាគច្រើនទទួលបានការយោគយល់ពីក្រុមអតីតតស៊ូដូចគ្នា ប៉ុន្តែក៏ទទួលរងនូវការរើសអើងពីប្រជាជនថ្មីមួយចំនួនដែលធ្វើដំណើរពីចម្ងាយ និងចំពោះប្រជាជនដែលមានជីវភាពធូរធារជាងខ្លួន។

អែម សេង អាយុ៥៧ឆ្នាំ មានទីកន្លែងកំណើតនៅខេត្តក្រចេះ បានលើកឡើងថា «ខ្ញុំឃើញថា សូម្បីតែអតីតអ្នកធ្លាប់តស៊ូជាមួយគ្នា ក៏មានការរើសអើងចំពោះខ្ញុំដែរ មិនដូចកាលដែលយើងធ្លាប់លំបាកលំបិននៅក្នុងព្រៃនោះទេ ដោយសារតែក្រោយពេលសមាហរណកម្មនៅឆ្នាំ១៩៩៨ អ្នកខ្លះបានទទួលតួនាទីជាពេទ្យ ហើយអ្នកខ្លះទៀតក៏ទទួលមុខតំណែងជាមន្ត្រីរាជការជាដើម។ ធ្វើដូចម្ដេច បើខ្ញុំជាជនពិការ?»

ជាម ទ្រឹម អាយុ៦០ឆ្នាំ មានទីកន្លែងកំណើតនៅខេត្តក្រចេះ និងជាអតីតយោធាខ្មែរក្រហមមួយរូបដែរបានលើកឡើងថា «ចំពោះយុវជនជំនាន់ក្រោយមួយចំនួន ក៏បានរើសអើងចំពោះអតីតអ្នកតស៊ូដូចជារូបខ្ញុំនេះដែរ ដោយគាត់ពុំបានយល់ពីតម្លៃនៃការតស៊ូ និងទំហំទឹកចិត្តក្នុងបុព្វហេតុជាតិមាតុភូមិនោះឡើយ ដែលអ្នកទាំងនោះមើលឃើញតែសម្បកក្រៅប៉ុណ្ណោះចំពោះក្រុមអតីតតស៊ូ»។ អន្លង់វែងប្រៀបបានទៅនឹងមជ្ឈមណ្ឌលកុមារកំព្រាមួយ ដែលប្រជាជនរាប់សិបនាក់ដែលធ្វើដំណើរមកដល់ទីនេះ សុទ្ធសឹងតែជាតែអ្នកបែកបាក់ពីក្រុមគ្រួសារ និងចាកចេញពីតំបន់ផ្សេងៗគ្នា។

ញឹម នន ភេទស្រី អាយុ៧០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិពងទឹក ឃុំគោកពោធិ៍ ស្រុកទ្រាំង ខេត្តតាកែវ បានរៀបរាប់ពីបទពិសោធន៍ជីវិតរបស់ខ្លួន និងការធ្វើដំណើរដ៏



ពើយតាម៉ុក ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពរួមនិងជាចក្ខុវិស័យដ៏វែងឆ្ងាយរបស់ខ្មែរក្រហម

វែងឆ្ងាយមកកាន់តំបន់អន្លង់វែងថា៖ នៅឆ្នាំ១៩៧០ ខ្ញុំបានសម្រេចចិត្តចូលបម្រើការងារជាកងនារីឃោសនា និងកងនារីដឹកជញ្ជូនរបស់ខ្មែរក្រហមនៅក្នុងស្រុកកំណើត។

លុះដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានផ្ញើសំបុត្រមួយច្បាប់មកកាន់ខ្ញុំ អំពីការស្នើឲ្យខ្ញុំវិលត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ ដើម្បីមើលថែឪពុករបស់ខ្ញុំ ដែលកំពុងធ្លាក់ខ្លួនឈឺជាទម្ងន់នៅឯផ្ទះ។ ប៉ុន្តែអ្វីដែលគួរឲ្យសោកស្ដាយ

និងវិប្បដិសារីរបស់ខ្ញុំមកទល់ពេលបច្ចុប្បន្ននេះ គឺខ្ញុំពុំបានវិលត្រឡប់ទៅជួបឪពុករបស់ខ្ញុំ ទៅតាមខ្លឹមសារនៃសំបុត្រដែលបានសរសេរនោះឡើយ រហូតដល់គាត់បានលាចាកលោកនេះទៅ។

បន្ទាប់ពីមរណៈភាពរបស់ឪពុកខ្ញុំនៅ ឆ្នាំ១៩៧៣ សភាពការណ៍នៅក្នុងខេត្តតាកែវ គឺមានភាពរឹករវយ៉ាងខ្លាំងជាពិសេសនៅម្តុំផ្សារអង្គតាសោម ដែលស្ថិតនៅប៉ែកខាងលិចខេត្តតាកែវ ដែលពេលនោះ ខ្ញុំកំពុងតែធ្វើជាកងដឹកជញ្ជូនគ្រាប់រំសេវនៅទីនោះដែរ។ ក្រោយពីធ្វើការនៅទីនោះបានមួយរយៈ ខ្ញុំក៏បានផ្លាស់ប្តូរមករស់នៅក្នុងមន្ទីរ១៥០ «ក» ក្រោមការចាត់តាំងរបស់ខ្មែរក្រហម។ ទោះជាយ៉ាងនេះក្តី ខ្ញុំពុំបានរស់នៅក្នុងមន្ទីរនោះជាប់លាប់នោះទេ ព្រោះខ្មែរក្រហមផ្លាស់ប្តូរខ្ញុំឲ្យធ្វើជាកងបង្កបង្កើនផលខាងកសិកម្មនៅ ក្នុងភូមិកំណើត ដើម្បីផ្គត់ផ្គង់ដល់កងទ័ពនៅតាមបណ្តោយសមរភូមិក្នុងខេត្តតាកែវ។ការរស់នៅក្នុងអង្គភាពផលិត ការ ចិញ្ចឹមសត្វ និងការដាំដុះ គឺជាការផ្លាស់ប្តូរដ៏សំខាន់បំផុតសម្រាប់កងអង្គភាពរបស់ខ្ញុំ។


អូរស្វាយ ជាប្រភពទឹកដែលហូរធ្លាក់ពីលើខ្នងភ្នំដងរែក

ជីវិតរស់នៅក្នុងកងអង្គភាពផលិត ហាក់មានភាពប្រសើរជាងតិចតួចណាស់ បើប្រៀបធៀបទៅនឹងជីវិតរស់នៅរបស់ប្រជាជនក្នុងសហករណ៍។ មិនយូរប៉ុន្មានខ្មែរក្រហមក៏បានរំសាយអង្គភាពផលិតស្បៀងនេះចោល ហើយប្តូរទៅជាអង្គភាពកែច្នៃសម្ភារធ្វើអំពីដីឥដ្ឋវិញម្តង ដែលនៅទីនោះមានទីតាំងស្ថិតនៅក្នុងបរិវេណ វត្តអង្គកែវ។ មួយរយៈក្រោយមក រោងចក្រដ៏ស្តួចស្តើងមួយនេះក៏បានដួលរលំទៅវិញបន្ទាប់ពីសង្គ្រាមខ្មែរក្រហមបានផ្ទុះឡើង ឥតឈប់ឈរជាមួយកងទ័ពវៀតណាមនៅចុងឆ្នាំ១៩៧៨។

ពេលនោះ ខ្ញុំ និងប្តីរបស់ខ្ញុំដែលត្រូវបានខ្មែរក្រហមផ្សំផ្គុំនៅឆ្នាំ១៩៧៧ ព្រមទាំងប្រជាជនជាច្រើននាក់ផងនោះក៏បានធ្វើដំណើរដោយរទេះគោ ដើម្បីចាកចេញពីស្រុកកំណើតនារដូវប្រាំង ហើយឆ្ពោះទៅកាន់តំបន់មួយចំនួននៅជាប់ទល់ដែនថៃ ដើម្បីគេចផុតពីការតាមយាយីរបស់កងទ័ពវៀតណាម។ ដំបូងឡើយ ខ្ញុំនិងប្រជាជនដែលភៀសខ្លួនទៅជាមួយ បានធ្វើដំណើរទៅដល់អូរមួយដែលស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង និងស្នាក់នៅទីនោះអស់រយៈពេលមួយសប្តាហ៍។ បន្ទាប់មក ខ្ញុំក៏បានធ្វើដំណើរទៅកាន់ខេត្តពោធិ៍សាត់នៅម្តុំចម្ការក្រូចមួយកន្លែង និងបានរស់នៅទីនោះ ប្រមាណជាកន្លះខែ។ លុះធ្វើដំណើរជាច្រើនខែកន្លងមករដូវវស្សាក៏ឈានចូលមកដល់ ដែលធ្វើឲ្យទឹកអូរឡើងជន់លិច និងបង្កជាការរាំងស្ទះដល់ការធ្វើដំណើររបស់ខ្ញុំ។ ស្របពេលនោះកងកម្លាំងវៀតណាម ក៏បានដេញបាញ់ប្រហារ ប្រកិតពីក្រោយ ទើបខ្ញុំសម្រេចចិត្តបោះបង់សត្វគោ និងរទេះចោលដើម្បីបន្តដំណើរដោយថ្មើរជើងទៅកាន់ទល់ដែនថៃ។

នៅពេលនោះ មនុស្សម្នាជាច្រើនក៏ត្រូវបានបាត់បង់ជីវិតដែរ ដោយសារការអត់អាហារ និងការលង់ទឹកស្លាប់នៅពេលឆ្លងអូរទៅត្រើយម្ខាងទៀត។ប្រជាជនមួយចំនួន ត្រូវបានទឹកជំនន់បោកគួចយកទៅ ដោយគ្មានថ្ងៃត្រឡប់

មកវិញឡើយ។ ចំណែកខ្ញុំផ្ទាល់ បានឆ្លងអូរដោយតោងវល្លិ៍ផ្តៅ និងមានសម្ភារមួយចំនួន ដូចជា ចាន ឆ្នាំងស្ពាយជាប់នឹងខ្លួនផងដែរ។ បន្ទាប់ពីឆ្លងអូររួចហើយ ខ្ញុំនិងកងកម្លាំងប្រជាជនដែលសេសសល់ ក៏បានបន្តធ្វើដំណើរដោយឆ្លងកាត់ភ្នំជាច្រើន និងចំណាយពេលប្រមាណជា២០ថ្ងៃទើបមកដល់ទឹកដីថៃ។ទីតាំងដំបូង ដែលខ្ញុំបានទៅរស់នៅក្នុងទឹកដីថៃគឺខ្លងយៃ ដែលបុរស និងស្ត្រី ត្រូវរស់នៅដាច់ដោយឡែកពីគ្នា និងពុំអនុញ្ញាតឲ្យយោធារស់នៅទីនោះឡើយ ហើយចំពោះរោងស្នាក់នៅវិញគឺត្រូវសង់ដោយខ្លួនឯង។

បន្ទាប់ពីរស់នៅទីនោះបានកន្លះខែ ខ្ញុំនិងប្រជាជនត្រូវបានតម្រួតថៃ ផ្លាស់ចេញពីខ្លងយៃ ហើយបញ្ជូនទៅកាន់ជំរំភៀសខ្លួនត្រាង។ ការរស់នៅក្នុងជំរុំភៀសខ្លួនត្រាងភាពអត់ឃ្លាន ក៏នៅតែជាបញ្ហាចោទសម្រាប់ជនភៀសខ្លួនដូចជាខ្ញុំ និងប្រជាជនជាច្រើននាក់ផ្សេងទៀតដដែល។ ពេលនោះ ខ្ញុំក៏បានដើរដកបន្លែផ្អី និងដីកទំពាំងយកមកស្ងោជាមួយអំបិលដើម្បីបរិភោគបណ្តោះអាសន្ន។ មិនយូរប៉ុន្មាន ខ្ញុំក៏បានធ្វើដំណើរចាកចេញពីទឹកដីត្រាង ហើយបន្តទៅរស់នៅក្នុងស្រុក១០០ ក្នុងទឹកដីថៃ។ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំបានបន្តធ្វើដំណើរទៅកាន់ទឹកដីស្រះកែវ ដែលនៅទីនោះគឺមានការរៀបចំជាផ្ទះសម្បែងជាជួរៗ ដើម្បីឲ្យប្រជាជនខ្មែរដែលភៀសខ្លួនរស់នៅក្នុងអំឡុងឆ្នាំ១៩៨០។ បន្ទាប់មកខ្ញុំ និងប្តីរបស់ខ្ញុំបាននាំគ្នាទៅអាររណើ (ក្តារ) នៅទឹកដីបឹងត្រកួនដោយប្រើរណាដៃ ដើម្បីយកឈើទាំងនោះទៅលក់ឲ្យជនជាតិថៃដែលភាគ ច្រើនសុទ្ធសឹងតែជាដើមស្រឡៅ និងប្រភេទឈើផ្សេងៗដែលអាចយកធ្វើផ្ទះបាន។ ពេលនោះខ្ញុំក៏ដូចជាប្រជាជន ដទៃទៀតដែរ គឺតែងតែនាំគ្នាធ្វើកិច្ចការផ្សេងៗក្នុងការទទួលបានប្រាក់កាស ដើម្បីទិញរបស់របរមួយចំនួនក្នុងទឹកដីថៃ ហើយ កាកបាទក្រហម គឺនៅតែបន្តគាំទ្រដល់ជនភៀសខ្លួនដូចខ្ញុំជានិច្ច។ ក្រោយមកខ្ញុំបានផ្លាស់ពីទឹកដីបឹងត្រកួនហើយមករស់នៅក្នុងភូមិ៥០ ដែលនៅទីនោះសណ្ឋានដីមានរាងដូចជាបាតខ្ទះ ហើយហ៊ុមព័ទ្ធទៅដោយភ្នំជាពិសេសគឺមានជំរំរបស់ជនភៀសខ្លួន ដែលបោះទីតាំងនៅទីនោះយ៉ាងច្រើនកុះករ។ ដោយសារសភាពការណ៍មិនអំណោយផលដែលបង្កឡើងដោយការវាយប្រហារពីកងកម្លាំងរដ្ឋាភិបាលនៅតាមចង្កេះភ្នំផងនោះ ខ្ញុំក៏បានសម្រេចចិត្តចាកចេញពីភូមិ៥០ហើយ មករស់នៅក្នុងភូមិ៤០វិញម្តង។

ការរស់នៅក្នុងភូមិ៤០ គឺគ្រប់គ្រងដោយ តាម៉ុក និងពឹងផ្អែកទាំងស្រុងទៅលើតាម៉ុក។ក្រោយមកយើងបានធ្វើដំណើរ មកកាន់តំបន់អន្លង់វែង បន្ទាប់ពីបានទៅរស់នៅក្នុងទឹកដីជាំស្វាបានមួយរយៈនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ខ្ញុំនិងគ្រួសារបានធ្វើដំណើរចុះពីលើភ្នំដងរែក រួចធ្វើដំណើរនៅលើដងផ្លូវដែលក្រាលទៅដោយខ្សាច់ និងថ្មធំៗ រហូតមកដល់មន្ទីរពេទ្យរបស់ តាម៉ុក (ដែលបច្ចុប្បន្នក្លាយជាមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង)។ខ្ញុំបានធ្វើដំណើរដោយឆ្លងកាត់បឹងអូរជីក ដែលកាលណោះតាម៉ុកពុំទាន់លើកជាទំនប់នៅឡើយទេ ដែលមានទឹកហូរល្ហឹងល្ហើយនៅរដូវវស្សាហើយហួតហែងទៅវិញនៅរដូវប្រាំង។ បឹងនេះក៏បានឆក់យកជីវិតរបស់ប្រជាជននៅអន្លង់វែងជាច្រើននាក់ ដែលតែងតែកើតឡើងនៅពេលរដូវវស្សាឈានមកដល់ម្តងៗ ព្រោះនៅពេលនោះប្រជាជនពុំទាន់មានស្ពានដើម្បីឆ្លងបឹងនេះនៅឡើយទេ។

សាមគ្គីភាពរបស់ប្រជាជនអន្លង់វែងក្រោមការគ្រប់គ្រងរបស់ តាម៉ុក បានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈទិដ្ឋភាពនៃការឆ្លងទឹកជំនន់ ដែលប្រជាជនទាំងឡាយត្រូវតោងដៃគ្នាដើម្បីឆ្លងកាត់មកត្រើយម្ខាងទៀត។ តាមការសង្កេតមើលប្រជាជនភាគច្រើន ដែលធ្លាប់មានដំណើរជីវិតមកកាន់សហគមន៍អន្លង់វែង គឺតែងតែផ្សាភ្ជាប់ជីវិតរស់នៅរបស់ខ្លួនទៅនឹងសហគមន៍នេះជាអចិន្ត្រៃយ៍ ទោះបីជាសង្គ្រាមត្រូវបានផុតរលត់ទៅហើយយ៉ាងណាក៏ដោយ។ ប្រជាជនស្ទើរតែទាំងស្រុងដែលរស់នៅសហគមន៍អន្លង់វែង គឺតែងតែមានសាច់រឿងយ៉ាងសម្បូរបែបរៀងៗខ្លួន ដែលមនុស្សជំនាន់ក្រោយគួរតែសិក្សាស្វែងយល់ពីឯកសាររស់ក្នុងសហគមន៍មួយនេះដើម្បីបុព្វហេតុផ្សះផ្សា និងសន្តិភាព។ **សួត វិចិត្រ**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**(តពីលេខមុន)**

ប្រែង សំអុល ហៅប្រាង អុល មានអាយុ៥១ឆ្នាំក្នុងឆ្នាំ ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀមខេត្តកំពង់ចាម ជាកូនរបស់លោកតា ប្រែង ប្រាង និងលោកយាយ គល់ ចិន មានប្រពន្ធឈ្មោះ តាំងលាង ស៊ីម មានកូនប្រុស៤នាក់ និង ស្រី៤នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែឆ្នាំ ដដែល។

ឆន សារិន ហៅ ញាតិ មានអាយុ២០ឆ្នាំ ក្នុងឆ្នាំ ១៩៧៧មានស្រុកកំណើតនៅចំការលើខេត្តកំពង់ចាម ជាកូន របស់ពូឆននិងមីង រឿន វ បានខ្មែរក្រហមចាប់ខ្លួននៅពេទ្យ ៩៨ថ្ងៃទី៦ខែមករាឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី ២៣ខែមីនា ឆ្នាំ១៩៧៧បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៧ថ្ងៃ។ឆានត្រេសហៅសេងបញ្ជាការវរៈសេនាតូចកងពល ២៩០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រ ហមសម្លាប់ឆានត្រេសហៅសេងនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

ឆាយ គឹមហេង ហៅ ហន មានអាយុ២៧ឆ្នាំក្នុងឆ្នាំ ១៩៧៦អតីតនិស្សិតច្បាប់ឆ្នាំទី១ មានស្រុកកំណើតនៅព្រៃ កប្បាស ខេត្តតាកែវជាកូនរបស់ពូ ឆាយ ហ៊ិត និងមីង នាង យូនីវមានប្រពន្ធឈ្មោះ នាងគោស៊ីសុដាន មានកូនប្រុស៣ នាក់ និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្រុកភ្នំស្រុក ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅ គុកទួលស្លែងក្នុងផ្ទះក០២បន្ទប់ធំ១០។ខ្មែរក្រហមចាប់បញ្ជូន ឆាយ គឹមហេង មកដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែមីនា ឬថ្ងៃទី៣០ខែតុលាឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជា ក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆាយ គឹមលាងហៅអូនមានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀមខេត្តកំពង់ចាមជាកូនរបស់ ពូឆាយ ប៉ាន់ និងមីង សេង យិម មានប្រពន្ធឈ្មោះដូរ សុក ហៀង ហៅ អេង ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល ៤៥០ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយសម្លាប់ចោល នៅថ្ងៃទី៦ ខែកក្កដាឆ្នាំ១៩៧៧។ ឆាយ ចេង ត្រូវបានខ្មែរ ក្រហមចាប់ខ្លួននៅកងពល៧០៣ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែឆ្នាំដដែល។

ឆាយ ចេង ហៅ ដាត មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើត នៅសំរោង ខេត្តតាកែវ ជាកូនរបស់ពូឆាយ ផៃ និងមីង ស្វាយ ថែម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង ពល៥០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯក សារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆាយ ម៉េង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារ កម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យ សហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជារកឃើញថាឈ្មោះឆាយ ម៉េងសរសេរថា ចាយ ម៉េង ត្រូវបានខ្មែរក្រហម ចាប់បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃ ទី២៥ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៥ខែតុលាឆ្នាំ ១៩៧៦។

ឆាយ រាសី មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុក កំណើតនៅកោះក្រឡខេត្តបាត់ដំបងជាកូនរបស់ពូឆាយគុយ និងមីងឡាំង អ៊ុក មានប្តីឈ្មោះអង់ជ្រេហ្គាស្តុងមានកូនប្រុស ១នាក់និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ ខ្លួននៅកំពង់ក្តី សៀមរាបថ្ងៃទ១៤ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅ

ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ០៤។ ខ្មែរក្រហមសម្លាប់ ឆាយ រាសី នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៦។ ប្តីក៏ត្រូវបាន យកមកសម្លាប់ចោលដែរ។ សូមមើលរកឈ្មោះ គួរទីញ អង់ដ្រេហ្គាស្តុង ។

ឆាយ សារិនកម្មកររទេះភ្លើងត្រូវបានខ្មែរក្រហមចាប់ ខ្លួនក្នុងឆ្នាំ១៩៧៦។ ឆាយ សារិន ចូលមកដល់គុកទួលស្លែង នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់នៅថ្ងៃទី៦ ខែឆ្នាំដដែល។ សូមរកមើលឈ្មោះប្តីគង់សុត ក្នុងព្យញ្ជនៈ អក្សរ«គ»។

ឆាយ ប៊ួយ មានអាយុ២៥ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មាន ស្រុកកំណើតនៅខេត្តកណ្តាលជាកូនរបស់ពូ ឆាយ ហេង និងមីង ជា ហ្គេច មានប្តីឈ្មោះ គង់ អាន មានកូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំពេញថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៥ ហើយសម្លាប់ចោលនៅថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ១៩៧៦ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល ១៦០ថ្ងៃ។

ឆាំ ប៊ុនរឿង កូនកម្មកររទេះភ្លើងត្រូវបានខ្មែរក្រហម ឃាត់ខ្លួននៅកន្លែងរថភ្លើងក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯក សារ បញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆាំ ខន មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំ ណើតនៅមង្គលបុរីខេត្តបាត់ដំបង ជាកូនរបស់លោកតា ឆាំ ខាន់ និងលោកយាយ អ៊ុំ ប៉ាន់ មានប្រពន្ធឈ្មោះ គីម លាន មានកូនប្រុស២នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ ខ្លួននៅភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅ ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះឃ បន្ទប់ធំ០៤បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ ឆាំ ខន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ ប្រពន្ធឈ្មោះ គីម លានឬតាំង គីមលាន ត្រូវបានខ្មែរក្រហម ចាប់បញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់ គឺថ្ងៃទី២៨។

ឆី យឿន មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំ ណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាមជាកូនរបស់ពូឆី រ៉ន និងមីង សេងទុងត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រឡតដ្ឋ អ៣ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៧ ហើយសម្លាប់ចោលនៅថ្ងៃទី៦ ខែមីនាឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤២ ថ្ងៃ។

ឆឹម ណារីជាប្រពន្ធរបស់ ព្រាបឌឹមត្រូវបានខ្មែរក្រហម ឃាត់ខ្លួននៅ២១ឃថ្ងៃទី៨ខែ វិច្ឆិកា ឆ្នាំ១៩៧៦ហើយសម្លាប់ ចោលនៅថ្ងៃបន្ទាប់គឺថ្ងៃទី៩។ ចំណែកឯ ព្រាប ឌឹម ជាប្តីត្រូវ បានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែងមុនប្រពន្ធអស់ ជាច្រើនខែគឺនៅថ្ងៃទី២០ខែកុម្ភៈឬថ្ងៃទី៤ខែមេសាឆ្នាំ១៩៧៦ ។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់ ព្រាបឌឹមនៅឡើយ។

ឆឹមសៀន មានអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុក កំណើតនៅមេមត់ខេត្តកំពង់ចាម ជាកូនរបស់ពូ ស៊ុន និងមីង សយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននរោងចក្រ ក១០ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួល ស្លែងក្នុងផ្ទះដ បន្ទប់ធំ០៣ បន្ទប់តូច៥។ នៅពុំទាន់មានឯក សារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆឹត ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំ ពង់សោមថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ បើយោងតាមឯក សារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយក ទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជ អាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញ ថា ឆឹតមានឈ្មោះហៅផ្សេងទៀតច្រើនដូចជា ចឹត ឬឆើត អិម ជងត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោមតាំងតែពី ថ្ងៃទី២២ខែធ្នូឆ្នាំ១៩៧៥។ ខ្មែរក្រហម បញ្ជូនឆឹតមកដល់ ទួលស្លែងនៅថ្ងៃទី៧ខែឧសភាឆ្នាំ១៩៧៦ និងសម្លាប់ចោល នៅថ្ងៃទី២៨ខែឆ្នាំដដែល។

ឆឹយ ធឿន ហៅ ឈិន មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្រុក២០ (ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ពូឆាយឆឹយ និងមីងពៅមៀចជាជាងជួសជុល យន្តហោះត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំង នៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ

០៧ បន្ទប់តូច ៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថាឆើយ ឈិនត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយនៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆុង ឆេង ឆេន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា ឆុង ឆេងមានឈ្មោះហៅក្រៅឆេនត្រូវបានខ្មែរក្រហមចាប់បញ្ជូន មកដល់គុកទួលស្លែងនៅថ្ងៃទី១៣ខែកញ្ញាឆ្នាំ១៩៧៦។នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឆើយ ណារ៉ាង មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញជាកូនរបស់អ៊ំ ម៉ម ឆើយ និងអ៊ំស្រី ជុំ រឿង មានប្រពន្ធឈ្មោះ សួន ផល្លី មានកូនប្រុស៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើង ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះចបន្ទប់ធំ៣បន្ទប់តូច៨។ ខ្មែរក្រហមសម្លាប់ឆើយណារ៉ាង នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ ឆើយណារ៉ាងជាប់ឃុំឃាំងនៅគុកទួលស្លែងរយៈពេល៩៣ថ្ងៃ។

ឆេង គី មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១៨(ស្រុកកោះធំ)ខេត្តកណ្តាល ជាកូនរបស់ពូគីតឆេងនិងមីងអៀង ចឺន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរពិការ៥០២ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ០៨ បន្ទប់តូច ១១។ កាលបរិច្ឆេទមកដល់គុកទួលស្លែងរបស់ ឆេង គី មានដល់ទៅ៣ផ្សេងគ្នាគឺថ្ងៃទី៣ខែមករា ឆ្នាំ១៩៧៦, ថ្ងៃទី៣០ ខែមករាឆ្នាំ១៩៧៦ និងថ្ងៃទី១៨ខែមីនា ឆ្នាំ១៩៧៦។ខ្មែរក្រហមសម្លាប់ឆេងគីនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។

ឆេង ជុនសឿន មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់អ៊ំ មួងឆយ និងអ៊ំស្រី ព្រឿង ប្រាង មានប្ដីឈ្មោះមូរេនមានកូនប្រុស១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនអគ្គីសនីផ្សារតូចថ្ងៃទី៧ ខែធ្នូឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះកបន្ទប់ធំ០៦បន្ទប់តូច៨។ ឆេង ជុនសឿន ឬឆេង ជនសឿន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ខែមេសាឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៥ខែឧសភាឆ្នាំ១៩៧៦ បន្ទាប់ជាប់ឃុំឃាំងអស់រយៈពេល៤១ថ្ងៃ។

មូ រេន ឬមូរ៉េន ជាប្ដីត្រូវបានខ្មែរក្រហមចាប់ បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៦ឬ១៣ខែមេសា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ជាមួយប្រពន្ធដែរ។

ឆេង តិចហាក់ មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅ ពញាឮ ខេត្តកណ្ដាលជាកូនរបស់ ពូឆេង ស៊ា និងមីងប៊ិន ហេងត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ថានីយរទេះភ្លើង ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ៨ បន្ទប់ធំ២ បន្ទប់តូច១៥។ ឆេង តិចហាក់ ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ឬ២១ខែវិច្ឆិកាឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

ឆេង ថា ហៅ ខាវ មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់ពូមី និងមីង សុង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**(តទៅលេខក្រោយ)**

**វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**



រូបទី១រាប់ពីខាងស្តាំ ៖ នួន ជា
រូបទី២រាប់ពីខាងស្តាំ ៖ កុយ ធួន
រូបទី៣រាប់ពីខាងស្តាំ ៖ ភ្ញៀវជនជាតិចិន

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 225, September 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.